







# កត្តាសំខាន់ៗដែលមានឥទ្ធិពលដល់ភាពជោគជ័យ ក្នុងការគ្រប់គ្រងសហគមន៍នេសាទ



# កត្តាសំខាន់ៗដែលមានឥទ្ធិពលដល់ភាពជោគជ័យ ក្នុងការគ្រប់គ្រងសហគមន៍នេសាទ

ម.ព.ឯ.ក AIDOC
Code: 141-022
Date:
Donated by:

រៀបចំដោយ

គំរោងគ្រប់គ្រងសហគមន៍នេសាទ

បោះពុម្ពនៅឆ្នាំ ២០០៦

ទស្សនៈដែលមាននៅក្នុងអត្ថបទនីមួយៗនៃសៀវភៅនេះ គឺជាគំនិតរបស់អ្នកនិពន្ធ ហើយនិងមិនឆ្លុះបញ្ចាំងពី
បណ្ដាដៃគូដែលគាំទ្រនោះទេ ។

**សៀវភៅនេះមាននៅ:**


រដ្ឋបាលជលផល (FiA)
ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ (CFDO)
ផ្ទះលេខ ១៨៦, វិថីព្រះនរោត្តម, សង្កាត់ទន្លេបាសាក់,
ខណ្ឌចំការមន, ប្រអប់សំបុត្រលេខ ៥៨២,
ភ្នំពេញ, កម្ពុជា
គេហទំព័រ: www.twgf.org / www.maff.gov.kh

វិទ្យាស្ថាន គ្រប់គ្រងធនធានធម្មជាតិដោយមាន
ការចូលរួមពីសហគមន៍ (CBNRM LI )
ផ្ទះលេខ ៣០, ផ្លូវលេខ ៩, សង្កាត់ទន្លេបាសាក់,
ខណ្ឌចំការមន, ប្រអប់សំបុត្រលេខ ២៥០៩, ភ្នំពេញ, កម្ពុជា
អ៊ីម៉ែល: info@cbnrmli.org / office@cbnrmli.org
គេហទំព័រ: www.cbnrmli.org


**កែសម្រួលដោយ:**


លី វុទ្ធី
ស៊ឹម ប៊ុនធឿន
វីប៉ែកកា ហ្គីប
ថូប៊ី ខាហ្សិន


**រចនាដោយ:**


ហៃ សុចិត្រ
សំអឿន សុធីរ៉ូ


**បណ្ដាដៃគូដែលគាំទ្រ**


មជ្ឈមណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា (IDRC)
រដ្ឋបាលជលផល (FiA) / ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ (CFDO)
វិទ្យាស្ថាន គ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (CBNRM LI)


IDRC CRDI CANADA

CBNRM Towards Sustainable Livelihoods



# មាតិកា


**អារម្ភកថា** ៤

**សេចក្តីថ្លែងអំណរគុណ** ៦

**បញ្ជីពាក្យបំព្រួញ** ៨

**និយមន័យនៃពាក្យគន្លឹះ** ៩

**សេចក្តីសង្ខេប** ១០

**សេចក្តីផ្តើម និង សាវតាគម្រោង** ១៤

**ករណីសិក្សាទី ១ :** ការនេសាទល្មើសច្បាប់នៅសហគមន៍នេសាទតំបន់ឆ្នេរ ឃុំថ្មស (ករណីសិក្សាក្នុងសហគមន៍នេសាទ ឃុំថ្មស ស្រុកបទុមសាគរ ខេត្តកោះកុង) ២២

រៀបរៀងដោយ: លោក សរិត សំបូរ, លោក សោម ពិសិដ្ឋ, លោក ព្រំ គឹមហ និងលោក គូ ហ៊ុយលាង

**ករណីសិក្សាទី ២ :** ការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទ កំពង់ក្រសាំង (ករណីសិក្សា ឃុំកំពង់ក្រសាំង ស្រុកបូរីជលសា ខេត្តតាកែវ) ៣៦

រៀបរៀងដោយ: លោក ទិត ភារៈ, លោក អ៊ូ សុផាន, លោកស្រី ចាន់រតនា, លោក ណែម កាណា និងលោក ប៉ែន មករា

**ករណីសិក្សាទី ៣ :** កិច្ចសហប្រតិបត្តិការណ៍របស់អ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព (ករណីសិក្សា នៅសហគមន៏នេសាទភ្មៀត-កោះពងសត្វ ឃុំភ្មៀត និងកោះពងសត្វ ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ) ៥៤

រៀបរៀងដោយ: លោក ជាម ប៉េអា, លោក រុន វិសិទ្ធិ, កញ្ញា យិន គឹមសួរ, លោក ស៊ុក វិន និងលោក នូវ លាង

**ការវិភាគ និងសំយោគមតិ** ៧៤

រៀបរៀងដោយ: លោក ស៊ិម ប៊ុនធឿន, លោក លី វុទ្ធី, លោក គឹម ណុង, លោកស្រី សូ ស្រីមុំ និង Rebecca Rivera-Guieb

**ឯកសារយោង** ៨០

**ឧបសម្ព័ន្ធ** ៨១

អ្នករួមសហកានៅក្នុងគម្រោង ៨១

មតិឆ្លុះបញ្ចាំងរបស់ក្រុមអ្នកនិពន្ធអំពីដំណើរការករណីសិក្សានេះ ៨៦



# អារម្ភកថា

ប្រទេសកម្ពុជា គឺជាប្រទេសមួយដែលប្រជាពលរដ្ឋពឹងផ្អែកទៅលើធនធានធម្មជាតិ និងដីកសិកម្មសម្រាប់ផ្គត់ផ្គង់ស្បៀងអាហារ និងជីវភាពរស់នៅរបស់ខ្លួន ក្នុងនោះវិស័យជលផលបានដើរតួនាទីយ៉ាងសំខាន់មិនត្រឹមតែរួមចំណែកក្នុងការលើកកំពស់សេដ្ឋកិច្ចជាតិប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាប្រភពផ្តល់នូវប្រាក់ចំណូលការងារធ្វើ និងសន្តិសុខស្បៀងដល់ប្រជាពលរដ្ឋកម្ពុជាទូទៅ ជាពិសេសចំពោះអ្នកដែលរស់នៅតំបន់ជនបទ ។

នៅខែ តុលា ឆ្នាំ ២០០០ រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចធ្វើការកែទម្រង់វិស័យជលផលដោយបានកាត់បន្ថយ និងលុបនាទីឡូត៍នេសាទប្រមាណជាង ៥៦% នៃផ្ទៃឡូត៍នេសាទសរុបទូទាំងប្រទេសស្មើនឹង ៥៣៨,៥២២ ហត. ជូនប្រជាពលរដ្ឋមូលដ្ឋានប្រើប្រាស់ជាលក្ខណៈគ្រួសារតាមរយៈការរៀបចំសហគមន៍នេសាទ ។ នៅក្នុងគោលនយោបាយកំណែទម្រង់នេះ រាជរដ្ឋាភិបាលបានចាត់ទុកការរៀបចំ និងគ្រប់គ្រងសហគមន៍នេសាទ ជាការងារដ៏មានអាទិភាពមួយក្នុងចំណោមកិច្ចការសំខាន់ៗរបស់វិស័យជលផល។ ក្នុងរយៈពេល ៦ ឆ្នាំកន្លងទៅនេះនាយកដ្ឋានជលផល (បច្ចុប្បន្នប្តូរជា រដ្ឋបាលជលផល) បានធ្វើការសម្របសម្រួល និងជម្រុញដល់ដំណើរការរៀបចំបង្កើតសហគមន៍នេសាទនៅទូទាំងប្រទេសបានយ៉ាងសកម្ម ។ គិតមកដល់ដំណាច់ឆ្នាំ ២០០៦ សហគមន៍នេសាទដែលបានរៀបចំហើយមានចំនួនសរុប ៥០៩ សហគមន៍ ក្នុងនោះសហគមន៍នេសាទនៅតំបន់ទឹកសាបមានចំនួន ៤៦៩ សហគមន៍ និង សហគមន៍នេសាទនៅតំបន់ឆ្នេរមានចំនួន ៤០ សហគមន៍ ។ សហគមន៍នេសាទទាំងនេះកំពុងស្ថិតនៅក្នុងដំណាក់កាលមួយដែលទាមទារឱ្យមានការជួយជ្រោមជ្រែងថែមទៀតក្នុងការពង្រឹងនូវគុណភាពរបស់ខ្លួន ។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ រដ្ឋបាលជលផលបានសហការជាមួយនឹងដៃគូ និងអ្នកពាក់ព័ន្ធនានាជាច្រើនក្នុងការបំពេញការងារដោយបានរៀនសូត្រនូវបទពិសោធន៍ពីការអនុវត្តន៍ជាក់ស្តែង និងបានចាត់វិធានការដោះស្រាយចំពោះបញ្ហាមួយចំនួនដែលពាក់ព័ន្ធ នឹងសហគមន៍នេសាទ ។

សៀវភៅករណីសិក្សានេះ គឺជាឧទាហរណ៍មួយដ៏ល្អដែលបញ្ជាក់អំពីការខិតខំប្រឹងប្រែងរបស់រដ្ឋបាលជលផលក្នុងកិច្ចសហការជាមួយដៃគូដែលបាន និងកំពុងបំពេញភារកិច្ចជួយដល់សហគមន៍នេសាទ ។ សៀវភៅនេះ គឺជាសមិទ្ធិផលមួយដែលកើតចេញពីកិច្ចសហការរវាងការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៃរដ្ឋបាល



ជលផល និងវិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ដែលបានចងក្រងឡើងអំពីរឿងរ៉ាវ និងបទពិសោធន៍នានារបស់សហគមន៍នេសាទសម្រាប់ជាមូលដ្ឋានក្នុងការបន្តនូវកិច្ចខិតខំប្រឹងប្រែងជួយដល់សហគមន៍នេសាទដើម្បីការពារធនធានជលផលនៅក្នុងមូលដ្ឋានរបស់ខ្លួនឱ្យបានរឹងមាំ និងដើម្បីរួមចំណែកលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រនៅតំបន់ជនបទឱ្យកាន់តែមានភាពប្រសើរឡើង ។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា ដែលបានជួយឧបត្ថម្ភដល់ការសិក្សាស្រាវជ្រាវករណីសិក្សានេះ ហើយក៏សូមថ្លែងអំណរគុណ និងកោតសរសើរដល់កិច្ចខិតខំប្រឹងប្រែងរបស់អ្នកពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមចំណែកដ៏ថ្លៃថ្លានៅក្នុងការសិក្សាស្រាវជ្រាវនេះ។ យើងសូមឧទ្ទិសសៀវភៅនេះដល់សហគមន៍នេសាទ និងអ្នកពាក់ព័ន្ធទាំងអស់នៅក្នុងប្រទេសកម្ពុជាក្នុងស្មារតីថែរក្សា និងប្រើប្រាស់ធនធានជលផលរបស់យើងឱ្យមានភាពគង់វង្សជារៀងដរាប ។

**ណៅ ធូក**

ប្រធានរដ្ឋបាលជលផល

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



# សេចក្តីថ្លែងអំណរគុណ

ក្រុមការងារសិក្សាស្រាវជ្រាវ និង ចងក្រងសៀវភៅករណីសិក្សានេះសូមថ្លែងអំណរគុណចំពោះ មជ្ឈមណ្ឌលអភិវឌ្ឍន៍អន្តរជាតិ (IDRC) នៃប្រទេសកាណាដា ដែលបានផ្តល់នូវទំនុកចិត្ត និង ការគាំទ្រថវិការនៅក្នុងដំណើរការអនុវត្តគម្រោងការកសាងសមត្ថភាពដល់ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទដោយទទួលបាននូវលទ្ធផលគួរជាទីមោទនៈ។

ជាពិសេស ក្រុមការងារសិក្សាស្រាវជ្រាវ សូមសម្តែងនូវអំណរគុណ និង ការដឹងគុណយ៉ាងជ្រាលជ្រៅចំពោះឯកឧត្តម **ណៅ ធួក** ប្រធានរដ្ឋបាលជលផលដែលបានផ្តល់ការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារស្រាវជ្រាវ ដោយធ្វើឱ្យការសិក្សាជ្រាវនេះសម្រេចបានជោគជ័យ ។ ជាមួយគ្នាផងដែរ សូមថ្លែងអំណរគុណចំពោះថ្នាក់ដឹកនាំ និង មន្ត្រីការិយាល័យជលផលខេត្តបន្ទាយមានជ័យ តាកែវ និង កោះកុង ដែលបានគាំទ្រ និង សហការនៅក្នុងការសិក្សាស្រាវជ្រាវនេះដោយទទួលលទ្ធផលជាទីពេញចិត្ត ។

ក្រុមការងារសិក្សាស្រាវជ្រាវ សូមថ្លែងអំណរគុណចំពោះលោកស្រី Rebecca Rivera-Guieb និង លោក ស៊ឹម ប៊ុនធឿន ដែលជាអ្នកសម្របសម្រួលដល់ការរៀបចំករណីសិក្សានេះតាំងពីចាប់ផ្តើមរហូតដល់ចប់ ហើយកិច្ចការនេះក៏មានការចូលរួមចំណែកពី លោកស្រី សូ ស្រីមុំ មកពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ លោកស្រី អ៊ឹម ម៉ារ៉ាឌី មកពីគំរោងស្រាវជ្រាវសហគមន៍ព្រៃឈើ លោក គឹម ណុង មកពីក្រសួងបរិស្ថាន ព្រមទាំងមន្ត្រីរបស់វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍មួយចំនួនទៀតផង ។

លើសពីនេះទៅទៀត សូមថ្លែងអំណរគុណយ៉ាងជ្រាជ្រៅចំពោះលោក កែន សេរីរដ្ឋា នាយកវិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ និង លោក Toby Carson ទីប្រឹក្សាគម្រោងដែលបានជួយដល់ដំណើរការនៃករណីសិក្សានេះ។

ជាចុងក្រោយ ក្រុមការងារសិក្សាស្រាវជ្រាវ និង ចងក្រងសៀវភៅករណីសិក្សានេះ សូមកោតសរសើរ និងដឹងគុណយ៉ាងជ្រាលជ្រៅចំពោះគណៈកម្មការ និង សមាជិកសហគមន៍នេសាទ ព្រមទាំងប្រជាពលរដ្ឋនៅក្នុង

សហគមន៍នេសាទ ដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សាស្រាវជ្រាវនេះ ជាពិសេសចំពោះរដ្ឋអំណាចភូមិ ឃុំពាក់ព័ន្ធទាំងអស់ដែលបានរួមសហការ និង បង្កភាពងាយស្រួលដល់ក្រុមសិក្សាជ្រាវចុះយកព័ត៌មាននៅតាមមូលដ្ឋាននីមួយៗបានទទួលជោគជ័យ ។

ដោយសារការរួមចំណែក និង កិច្ចសហការគាំទ្រដ៏ថ្លៃថ្លាទាំងអស់នេះហើយទើបការងារសិក្សាស្រាវជ្រាវ និង ការចងក្រងអត្ថបទករណីសិក្សានេះទទួលបានជោគជ័យ ។

**លោក លី វុទ្ធី**

ប្រធានដឹកនាំគម្រោង

សហគមន៍នេសាទ ដែលត្រូវបានជ្រើសរើសសម្រាប់ការសិក្សាស្រាវជ្រាវនេះ ជាពិសេសចំពោះរដ្ឋអំណាចភូមិឃុំពាក់ព័ន្ធទាំងអស់ដែលបានរួមសហការ និង បង្កភាពងាយស្រួលដល់ក្រុមសិក្សាជ្រាវចុះយកព័ត៌មាននៅតាមមូលដ្ឋាននីមួយៗបានទទួលជោគជ័យ ។

ដោយសារការរួមចំណែក និង កិច្ចសហការគាំទ្រដ៏ថ្លៃថ្លាទាំងអស់នេះហើយទើបការងារសិក្សាស្រាវជ្រាវ និង ការចងក្រងអត្ថបទករណីសិក្សានេះទទួលបានជោគជ័យ។

**លោក លី វុទ្ធី**

ប្រធានដឹកនាំគម្រោង



# បញ្ជីពាក្យបំព្រួញ

| | |
|---|---|
| CBNRM LI | វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (Community-Based Natural Resource Management Learning Institute) |
| CF | សហគមន៍ព្រៃឈើ (Community Forestry) |
| CFO | ការិយាល័យសហគមន៍ព្រៃឈើ (Community Forestry Office) |
| CFDO | ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ (Community Fisheries Development Office) |
| CFDU | ក្រុមអភិវឌ្ឍន៍សហគមន៍នេសាទ (Community Fihseries Development Unit) |
| CFMP | គម្រោងគ្រប់គ្រងសហគមន៍នេសាទ (Community Fisheries Management Project) |
| CPADO | ការិយាល័យអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ (Community Protected Area Development Office) |
| FiA | រដ្ឋបាលជលផល (Fisheries Administration) |
| IDRC | មជ្ឈមណ្ឌលស្រាវជ្រាវដើម្បីអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសកាណាដា (International Development Research Centre) |
| MRRF | គម្រោងគ្រប់គ្រងអាងទឹក និងទន្លេនៃអាងទន្លេមេគង្គ (Management of River and Reservoir Fisheries in the Mekong Basin |
| OA | អង្គការអុកស្វាមអាមេរិក (Oxfam American) |
| PFO | ការិយាល័យជលផលថ្នាក់ខេត្ត (Provincial Fisheries Office) |
| PLUP | ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី (Participatory Land Use Planning) |
| RECOFTC | មជ្ឈមណ្ឌលបណ្តុះបណ្តាលព្រៃឈើសហគមន៍ប្រចាំតំបន់អាស៊ី និងប៉ាស៊ីភិច (Regional Community Forestry Training Center) |
| TSEMP | គម្រោងគ្រប់គ្រងបរិស្ថាននៅបឹងទន្លេសាប (Tonle Sap Environmental Management Project) |
| UNTAC | អង្គការ UNTAC (United Nations Transitional Authority Cambodia) |
| WWF | អង្គការមូលនិធិពិភពលោកសម្រាប់អភិរក្សធម្មជាតិ (Worldwide Fund for Nature ) |



# និយមន័យនៃពាក្យគន្លឹះ

**អន្លង់អភិរក្ស :** គឺជាអន្លង់ទឹកជ្រៅ ដែលមានជម្រៅប្រមាណពី ៧-១០ ម៉ែត្រនៅរដូវវស្សា និង ១-២ ម៉ែត្រនៅរដូវប្រាំង។ អន្លង់ជ្រៅ គឺជាទីជម្រករបស់មច្ឆជាតិជាច្រើនប្រភេទ ជាពិសេសនៅរដូវប្រាំង។

**ឈិបយន្ត "រុញដោយម៉ាស៊ីន" (ឌុន) :** គឺជាឧបករណ៍នេសាទសមុទ្រដែលធ្វើពីសាច់មងក្រឡា ០.៦០ សម ឬ ស្បៃម៉ុងនីឡុង រាងដូចសាជី និង ដូចឧបករណ៍ជនទឹកសាប មានចំពាស់ឈើពីរដើម ប្រវែងពី ១៥ ម-១៧ម ភ្ជាប់ដោយទ្រនាប់ជ័ររាងដូចស្នូក ស្បែកជើងស្ថិតនៅខាងចុងឈើ ហើយភ្ជាប់នឹងទូកយន្តដែលមានកំលាំងម៉ាស៊ីនពី ១៥-២៤សេះ គេប្រើប្រាស់សំរាប់ចាប់បង្គា ឬត្រីតូចៗ គ្រប់ប្រភេទនៅតំបន់ឆ្នេរសមុទ្រ (ជម្រៅទឹកតិចជាង ២០ ម៉ែត្រ) ដែលច្បាប់ត្រូវបានហាមឃាត់ ។

**អួនអូស :** ជាឧបករណ៍នេសាទសមុទ្រ ធ្វើពីសាច់មងក្រឡា ១,៥០សម ដល់ ៥សម អូសទាញដោយទូកយន្ត មានកំលាំងម៉ាស៊ីនចាប់ពី៣៣សេះឡើង មានរាងប្រហាក់ប្រហែលនឹងដាយចាប់ត្រីទឹកសាបមានខ្សែព្ួរ រនងលើក្រោម អង្កត់ផ្ចិត ទំហំ ១០ មម. កំសួលសំណា ក្តារតាខេ នឹងខ្សែកាប អង្កត់ផ្ចិត ទំហំ ១០ មម. ភ្ជាប់ពីអួនទៅទូកយន្ត ដោយប្រើសម្រាប់ចាប់ត្រី និងបង្គា គ្រប់ប្រភេទ ។



# សេចក្ដីសង្ខេប



# សេចក្តីសង្ខេប

ការកែទម្រង់គោលនយោបាយវិស័យជលផលរបស់រាជរដ្ឋាភិបាល ដែលបានធ្វើឡើងកាលពីចុងឆ្នាំ ២០០០ បាននាំមកនូវអត្ថប្រយោជន៍យ៉ាងធំធេងដល់ប្រជាពលរដ្ឋ ដែលរស់នៅក្នុងតំបន់ជនបទ ជាពិសេសអ្នកដែលមានមុខរបរពឹងផ្អែកលើធនធានជលផល។ ការកែទម្រង់នេះ គឺជាការចែករំលែកនូវសិទ្ធិអំណាច ក្នុងការគ្រប់គ្រងធនធានជលផលដល់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន តាមរយៈការបង្កើតសហគមន៍នេសាទដើម្បីចូលរួមគ្រប់គ្រងថែរក្សាការពារ និងប្រើប្រាស់ធនធានជលផលនៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយសមធម៌ និងមានចីរភាព។

រដ្ឋបាលជលផល (ពីមុនជានាយកដ្ឋានជលផល) បានខិតខំបំពេញភារកិច្ចរបស់ខ្លួន ក្នុងការសម្របសម្រួលរៀបចំសហគមន៍នេសាទយ៉ាងសកម្ម ដោយទទួលបាននូវលទ្ធផលគួរជាទីកត់សំគាល់។ គិតមកដល់ដំណាច់ឆ្នាំ ២០០៦ សហគមន៍នេសាទ ដែលបានរៀបចំហើយមានចំនួនសរុប ៥០៩ សហគមន៍ ក្នុងនោះសហគមន៍នេសាទនៅតំបន់ទឹកសាបមានចំនួន ៤៦៩ សហគមន៍ និងសហគមន៍នេសាទនៅតំបន់ឆ្នេរមានចំនួន ៤០ សហគមន៍។ សហគមន៍នេសាទទាំងនេះកំពុងស្ថិតនៅក្នុងដំណាក់កាលមួយដែលទាមទារឱ្យមានការជួយជ្រោមជ្រែងថែមទៀត ក្នុងការពង្រឹងនូវគុណភាពរបស់ខ្លួន។ នៅក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងទៅនេះ រដ្ឋបាលជលផលបានសហការជាមួយនិងដៃគូ និងអ្នកពាក់ព័ន្ធនានាជាច្រើនក្នុងការបំពេញការងារ ដោយបានរៀនសូត្រនូវបទពិសោធន៍ពីការអនុវត្តន៍ជាក់ស្តែង និងបានចាត់វិធានការដោះស្រាយចំពោះបញ្ហាមួយចំនួនដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ។

ដើម្បីឆ្លើយតបទៅនិងតំរូវការ និងសំណូមពររបស់សហគមន៍មូលដ្ឋាន គម្រោងកសាងសមត្ថភាពដើម្បីគ្រប់គ្រងសហគមន៍នេសាទ CBCFM Project បានជួយឧបត្ថម្ភដល់ការកសាងសមត្ថភាពដល់បុគ្គលិកការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ CFDO និងបុគ្គលិកសមភាគីខេត្ត ដែលជាមន្ត្រីផ្នែកអភិវឌ្ឍន៍សហគមន៍នេសាទ CFDU ។

សកម្មភាពផ្តួចផ្តើមនេះ គឺទទួលបានការគាំទ្រពីមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) នៃប្រទេសកាណាដា ហើយកំពុងអនុវត្តដោយការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ នៃរដ្ឋបាលជលផលចាប់តាំងពីឆ្នាំ ២០០៣ មកក្នុងកិច្ចសហការជាមួយវិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិ CBNRM Learning Institute ។ គម្រោងបានផ្តល់ការឧបត្ថម្ភដល់សហគមន៍នេសាទចំនួន ៣ ដែលបានជ្រើសរើសសម្រាប់ការសាកល្បង គឺសហគមន៍នេសាទកំពង់ក្រសាំងស្ថិតនៅក្នុងខេត្តតាកែវ សហគមន៍នេសាទភ្លៀត-កោះពងសត្វ ក្នុងខេត្តបន្ទាយមានជ័យ និងសហគមន៍នេសាទឃុំថ្មស នៅខេត្តកោះកុង។

បុគ្គលិកគម្រោងបានរួមចំណែកធ្វើអោយប្រសើរឡើងនូវដំណើរការនៃសហគមន៍នេសាទក្នុងប្រទេសកម្ពុជា ដោយមានការស្វែងយល់យ៉ាងច្បាស់អំពីតម្រូវការនៃការកសាងសមត្ថភាពដល់ប្រជាជននៅក្នុងមូលដ្ឋានដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ ការឆ្លុះបញ្ចាំង និងការពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធដំណើរការសសេរករណីសិក្សា និងការវិភាគគឺជាយុទ្ធសាស្ត្រក្នុងការឆ្លុះបញ្ចាំង ការធ្វើផែនការ ការរៀបចំឯកសារ និងការអនុវត្តន៍សកម្មភាព។

សៀវភៅករណីសិក្សានេះ គឺមានប្រធានបទចំនួន ៣ ដែលបានរៀបចំ និងចងក្រងឡើងក្នុងគោលបំណងដើម្បីឆ្លុះបញ្ចាំងអំពីបទពិសោធន៍ និងស្ថានភាពជាក់ស្តែងផ្សេងៗគ្នាដែលកើតមាននៅក្នុងសហគមន៍នេសាទចំនួន ៣ កន្លែង ក្នុងនោះ ប្រធានបទទី ១ លើកឡើងអំពីការធ្វើនេសាទល្មើសច្បាប់នៅក្នុងឃុំថ្មសរ ខេត្តកោះកុង ប្រធានបទទី២ លើកឡើងអំពីការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាជននៅក្នុងសហគមន៍នេសាទកំពង់ក្រសាំង ខេត្តតាកែវ និងប្រធានបទទី ៣ លើកឡើងអំពីកិច្ចសហប្រតិបត្តិការរបស់អ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព។

ប្រធានបទទី១ រៀបចំដោយ លោក សរិត សំបូរ លោក ព្រំ គឹមហ លោក សោម ពិសិទ្ធ និង លោក គួ ហ៊ុយលាង បានធ្វើការរៀបរាប់អំពីមូលហេតុដែលនាំឱ្យប្រជាពលរដ្ឋនៅក្នុងឃុំថ្មសរ ក្នុងខេត្តកោះកុង ធ្វើការនេសាទដោយប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់។ សកម្មភាពទាំងនេះបានបណ្តាលឱ្យមានបញ្ហាជម្លោះរវាងអ្នកនេសាទធុនតូច និងអ្នកនេសាទធុនធំ ទន្ទឹមនិងនោះដែរបានធ្វើឱ្យផលនេសាទមានការថយចុះ។ ដូចនេះហើយ ទើបប្រជាពលរដ្ឋដែលរស់នៅក្នុងឃុំថ្មសរ បានធ្វើការស្នើសុំឱ្យមានការបង្កើតសហគមន៍នេសាទឡើងដើម្បីថែរក្សាការពារ និងប្រើប្រាស់នូវធនធានជលផលក្នុងតំបន់នេះឱ្យមានប្រសិទ្ធិភាព។

ប្រធានបទទី ២ រៀបចំ និងចងក្រងដោយ លោក ទិត ភារៈ លោក អ៊ូ សុផាន លោក ណែម កាណូ លោក ប៉ែន មករា និងអ្នកស្រី ចាន់ រតនា។ ប្រធានបទនេះបានបង្ហាញអំពីការប្រកបរបររបស់ប្រជាជននៅសហគមន៍នេសាទកំពង់ក្រសាំង ស្រុកបូរីជលសារ ខេត្តតាកែវ។ សហគមន៍នេសាទកំពង់ក្រសាំង ជាអតីត ឡូត៍នេសាទ លេខ១២ និងលេខ១៣ របស់ខេត្តតាកែវ ក្នុងកំឡុងមុនពេលមានកំណែទម្រង់វិស័យជលផល ជម្លោះតែងតែកើតមានរវាងអាជីវករឡូត៍នេសាទជាមួយប្រជានេសាទនៅក្នុងតំបន់។ ដោយមើលឃើញនូវកត្តាលំបាកទាំងនេះទើបរាជរដ្ឋាភិបាលកម្ពុជាបានកាត់ឡូត៍នេសាទលេខ១២ និងលេខ១៣ជូនប្រជាពលរដ្ឋធ្វើការប្រើប្រាស់ជាលក្ខណៈគ្រួសារតាមរយៈការបង្កើតសហគមន៍នេសាទ។ ក្រោយពីសហគមន៍សហគមន៍នេសាទកំពង់ក្រសាំងត្រូវបានបង្កើតឡើង ប្រជាពលរដ្ឋក្នុងតំបន់មានជីវភាពរីកចំរើនប្រសើរជាងមុនតាមរយៈការផ្តល់នូវការកសាងសមត្ថភាព និងផ្តល់ជាឥណទានខ្នាតតូចពីស្ថាប័នពាក់ព័ន្ធនានា និងគំរោង IDRC ដល់សហគមន៍ក្នុងការប្រកបរបរចិញ្ចឹមជីវិតបន្ថែមលើមុខរបរនេសាទប្រចាំថ្ងៃ។

ប្រធានបទទី ៣ រៀបចំដោយ លោក ជាម ប៉េអា លោក ស៊ុក វិន លោក នូវ លាង លោក រុន វិសិទ្ធ និងកញ្ញា យិន គឹមសួរ បានធ្វើការបង្ហាញអំពីកិច្ចសហប្រតិបត្តិការរបស់អ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាពនៅក្នុងសហគមន៍នេសាទភ្នៀតកោះពងសត្វ ដែលបច្ចុប្បន្នបានបង្កើតទៅជាសហព័ន្ធសហគមន៍នេសាទភ្នៀតកោះ–ពងសត្វ ស្រុកសេរីសោភ័ណ ខេត្តបន្ទាយមានជ័យ។ សហគមន៍នេសាទនេះ គឺជាសហគមន៍នេសាទគំរូមួយក្នុងចំណោមសហគមន៍នេសាទទាំងអស់ទូទាំងប្រទេសកម្ពុជាដែលបានទទួលមេដៃប្រាក់ពី សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាកាលពីឆ្នាំ២០០៥។ សហគមន៍នេសាទនេះបានទទួលជោគជ័យក្នុងការចូលរួមគ្រប់គ្រងថែរក្សាធនធានជលផល និងបានធ្វើកិច្ចសហការយ៉ាងល្អជាមួយអាជ្ញាធរដែនដី អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀត។



នៅក្នុងផ្នែកសំយោគមតិនៃអត្ថបទករណីសិក្សានេះ ដែលសរសេរដោយ ស៊ឹម ប៊ុនធឿន, លី វុទ្ធី, គិម ណុង, សូ ស្រីមុំ និង វីប៉ែកកា ហ្គីប បានបង្ហាញអំពី:

- ជាដំបូង ការចូលរួមយ៉ាងសកម្ម ការចំណាប់អារម្មណ៍ និងការតាំងចិត្តរបស់ប្រជាពលរដ្ឋក្នុងសហគមន៍ និងសមាជិកសហគមន៍នេសាទ
- ទីពីរ កិច្ចសហការរវាងអ្នកពាក់ព័ន្ធ និងបណ្តាញការងារ ដែលចាប់ផ្តើមក្នុងភាពជាដៃគូរជាមួយគណៈកម្មការសហគមន៍នេសាទ និងក្រុមប្រឹក្សាភូមិ ឃុំ គឺជាផ្នែកមួយយ៉ាងសំខាន់ក្នុងការគ្រប់គ្រងសហគមន៍នេសាទ ។
- ទីបី យុទ្ធសាស្ត្រយ៉ាងសាមញ្ញនៅមូលដ្ឋាន ដូចជាការបង្កើតក្រុមជួយខ្លួនឯង ជាជំហានឈ្ពោះទៅរកភាពប្រសើរឡើងក្នុងជីវភាពរស់នៅ ។
- ទីបួន ទីផ្សារគឺមានឥទ្ធិពលដល់ការសម្រេចចិត្តក្នុងការប្រើប្រាស់ និងទាញយកផលប្រយោជន៍ពីធនធានធម្មជាតិ
- ជាចុងក្រោយ ចំណុចរួមដែលបានលើកឡើងនៅក្នុងករណីសិក្សាទាំង៣ គឺប្រជាពលរដ្ឋនៅក្នុងសហគមន៍នេសាទមានជម្រើសតិចក្នុងការប្រកបមុខរបរចិញ្ចឹមជីវិត ហើយការរស់នៅរបស់ពួកគេគឺពឹងផ្អែកយ៉ាងខ្លាំងទៅលើធនធានជលផល

កត្តាសំខាន់៧ដែលមានឥទ្ធិពលដល់ភាពជោគជ័យក្នុងការគ្រប់គ្រងសហគមន៍នេសាទ ជាសៀវភៅករណីសិក្សាដែលលើកឡើងអំពីការគ្រប់គ្រងធនធានជលផល តាមរយៈសហគមន៍នេសាទដោយមានអ្នកជំនាញជាច្រើន បានធ្វើការរួមគ្នាដើម្បីចងក្រងនូវបទពិសោធន៍កើតមានជាក់ស្តែងនៅតាមមូលដ្ឋានដោយរៀបចំជាភាសាខ្មែរ និងភាសាអង់គ្លេស ។ លើសពីនេះទៅទៀត សៀវភៅនេះបានផ្តល់នូវមូលដ្ឋានក្នុងការវិភាគរាល់កត្តាពាក់ព័ន្ធនានា និងអំពីការចូលរួមរបស់ប្រជាពលរដ្ឋ ក៏ដូចជាអ្នកពាក់ព័ន្ធទាំងអស់ដើម្បីសម្រេចបានជោគជ័យក្នុងការគ្រប់គ្រងសហគមន៍នេសាទក្នុងប្រទេសកម្ពុជា ។



# សេចក្តីផ្តើម និងសាវតាគម្រោង



# សេចក្តីផ្តើម និងសាវតាគម្រោង

ដោយ ស៊ុម ប៊ុនធឿន, លី វុទ្ធី និង Rebecca Rivera-Guieb

គម្រោងកសាងសមត្ថភាពដើម្បីគ្រប់គ្រងសហគមន៍នេសាទ គឺជាការងារផ្តួចផ្តើមមួយដែលទទួលបានការគាំទ្រពីមជ្ឈមណ្ឌលស្រាវជ្រាវអភិវឌ្ឍន៍អន្តរជាតិ (IDRC) នៃប្រទេសកាណាដា ហើយកំពុងអនុវត្តដោយការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៃរដ្ឋបាលជលផលចាប់តាំងពីឆ្នាំ ២០០៣ មក ។ គម្រោងនេះបានជួយកសាងសមត្ថភាពដល់មន្ត្រីការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៅថ្នាក់ជាតិ និង មន្ត្រីផ្នែកអភិវឌ្ឍន៍សហគមន៍នេសាទនៅថ្នាក់ខេត្ត ។ ក្រៅពីនេះគម្រោងបានផ្តល់ការឧបត្ថម្ភដល់សហគមន៍នេសាទចំនួន ៣ ដែលបានជ្រើសរើសសម្រាប់ការសាកល្បង គឺសហគមន៍នេសាទកំពង់ក្រសាំង ស្ថិតនៅក្នុងខេត្តតាកែវ សហគមន៍នេសាទភ្លៀត កោះពងសត្វ ខេត្តបន្ទាយមានជ័យ និង សហគមន៍នេសាទឃុំថ្មស ខេត្តកោះកុង (រូបភាពទី ១ : ផែនទីកំណត់តំបន់គោលដៅរបស់ គម្រោង) ។

ដោយប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវដោយមានការចូលរួមគម្រោងមានគោលបំណងដើម្បី :

១. បង្កើនចំណេះដឹង និង ជំនាញរបស់មន្ត្រីការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និង មន្ត្រីផ្នែកអភិវឌ្ឍន៍សហគមន៍នេសាទ អំពីវិធីសាស្ត្រពាក់ព័ន្ធនឹងការគ្រប់គ្រងសហគមន៍នេសាទដែលជាគំរូសម្រាប់ការគ្រប់គ្រងសហគមន៍នេសាទនៅក្នុងប្រទេសកម្ពុជា
២. ជួយដល់ដំណើរការបង្កើត និង កែលំអសហគមន៍នេសាទនៅតំបន់គោលដៅសាកល្បងរបស់គម្រោង
៣. បង្កើនការយល់ដឹងរបស់គណៈកម្មការសហគមន៍នេសាទ អំពីច្បាប់ជលផលអនុក្រឹត្យស្តីពីសហគមន៍នេសាទ និង ជំហាននៃការរៀបចំសហគមន៍នេសាទ ព្រមទាំងជំនាញផ្សេងៗទៀត
៤. ជម្រុញកិច្ចសហការ និង រៀបចំបណ្តាញការងារជាមួយភាគីពាក់ព័ន្ធផ្សេងៗទៀតពាក់ព័ន្ធនឹងសហគមន៍នេសាទ ។

ពេលចាប់ផ្តើម សាកលវិទ្យាល័យ Dalhousie បានផ្តល់បច្ចេកទេសដល់គម្រោងតាមរយៈលោកបណ្ឌិត Gary F. Newkirk និង លោកស្រី Rebecca Rivera-Guieb ។ ចាប់តាំងពី ឆ្នាំ២០០៥ គម្រោងកសាងសមត្ថភាពនេះបានទទួលជំនួយបច្ចេកទេសបន្តតាមរយៈលោកស្រី Rivera-Guieb នៃវិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ និង មន្ត្រីផ្សេងៗទៀតរបស់វិទ្យាស្ថាននេះ ។

CBNRM LI និង ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទបានសហការគ្នាលើការងារមួយចំនួនដើម្បីរួមចំណែកនៅក្នុងដំណើរការសហគមន៍នេសាទក្នុងប្រទេសកម្ពុជារួមមាន : ការសិក្សាអំពីតម្រូវការនៃការកសាងសមត្ថភាពដល់ប្រជាជន



នៅក្នុងមូលដ្ឋានដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ ការឆ្លុះបញ្ចាំង និង ការពិគ្រោះយោបល់ជាមួយនឹងអ្នកពាក់ព័ន្ធ និងអ្នកដែលបានចូលរួមក្នុងការរៀបចំករណីសិក្សានេះ ។

ជាទូទៅករណីសិក្សាគឺជាការពិពណ៌នា និងវិភាគអំពីស្ថានភាពជាក់លាក់ណាមួយ។ ករណីសិក្សា គឺស្រដៀងគ្នាទៅនឹងការពិពណ៌នាអំពីរូបភាពអ្វីមួយប្រាប់ដល់អ្នកណាម្នាក់ដែលពុំធ្លាប់បានដឹងអំពីរូបភាពនោះ ។

ករណីសិក្សាមានលក្ខណៈពិសេសមួយ ពីព្រោះវាមានទម្រង់អាចបត់បែនបាន ហើយធ្វើឱ្យអ្នកនិពន្ធអាចបញ្ចេញនូវគំនិតច្នៃប្រឌិតរបស់ខ្លួនក្នុងការចែករំលែកបទពិសោធន៍នៅក្នុងសាច់រឿងរបស់គេ ។ ទន្ទឹមនេះ ករណីសិក្សាបង្ហាញពីការវិភាគបញ្ហាជាក់លាក់តាមរបៀបគួរឱ្យចាប់អារម្មណ៍ ។ ជាពិសេស ទាក់ទងនឹងការងារគ្រប់គ្រងធនធានដោយសហគមន៍ ករណីសិក្សាកាន់តែធ្វើឱ្យមានការចាប់អារម្មណ៍ និង ជាវិធីសាស្ត្រចូលរួមមួយយ៉ាងល្អ ប្រសិនបើករណីសិក្សានោះត្រូវធ្វើឡើងតាមរបៀបនៃការចូលរួមពីក្រុមអ្នកសរសេរនៅក្នុងដំណើរការទាំងមូលឱ្យបានពេលលេញ ។

ពាក្យករណីសិក្សាត្រូវបានយកទៅប្រើប្រាស់នៅក្នុងបរិបទ និង មានគោលបំណងខុសគ្នាៗ :

- ករណីសិក្សាដើម្បីចែករំលែកព័ត៌មានគម្រោង
- ករណីសិក្សាដើម្បីផ្លាស់ប្តូរមេរៀនដែលជាពិសោធន៍ល្អៗ
- ករណីរសិក្សាដើម្បីបញ្ចុះបញ្ចូលអ្នករៀបចំគោលនយោបាយ
- ករណីរសិក្សាខ្លីៗមួយចំនួនដើម្បីទាក់ទាញអ្នកអានបានយ៉ាងទូលំទូលាយ
- ករណីសិក្សាអំពីស្ថានភាពជាក់លាក់ណាមួយដែលអាចឱ្យសិស្សយកធ្វើជាមេរៀន
- ករណីសិក្សាដែលរៀបរាប់វែងអន្លាយ និង ក្បោះក្បាយដើម្បីទាក់ទាញអ្នកផ្តល់ជំនួយ

នៅប្រទេសកម្ពុជា តាមបណ្តាស្ថាប័នរបស់រដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធនានាបានរៀបចំករណីសិក្សា គឺផ្តោតទៅបទពិសោធន៍ដែលបានអនុវត្តនៅក្នុងគម្រោងនីមួយៗផ្សេងគ្នា ។ វិទ្យាស្ថាន CBNRM LI គឺជាអង្គការមួយដែលបាននិងកំពុងជំរុញការបង្កើតករណីសិក្សា ហើយនៅប៉ុន្មានឆ្នាំថ្មីៗនេះបានជួយសម្របសម្រួលការរៀបចំ និងបោះពុម្ពសៀវភៅករណីសិក្សាជាច្រើនទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ។ តាមបទពិសោធន៍នៅក្នុងប្រទេសកម្ពុជាយើង គឺមានលក្ខណៈពិសេសពីព្រោះការសរសេរករណីសិក្សាគឺនាំមកនូវការសាមគ្គីគ្នារវាងស្ថាប័នអភិវឌ្ឍន៍ ហើយធ្វើឱ្យមានទំនាក់ទំនងរវាងស្ថាប័នរដ្ឋជាមួយអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងបានរឹតចំណងមិត្តភាពរវាងអ្នកស្រាវជ្រាវទាំងឡាយអ្នកដែលបំពេញការងារនៅមូលដ្ឋាន និងអ្នកដែលបំពេញការងារពាក់ព័ន្ធនឹងការអភិវឌ្ឍន៍នៅក្នុងប្រទេស ។

គំនិតផ្តួចផ្តើមនៃការសរសេរករណីសិក្សានេះ គឺជាកិច្ចសហការរវាងវិទ្យាស្ថាន CBNRM LI និងការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ ដើម្បីគាំទ្រដល់កិច្ចការនៅក្នុងតំបន់សាកល្បងរបស់គម្រោងតាមរយៈការបណ្តុះបណ្តាលអំពីការវិភាគ និង សរសេរករណីសិក្សាដែលជាយុទ្ធសាស្ត្រសម្រាប់ធ្វើការឆ្លុះបញ្ចាំង ការធ្វើផែនការ ការចងក្រងឯកសារ និង ការធ្វើសកម្មភាព ។ ការបណ្តុះបណ្តាលត្រូវបានធ្វើឡើងជាបន្តបន្ទាប់ដែលមានរយៈពេលចំនួន ១ ឆ្នាំ ដោយមានការផ្លាស់ប្តូរមេរៀនជាបទពិសោធន៍ពីគ្នាទៅវិញទៅមករវាងមន្ត្រីរបស់ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និង មន្ត្រីរបស់ផ្នែកអភិវឌ្ឍន៍សហគមន៍នេសាទ អំពីការគ្រប់គ្រងសហគមន៍នេសាទ ។ ដំណើរការសិក្សាស្រាវជ្រាវករណីសិក្សានេះបានផ្តល់នូវឱកាសមួយដ៏ប្រសើរសម្រាប់សមាជិកសហគមន៍នេសាទ ប្រជាពលរដ្ឋក្នុងភូមិ និង ក្រុមប្រឹក្សាឃុំ ដើម្បីពិភាក្សាអំពីលទ្ធផលគម្រោងដែលបានអនុវត្តនៅក្នុងតំបន់នោះ ។ អ្នកសរសេរកណីសិក្សារួមមាន ក្រុមការងាររបស់ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និង ផ្នែកអភិវឌ្ឍន៍សហគមន៍នេសាទ ដោយបានសហការយ៉ាងជិតស្និទ្ធជាមួយនឹងដៃគូនានា និង ប្រជាជនមូលដ្ឋាននៅក្នុងតំបន់សាកល្បងរបស់គម្រោង ។

រូបភាពទី ២ បង្ហាញអំពីជំហាននៃការរៀបចំ និងសរសេរករណីសិក្សានេះ ។ ជំហាដំបូង គឺការរៀបចំសិក្ខាសាលាស្តីអំពីការសរសេរករណីសិក្សាដែលធ្វើឡើងនៅទីក្រុងភ្នំពេញមានរយៈពេល ៣ ថ្ងៃ ចាប់ពីថ្ងៃទី ១៩-២១ ខែមករា ឆ្នាំ ២០០៦ (ជំហានទី១) ។ នៅក្នុងសិក្ខាសាលានេះ គំនិតសំខាន់ស្តីអំពីករណីសិក្សាត្រូវបានលើកយកមកធ្វើការបកស្រាយ និង ពិភាក្សា ។ លើសពីនេះទៀត អ្នកចូលរួមសរសេរករណីសិក្សាបានបញ្ចេញទស្សនៈមតិនិងយោបល់ទាក់ទងនឹងការងារសហគមន៍នេសាទនៅក្នុងទីតាំងទាំង ៣ របស់គម្រោង ។ នៅពេលបញ្ចប់សិក្ខាសាលា ក្រុមអ្នកសរសេរករណីសិក្សាត្រូវបានរៀបចំឡើង ហើយក្រុមនីមួយៗបានរៀបចំផែនការដើម្បីដំណើរការសិក្សាស្រាវជ្រាវ ។ ប្រធានបទដំបូងត្រូវបានជ្រើសរើសសម្រាប់សរសេរករណីសិក្សា ហើយសំណួរស្រាវជ្រាវសំខាន់ក៏បានលើកយកមកពិភាក្សា និងឯកភាពគ្នា ។

នៅក្នុងខែជាបន្តបន្ទាប់មកទៀត មន្ត្រីរបស់ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និង មន្ត្រីរបស់ផ្នែកអភិវឌ្ឍន៍សហគមន៍នេសាទ បានចំណាយពេលវេលាចុះទៅមូលដ្ឋាននៃទីតាំងរបស់គម្រោង ដើម្បីពន្យល់ពីគំនិតផ្តួចផ្តើមនៃការសរសេរករណីសិក្សានេះដល់គណៈកម្មាធិការសហគមន៍នេសាទ ។ ក្រុមអ្នកសិក្សាស្រាវស្រាវក៏បានធ្វើការពិគ្រោះយោបល់ជាមួយអ្នកភូមិ អង្គការដៃគូ និង អ្នកពាក់ព័ន្ធដទៃទៀតអំពីប្រធានបទដែលបានលើកឡើងដើម្បីធ្វើការស្រាវជ្រាវនេះ ។ ជំហានទី ២ នៃដំណើរការនេះ គឺការបណ្តុះបណ្តាលដែលមានរយៈពេល ៣ ថ្ងៃ នៅទីក្រុងភ្នំពេញ ពីថ្ងៃទី ២៤-២៦ ខែមេសា ឆ្នាំ ២០០៦ ដោយមានការរួមពីអ្នកសរសេរករណីសិក្សាទាំងអស់ (ជំហានទី ២ និង ទី ៣) ។ អ្នកសរសេរករណីសិក្សាទាំងអស់មាន ១៤ នាក់ បែងចែកជា ៣ ក្រុម ក្នុងនោះក្រុមទី ១ មាន ៤ នាក់ គឺសិក្សាស្រាវជ្រាវនៅសហគមន៍នេសាទឃុំថ្មស ខេត្តកោះកុង ក្រុមទី ២ មាន ៥ នាក់ គឺសិក្សាស្រាវជ្រាវនៅសហគមន៍នេសាទ កំពង់ក្រសាំង ខេត្តតាកែវ និង ក្រុមទី ៣ មានគ្នា ៥ នាក់ គឺសិក្សាស្រាវជ្រាវនៅសហគមន៍ ភ្លៀត កោះពងសព្វ ខេត្តបន្ទាយមានជ័យ ។

នៅក្នុងក្រុមនីមួយៗ គឺមានមន្ត្រីរបស់ផ្នែកអភិវឌ្ឍន៍សហគមន៍នេសាទ ១ នាក់ចូលរួម ។ លើសពីនេះទៀត មានមន្ត្រីមកពីគម្រោងការចូលរួមគ្រប់គ្រងធនធានតំបន់ឆ្នេរ (PMCR) នៃក្រសួងបរិស្ថាន ចំនួន ៣ នាក់ ក៏បានចូលរួមនៅក្នុងការបណ្តុះបណ្តាលដែរ ក្នុងគោលបំណងដើម្បីសរសេរករណីសិក្សាសម្រាប់គម្រោងរបស់ខ្លួននៅក្នុងខេត្តកោះកុង ។ ការបណ្តុះបណ្តាលនៅភ្នំពេញនេះមានគោលបំណងដើម្បីពន្យល់ពីគោលគំនិត ដំណើរការ និង ទម្រង់នៃការសរសេរករណីសិក្សាឱ្យកាន់តែស៊ីជម្រៅ ។ អ្នកសរសេរករណីសិក្សាបានរៀនអំពីរបៀបចងក្រងគំនិតណែនាំ ខ្លឹមសារគោល កំណត់ក្រុមគោលដៅ និង គោលបំណងនៃករណីសិក្សា និង ការរៀបចំណងជើងសំខាន់ៗនៃករណីសិក្សា ។

បន្ទាប់ពីវគ្គបណ្តុះបណ្តាលនៅទីក្រុងភ្នំពេញ ក្រុមអ្នកសរសេរទាំង ៣ ក្រុមបានចុះទៅតាមទីកន្លែងដែលត្រូវធ្វើការសិក្សាស្រាវជ្រាវ ចាប់ពី ថ្ងៃទី ២០-៣០ ខែមេសា ឆ្នាំ ២០០៦ ដើម្បី: (១)ជួបសំណេះសំណាលជាមួយប្រជាជនមូលដ្ឋានអំពីគម្រោងផែនការដែលក្រុមអ្នកសរសេរបានរៀបចំឡើង (២) ប្រមូលទិន្នន័យផ្ទាល់ពីប្រជាពលរដ្ឋនៅក្នុងសហគមន៍ និង ឯកសារដែលមានស្រាប់ (ជំហានទី ៤) ។ បន្ទាប់ពីការស្រាវជ្រាវនៅតំបន់គម្រោងរួចមក ក្រុមសិក្សាស្រាវជ្រាវបានជួបជុំគ្នាដើម្បីធ្វើការចែករំលែកបទពិសោធន៍ទៅវិញទៅមក និង ពិនិត្យកែសម្រួលឡើងវិញនូវអ្វីដែលក្រុមនីមួយៗបានរៀបចំមុនពេលចុះទៅមូលដ្ឋាន ដោយផ្អែកលើមតិយោបល់ដែលប្រមូលបានពីប្រជាជននៅមូលដ្ឋាន (ជំហានទី ៥) ។ គួរកត់សំគាល់ផងដែរថា ក្រុមអ្នកសរសេរបានរៀបចំខ្លឹមសារគោល និង រៀបចំចំណងជើងសំខាន់ៗ នៃអត្ថបទករណីសិក្សាមុនពេលចុះទៅប្រមូលទិន្នន័យនៅមូលដ្ឋាន ។ មូលហេតុដែលក្រុមអាចរៀបចំមុនបាន គឺដោយសារតែមន្ត្រីរបស់ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និង មន្ត្រីរបស់ផ្នែកអភិវឌ្ឍន៍សហគមន៍នេសាទដែលចូលរួមនៅក្នុងក្រុមសិក្សាស្រាវជ្រាវនេះបានបំពេញការងារនៅទីក្នុងតំបន់គម្រោងសាកល្បងទាំង ៣ នេះ អស់រយៈពេល ៣ ឆ្នាំមកហើយ ដោយមានការយល់ដឹង និង ប្រមូលបាននូវព័ត៌មានសំខាន់ៗអំពីតំបន់ទាំងនេះយ៉ាងច្បាស់លាស់ ។ ជាក់ស្តែង កន្លងមកមន្ត្រីសមភាគីរបស់គម្រោង IDRC នៃការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ រួមជាមួយនឹងមន្ត្រីសមភាគីរបស់គម្រោងនៃផ្នែកអភិវឌ្ឍន៍សហគមន៍នេសាទតាមបណ្តាខេត្ត ទាំង ៣ បានធ្វើការប្រមូលព័ត៌មានដោយប្រើវិធីសាស្ត្រ PRA នៅក្នុងតំបន់ទាំង ៣ របស់គម្រោង ដើម្បីសរសេររបាយការណ៍សម្រាប់កំណត់វិសាលភាពដែលត្រូវអនុវត្ត និងកំណត់នូវបញ្ហាដែលកើតមាននៅក្នុងតំបន់ ទាំងនោះមុននឹងរៀបចំផែនការសកម្មភាពរបស់គម្រោង ។ម៉្យាងទៀត នេះមិនមែនជាលើកទីដំបូងទេដែលក្រុមអ្នកសរសេរករណីសិក្សាត្រូវប្រមូលព័ត៌មាននៅមូលដ្ឋាន ពីព្រោះនេះ គឺជាផ្នែកមួយនៃការងារដែលធ្លាប់បានធ្វើកន្លងមក ។

បន្ទាប់ពីការប្រមូលទិន្នន័យនៅមូលដ្ឋានរួចមក ជំហានបន្ទាប់មកទៀតគឺការបណ្តុះបណ្តាលនៅក្រុងព្រះសីហនុ ។ វគ្គបណ្តុះបណ្តាលនេះ គឺធ្វើឡើងពីថ្ងៃទី ១-៤ ខែឧសភា ឆ្នាំ២០០៦ (ជំហានទី ៦ និង ទី ៧) ។ នៅក្នុងវគ្គបណ្តុះបណ្តាលនេះ ក្រុមស្រាវជ្រាវនីមួយៗបានរៀបចំសរសេររបាយការណ៍ព្រាងលើកទី ១ ទៅតាមប្រធានបទរបស់ខ្លួន ។



បន្ទាប់មកសមាជិកក្រុមម្នាក់ៗបានប្តូរនូវកិច្ចការទៅវិញទៅមកដើម្បីជួយពិនិត្យមើល និង កែសម្រួលឱ្យបានសមស្រប ។ សមាជិកក្រុមស្រាវជ្រាវទាំងអស់បានរៀនសូត្រអំពីរបៀបផ្ទៀងផ្ទាត់អត្ថបទ និង រៀបចំចងក្រងផងដែរ ។ នៅទីបញ្ចប់ នៃការបណ្តុះបណ្តាលសមាជិកទាំងអស់បានបញ្ចេញទស្សនៈរបស់ខ្លួនអំពីដំណើរការនៃការសរសេររបាយការណ៍ករណីសិក្សា ។

បន្ទាប់ពីការបណ្តុះបណ្តាលមក អ្នកសរសេរករណីសិក្សាបានពិភាក្សាលើរបាយការណ៍ករណីសិក្សាជាមួយនឹងមន្ត្រីការិយាល័យជលផលខេត្ត និង ស្ថាប័នពាក់ព័ន្ធដ៏ទៃទៀត ។ នេះ គឺជាដំណើរការដ៏សំខាន់នៅក្នុងការសរសេរករណីសិក្សា ពីព្រោះមតិយោបល់ពីស្ថាប័នពាក់ព័ន្ធមានសារៈសំខាន់ មុនពេលរបាយការណ៍ ករណីសិក្សាត្រូវបានផ្សព្វផ្សាយជាសាធារណៈ ។ ជំហាបន្ទាប់មកទៀត គឺការបកប្រែឯកសារជាភាសាអង់គ្លេស ដើម្បីធ្វើការផ្ទៀងផ្ទាត់ចុងក្រោយ និង រៀបចំចងក្រងករណីសិក្សាទាំងអស់បញ្ចូលគ្នា (ជំហានទី ៨) ។

ពីថ្ងៃទី ៣០ ខែវិច្ឆិកា ដល់ថ្ងៃទី ១ ខែធ្នូ ឆ្នាំ ២០០៦ សិក្ខាសាលាបូកសរុបមតិត្រូវបានរៀបចំឡើងនៅខេត្តបាត់ដំបង។ នៅក្នុងសិក្ខាសាលានេះ តំណាងក្រុមអ្នកសរសេរករណីសិក្សាទាំង ៣ ក្រុមបានធ្វើបទបង្ហាញអំពីករណីសិក្សារបស់ខ្លួនម្នាក់ម្តងៗ ដើម្បីឱ្យសមាជិកទាំងអស់ធ្វើការផ្ទៀងផ្ទាត់ និង ផ្តល់នូវមតិយោបល់បន្ថែម ។ នេះ គឺជាឱកាសដ៏ល្អសម្រាប់ការវិភាគរួមគ្នា និង ការបូកសរុបមតិអំពីករណីសិក្សាទាំង ៣ ។ នៅទីបញ្ចប់ នៃសិក្ខាសាលាអ្នកចូលរួមទាំងអស់បានធ្វើការចាប់អារម្មណ៍រៀងៗខ្លួនអំពីដំណើរការ និង បទពិសោធន៍ទូទៅនៃការសរសេរករណីសិក្សា និង លើកឡើងនូវសំណូមពរមួយចំនួនដើម្បីកែលំអរដល់ដំណើរការនៅពេលក្រោយ (ជំហានទី ៩) ។

ជំហានចុងក្រោយ (ជំហាទី ១០) រៀបរាប់អំពីការដាក់សេចក្តីព្រាងចុងក្រោយឱ្យសមាជិករបស់ក្រុមទាំងអស់ធ្វើការពិនិត្យ និង កែសម្រួលជាចុងក្រោយមុននឹងធ្វើការបោះពុម្ព និង ផ្សព្វផ្សាយជាសាធារណៈ ។

សៀវភៅនេះ គឺជាលទ្ធផលមួយដែលកើតឡើងបន្ទាប់ពីបានឆ្លងកាត់ច្រើនជំហាននៃដំណើរការសរសេរករណីសិក្សានេះ ក្នុងនោះមានករណីសិក្សាចំនួន ៣ ដែលបានធ្វើការសិក្សាស្រាវជ្រាវទៅលើប្រធានបទខុសៗគ្នា នៅក្នុងតំបន់សាកល្បងទាំង ៣ របស់ គម្រោង IDRC របស់ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ ។ លទ្ធផលដែលបានរកឃើញនៅក្នុងការសិក្សាស្រាវជ្រាវនេះ អាចធ្វើជាមូលដ្ឋានសម្រាប់ធ្វើការវិភាគស្ថានភាព ឬបញ្ហានានាដែលអាចកើតមាននៅក្នុងសហគមន៍នេសាទផ្សេងទៀតនៅក្នុងប្រទេសកម្ពុជា ហើយក៏ជាបទពិសោធន៍មួយសម្រាប់បណ្តាប្រទេសផ្សេងទៀតនៅក្នុងពិភពលោកផងដែរ ។ ទោះបីជាយ៉ាងដូច្នេះក្តីករណីសិក្សានេះ គឺគ្រាន់តែជាការរួមចំណែកមួយដ៏តូចប៉ុណ្ណោះ បើប្រៀបធៀបនៅនឹងបទពិសោធន៍ដ៏ធំទូលាយដែលធ្លាប់កើតមានកន្លងមកពាក់ព័ន្ធនឹងសហគមន៍នេសាទ និងការងារអភិវឌ្ឍនៅក្នុងប្រទេសកម្ពុជា ។

រូបភាពទី ១: ផែនទីកំណត់តំបន់គោលដៅរបស់គម្រោង



## រូបភាពទី ២: ដំណើរការនៃការសរសេរករណីសិក្សា

### ជំហានទី ១

- ពិភាក្សាបញ្ហាសំខាន់ៗនៅក្នុងទីតាំងរបស់គម្រោងសាកល្បង ហើយផ្តល់យោបល់ក្នុងការជ្រើសរើសប្រធានបទសំរាប់ធ្វើការសិក្សា
- ណែនាំអំពីគំនិតសំខាន់ៗ
- ពិគ្រោះយោបល់នៅក្នុងតំបន់សិក្សា

១

### ជំហានទី ២

- រៀបចំគំនិតណែនាំ
- កំណត់ក្រុមគោលដៅ និង គោលបំណង

២

### ជំហានទី ៣

- រៀបចំខ្លឹមសារគោល
- រៀបចំចំណុចសំខាន់ៗដែលត្រូវសិក្សា

៣

### ជំហានទី ៤

ចុះស្រាវជ្រាវនៅមូលដ្ឋានដើម្បី :

- ពន្យល់សហគមន៍អំពីករណីសិក្សា ហើយទទួលយកមតិយោបល់កែលំអ
- ប្រមូទិន្នន័យដំបូង និងឯកសារដែលមានស្រាប់

៤

### ជំហានទី ៥

- ធ្វើការចែករំលែកបទពិសោធន៍ដែលបានពីមូលដ្ឋាន
- ពិនិត្យកែសម្រួលគោលបំណង
- កែលំអចំនុចសំខាន់ៗដែលត្រូវសិក្សា

៥

### ជំហានទី ៦

ចាប់ផ្តើមសរសេរព្រាងអំពី :

- សេចក្តីផ្តើម និង សេចក្តីសន្និដ្ឋាន
- សាវតារ និង ស្ថានភាពទូទៅ
- តួសេចក្តី (សាច់រឿង)

៦

### ជំហានទី ៧

- ពិភាក្សាជាក្រុមលើសេចក្តីព្រាងទី ១
- កែសម្រួល និង ការបញ្ចូលករណីសិក្សាទាំងអស់ជាមួយគ្នា
- កែសម្រួលឡើងវិញសេចក្តីព្រាងទី ១
- ធ្វើការឆ្លុះបញ្ចាំងអំពីដំណើរការ

៧

### ជំហានទី ៨

- ក្រុមអ្នកសរសេរពិភាក្សាសេចក្តីព្រាង ជាមួយការិយាល័យជលផលខេត្តនិងស្ថាប័នពាក់ព័ន្ធនានា
- CFDO និងCBNRM LI
- តាមដានក្រុមការងារដើម្បីផ្ទៀងផ្ទាត់ចុងក្រោយ និង រៀបរៀងបញ្ចូលគ្នា

៨

### ជំហានទី ៩

- បកប្រែ
- សិក្ខាសាលាបូកសរុបលទ្ធផលដើម្បីបង្ហាញករណីសិក្សានីមួយៗ និងវិភាគចំណុចរួមរបស់ករណីសិក្សា
- សរសេររបាយការណ៍រួម

៩

### ជំហានទី ១០

- ពិនិត្យ និងផ្ទៀងផ្ទាត់ចុងក្រោយ
- បោះពុម្ព
- ផ្សព្វផ្សាយ

១០



# ការនេសាទល្មើសច្បាប់នៅសហគមន៍តំបន់ឆ្នេរឃុំថ្មស



# ការនេសាទល្មើសច្បាប់នៅសហគមន៍តំបន់ឆ្នេរឃុំថ្មស

ករណីសិក្សាសហគមន៍នេសាទឃុំថ្មស ស្រុកបូទុមសាគរ ខេត្តកោះកុង


**ស្រាវជ្រាវ និងចងក្រងដោយ :**

លោក សរិត សំបូរ

លោក សោម ពិសិដ្ឋ

លោក ព្រំ គឹមហ

លោក គូ ហ៊ុយលាង



**សារគន្លឹះ:** សកម្មភាពនេសាទខុសច្បាប់ក្នុងសហគមន៍នេសាទតំបន់ឆ្នេរឃុំថ្មស បណ្តាលឱ្យធនធានជលផលថយចុះ និងប្រាក់ចំណូលពីការនេសាទថយចុះ


## ១. សេចក្តីផ្តើម

ឃុំថ្មសស្ថិតនៅក្នុងស្រុកបូទុមសាគរ ខេត្តកោះកុង ទិសពាយព្យនៃប្រទេសកម្ពុជាដែលលាតសន្ធឹងនៅតាមបណ្តោយឆ្នេរសមុទ្ររវាងខេត្តកោះកុង និងក្រុងព្រះសីហនុដែលមានចំងាយប្រមាណ ២៣៧ គីឡូម៉ែត្រពីទីរួមខេត្តកោះកុង និងប្រមាណ ៣៧គមពីក្រុងព្រះសីហនុ ។

ឃុំថ្មស មានភូមិចំនួនប្រាំគឺ ភូមិថ្មស ភូមិចំការលើ ភូមិថ្មី ភូមិស្រែត្រាវ និងភូមិចំលងគោ ។ ផ្អែកតាមស្ថិតិដែលរៀបចំឡើងដោយក្រុមប្រឹក្សាឃុំក្នុងឆ្នាំ២០០៥ប្រជាពលរដ្ឋសរុបនៅក្នុងឃុំថ្មសទាំងមូលមាន១៧៥៤គ្រួសារ គិតជាចំនួនមនុស្សមាន៩៥៣៨នាក់ក្នុងនោះស្រីមាន់ចំនួន៤៧៩៥នាក់ ហើយដង់ស៊ីតេប្រជាពលរដ្ឋនៅក្នុងឃុំមានចំនួនប្រមាណ ៤០នាក់ ក្នុង១គីឡូម៉ែត្រការ៉េ ។

ស្ថានភាពភូមិសាស្ត្រនៅក្នុងឃុំថ្មសមានសណ្ឋានចែកជាពីរប្រភេទ គឺតំបន់ជើងភ្នំនិងតំបន់ឆ្នេរសមុទ្រ ។ តំបន់ជើងភ្នំមានភូមិចំនួនពីរគឺភូមិស្រែត្រាវ និងភូមិថ្មី ប្រជាជនរស់នៅទីនោះអាចធ្វើស្រែធ្វើចំការសម្រាប់ទ្រទ្រង់ជីវភាពរស់នៅ។ ចំណែកតំបន់ឆ្នេរសមុទ្រមានចំនួន៣ភូមិ គឺភូមិថ្មស ភូមិចំលងគោ និងភូមិចំការលើ ហើយប្រជាជនរស់នៅ ក្នុងភូមិទាំង៣នេះគឺមានមុខរបរចំរុះជាងភូមិ២ទៀតរួមមានការធ្វើនេសាទ ការធ្វើស្រែចំការ ការចិញ្ចឹមសត្វ និងការលក់ដូរជាដើម ។

តំបន់ឆ្នេរថ្មសគឺជាកន្លែងដែលមានលក្ខណៈអំណោយផលយ៉ាងល្អប្រសើរចំពោះធនធានជលផល ជាពិសេសជាកន្លែងសម្បូណ៌បង្កា និងគ្រែងឈាមដែលមានតម្លៃទីផ្សារខ្ពស់ ។ ប្រជាជននៅក្នុងឃុំថ្មសភាគច្រើនមានជីវភាពរស់នៅ



ពឹងផ្អែកលើធនធានជលផល ជាក់ស្តែងមានប្រជាជនប្រមាណ ៦០ ភាគរយ ប្រកបមុខរបរធ្វើនេសាទជាមុខរបរសំខាន់ទី១របស់ខ្លួន ។ ក្នុងអំឡុងឆ្នាំ ១៩៧៩ដល់ឆ្នាំ ១៩៩៧ ប្រជានេសាទភាគច្រើនប្រើប្រាស់ឧបករណ៍ជាលក្ខណៈគ្រួសារប៉ុណ្ណោះ ដើម្បីផ្គត់ផ្គង់ជីវភាពរស់នៅក្នុងក្រុមគ្រួសារ ប៉ុន្តែក្រោយឆ្នាំ១៩៩៨ បន្តមកដល់សព្វថ្ងៃនេះ ប្រជានេសាទភាគច្រើនបានផ្លាស់ប្តូរពីការប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារមកប្រើប្រាស់ឧបករណ៍នេសាទ ដែលមានលក្ខណៈបច្ចេកទេសទំនើប ដែលចម្លងមកពីប្រទេសថៃឡង់ដ៍ និងប្រទេសវៀតណាម ហើយឧបករណ៍ទាំងនោះត្រូវបានចាត់ទុកជាឧបករណ៍ល្មើសច្បាប់ ដូចជាឈីបយន្ត (ឌុន) និងអួនអូសប្រើដោយកំលាំងម៉ាស៊ីនដែលប្រើប្រាស់នៅតំបន់ទឹករាក់ជាង ២០ម៉ែត្រ ជាដើម ដែលជាហេតុធ្វើឱ្យកើតមានទំនាស់រវាងអ្នកនេសាទតូចតាចជាមួយអ្នកនេសាទដែលប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់ទាំងនោះ និងធ្វើឱ្យធនធានជលផលប្រឈមនឹងការវិនាសហិនហោចនាពេលអនាគត ។

ដោយមើលឃើញនូវបញ្ហាដែលកើតមានទាំងនេះនិងមានសំណូមពរពីប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានទើបការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៃរដ្ឋបាលជលផល ក្រោមការជួយឧបត្ថម្ភថវិកាពីមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍន៍អន្តរជាតិកាណាដា (IDRC )បានសហការជាមួយការិយាល័យជលផលខេត្តកោះកុង និងមានការចូលរួមពីបណ្តាស្ថាប័នពាក់ព័ន្ធចុះធ្វើការសម្របសម្រួលបង្កើតសហគមន៍នេសាទតំបន់ឆ្នេរឃុំថ្មសនាថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០០៥ ។ ការបង្កើតសហគមន៍នេសាទនៅក្នុងឃុំថ្មស គឺចាប់ផ្តើមឡើងដោយការបង្កើតសហគមន៍នេសាទនៅក្នុងភូមិ១របស់ឃុំ ប៉ុន្តែដើម្បីឱ្យការគ្រប់គ្រងធនធានជលផលនៅក្នុងតំបន់ឃុំថ្មសមានប្រសិទ្ធភាពទាមការចូលរួមពីបណ្តាភូមិចំនួន៤ទៀតនៅក្នុងឃុំ ។ ដូច្នេះទើបការងារបង្កើតសហគមន៍នេះបន្តធ្វើនៅក្នុងភូមិទាំង ៤ នោះ ហើយបានបញ្ចប់ នៅថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៥។

ការបង្កើតសហគមន៍នេសាទ គឺជាវិធីសាស្ត្រគ្រប់ គ្រងធនធានជលផលដ៏ល្អប្រសើរដែលស្របទៅនឹងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល ហើយអាចដោះស្រាយបាន នូវបញ្ហាដែលកើតមានឡើងនៅក្នុងមូលដ្ឋាន ដូចជាទំនាស់រវាងអ្នកនេសាទនិងអ្នកនេសាទ បទល្មើសនេសាទនិងការប្រើប្រាស់ ធនធានជលផលហួសកំរិតជាដើម ។

សហគមន៍នេសាទឃុំថ្មសត្រូវបានបង្កើតឡើងដោយមានភូមិចំនួន៥ចូលរួមចងក្រងគ្នាជាសហព័ន្ធមួយ។ រីឯលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ គឺទើបតែរៀបចំនិងមានការទទួលស្គាល់បណ្តោះអាសន្ននៅថ្នាក់ខេត្តកាលពីថ្មីៗនេះតែប៉ុណ្ណោះ ហើយពុំទាន់មានផែនការគ្រប់គ្រងនៅឡើយ ដូច្នេះដំណើរការរបស់សហគមន៍ពុំទាន់ភាពរលូតនៅឡើយទេ ក្នុងនោះបញ្ហាបទល្មើសនេសាទនៅតែកើតមានក្នុងកន្លែងនេសាទសហគមន៍ដែលបង្ករឡើងដោយអ្នកនេសាទល្មើសច្បាប់នៅក្នុងឃុំពុំព្រមចូលរួមជាសមាជិកសហគមន៍នេសាទ ។



ភូមិថ្មស

(ថតរូបភាពដោយ ក្រុមភូមិថ្មស, ២០០៦)



## រូបភាពទី៣៖ ផែនទីសហគមន៍នេសាទឃុំថ្មស





ករណីសិក្សាអំពីសកម្មភាពនេសាទខុសច្បាប់ក្នុងសហគមន៍នេសាទតំបន់ឆ្នេរឃុំថ្មស ត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីចងក្រងជាឯកសារដែលបញ្ជាក់អំពីការជះឥទ្ធិពលនៃការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់លើធនធានជលផល និងលើជីវភាពរស់នៅរបស់ប្រជាជននៅក្នុងឃុំថ្មស ព្រមទាំងផ្តល់ជាអនុសាសន៍ក្នុងការដោះស្រាយបញ្ហាឱ្យចំគោលដៅចំពោះការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់នៅក្នុងឃុំថ្មស ។

ប្រភពព័ត៌មានដែលប្រើសម្រាប់ករណីសិក្សានេះរួមមានព័ត៌មានដែលមានស្រាប់ដូចជារបាយការណ៍អត្ថបទផ្សព្វផ្សាយស្ថិតិនិងឯកសារផ្សេងៗទៀតដែលទទួលបានពីការិយាល័យជលផលខេត្តកោះកុងនិងក្រុមប្រឹក្សាឃុំថស និងព័ត៌មានដែលប្រមូលពីមូលដ្ឋានផ្ទាល់តាមរយៈការសំភាសន៍ជាមួយប្រជានេសាទដែលប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់រួមមាន: អ្នកនេសាទប្រើឧបករណ៍ឈិបយន្ត (ឌុន) និងអួនអូសដោយម៉ាស៊ីនទឹករាក់ជាង ២០ម៉ែត្រ ព្រមទាំងជាមួយអ្នកប្រមូលទិញផលនេសាទ និងមន្ត្រីសង្កាត់នេសាទ ដោយប្រើបញ្ជីសំណួរ និងធ្វើការអង្កេតដោយផ្ទាល់អំពីស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋនៅក្នុង សហគមន៍នេសាទឃុំថ្មស ។

ករណីសិក្សានេះ គឺផ្តោតទៅលើតែឧបករណ៍នេសាទល្មើសច្បាប់ចំនួនពីរប្រភេទ គឺឧបករណ៍នេសាទឈិបយន្ត (ឌុន) និងអួនអូសដោយប្រើម៉ាស៊ីនទឹករាក់ជាង២០ម៉ែត្រពីព្រោះឧបករណ៍នេសាទទាំង២នេះមានការនិយមចូលចិត្តប្រើជាទូទៅពីសំណាក់អ្នកនេសាទល្មើសច្បាប់នៅក្នុងឃុំថ្មស និងនៅតំបន់ឆ្នេរសមុទ្រផ្សេងៗទៀត ។លើសពីនេះទៅទៀត ការសិក្សានេះ គឺផ្តោតទៅលើតែអ្នកនេសាទល្មើសច្បាប់នៅតែក្នុងសហគមន៍នេសាទឃុំថ្មសប៉ុណ្ណោះ ពីព្រោះមិនអាចប្រមូលបានព័ត៌មានអំពីអ្នកនេសាទមកពីក្រៅតំបន់ថ្មសទេ ។ ដូច្នេះករណីសិក្សានេះជាជំហានទី ១ សម្រាប់ជាមូលដ្ឋានក្នុងការសិក្សាស្រាវជ្រាវបន្ត ដើម្បីស្វែងយល់ឱ្យបានស៊ីជម្រៅអំពីការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់នៅក្នុងតំបន់ឆ្នេរឃុំថ្មស ។

**ឈិបយន្ត "រុញដោយម៉ាស៊ីន" (ឌុន)**ជាឧបករណ៍នេសាទសមុទ្រដែលធ្វើពីសាច់មងក្រឡា០.៦០សមឬ ស្បៃម៉ុងនីឡុងរាងដូចសាជីនិងដូចឧបករណ៍ជនទឹកសាបមានចំពាស់ឈើពីរដើមប្រវែងពី ១៥ ម-១៧ម ភ្ជាប់ដោយទ្រនាប់ជ័ររាងដូចស្នូកស្បែកជើងស្ថិតនៅខាងចុងឈើ ហើយភ្ជាប់នឹងទូកយន្តដែលមានកំលាំងម៉ាស៊ីនពី១៥-២៤សេះគេប្រើប្រាស់សំរាប់ចាប់បង្គាឬត្រីតូចៗគ្រប់ប្រភេទនៅតំបន់ឆ្នេរសមុទ្រ (ជម្រៅទឹកតិចជាង ២០ ម៉ែត្រ) ដែលច្បាប់ត្រូវបានហាមឃាត់ ។

**អួនអូស :** ជាឧបករណ៍នេសាទសមុទ្រ ធ្វើពីសាច់មងក្រឡា ១,៥០សម ដល់ ៥សម អូសទាញដោយទូកយន្តមានកំលាំងម៉ាស៊ីនចាប់ពី៣៣សេះឡើង មានរាងប្រហាក់ប្រហែលនឹងដាយចាប់ត្រីទឹកសាបមានខ្សែព្ររនងលើក្រោមអង្កត់ផ្ចិតទំហំ ១០ មម.កំសួលសំណ ក្តារតាខេ នឹងខ្សែកាប អង្កត់ផ្ចិត ទំហំ ១០ មម.ភ្ជាប់ពីអួនទៅទូកយន្តដោយប្រើសម្រាប់ចាប់ត្រីនិងបង្គាគ្រប់ប្រភេទ ។



# ២. ហេដ្ឋារចនាសម្ព័ន្ធ

## ២.១. លំនៅស្ថាន

ជាទូទៅការសង់លំនៅដ្ឋាននៅក្នុងភូមិនីមួយៗ មានលក្ខណៈជាប់ៗគ្នាពីផ្ទះមួយទៅផ្ទះមួយដោយដំបូលប្រក់ស្បូវ ប្រក់ក្បឿង ប្រក់ហ្វីប្រូស៊ីម៉ងត៍ និងប្រក់សង្កសី ប៉ុន្តែភាគច្រើនផ្ទះសាងសង់ដោយប្រក់ហ្វីប្រូស៊ីម៉ងត៍ និងប្រក់ស័ង្កសីមានប្រមាណ ១.១០៥ផ្ទះ នៅក្នុងភូមិថ្មស ហើយមានជីវភាពល្អប្រសើរជាងបណ្តាភូមិផ្សេងៗទៀត ។ ប្រក់ក្បឿង ប្រក់ហ្វីប្រូស៊ីម៉ងត៍ និងប្រក់សង្កសី ប៉ុន្តែភាគច្រើនផ្ទះសាងសង់ដោយប្រក់ហ្វីប្រូស៊ីម៉ងត៍ និងប្រក់ស័ង្កសីមានប្រមាណ ១.១០៥ ផ្ទះ នៅក្នុងភូមិថ្មសហើយមានជីវភាពល្អប្រសើរជាងបណ្តាភូមិផ្សេងៗទៀត ។

## ២.២. ប្រព័ន្ធផ្លូវគមនាគមន៍

បណ្តាញផ្លូវគោកក្នុងឃុំថ្មសទាំងមូលគឺពុំទាន់មានការរៀបរយឱ្យបានល្អនៅឡើយទេការធ្វើដំណើរពីភូមមួយទៅភូមិមួយ គឺមានការលំបាកនិងចំណាយពេលវេលាច្រើន ។ ប្រភេទផ្លូវដែលភ្ជាប់ពីភូមិមួយទៅភូមិមួយទៀត គឺជាប្រភេទផ្លូវលំផ្លូវជើងតាមច្រកព្រៃ និងតាមជម្រេលជើងភ្នំ ។ ការធ្វើដំណើរដោយម៉ូតូក៏មានការលំបាក និងត្រូវចំណាយអស់ថវិកាច្រើន ពីព្រោះមិនអាចជិះបានលឿននិងងាយស្រួលឡើយ ។ ក្រៅពី ផ្លូវគោកប្រជាពលរដ្ឋនៅក្នុងឃុំថ្មសអាចធ្វើដំណើរឆ្លងពីភូមិមួយទៅភូមិទៀតតាមផ្លូវទឹក ប៉ុន្តែគេត្រូវប្រើប្រាស់មធ្យោបាយដោយខ្លួនឯង ពីព្រោះពុំមានទូកដរសម្រាប់ដឹកអ្នកដំណើរនៅក្នុងឃុំឡើយ ។



បណ្តាញផ្លូវគោកដែលឆ្លងកាត់ឃុំថ្មសទៅកាន់ភូមិផ្សេងទៀតស្ថិតក្នុងការអភិវឌ្ឍន៍

(ថតរូបភាពដោយ ក្រុមឃុំថ្មស, ២០០៦)

ចំណែកការធ្វើចរាចរពីឃុំថ្មសទៅទីរួមខេត្តកោះកុង អាចប្រព្រឹត្តទៅបានតាមផ្លូវគោក ដោយភ្ជាប់ពីឃុំទៅផ្លូវជាតិលេខ៤៨ដោយឆ្លងកាត់ច្រកតូចៗ ដែលអាចធ្វើដំណើរបានតែទោចក្រយានយន្តប៉ុណ្ណោះ ។ ប្រជាជនអាចធ្វើដំណើរចេញចូលឃុំថ្មសទៅក្រុងព្រះសីហនុ ឬទីរួមខេត្តកោះកុងបានតាមផ្លូវទឹកដែលមានទូកកាណូតលឿនដែលដឹកអ្នកដំណើរឡើងចុះពីក្រុងព្រះសហីនុទៅទីរួមខេត្តកោះកុង ។



## ២.៣. ការសិក្សាអប់រំ

ទូទាំងឃុំថ្មសមានសាលាបឋមសិក្សាចំនួន ០៧ កន្លែង អាចឱ្យសិស្សចូលរៀនបានប្រមាណ ១.៨៣៥ នាក់ និងសាលាអនុវិទ្យាល័យមានមួយកន្លែងមានទីតាំងស្ថិតនៅក្នុងភូមិថ្មសមានសិស្សកំពុងសិក្សាប្រមាណ២២១នាក់ ។ អត្រាអ្នកមិនចេះអក្សរដោយគិតពីអាយុ១៥ឆ្នាំឡើងទៅមានប្រមាណ២៣,៥០ភាគរយដែលភាគច្រើនជាស្ត្រីប្រមាណ១២,១៣ភាគរយ (ស្ថិតិក្រុមប្រឹក្សាឃុំ ២០០៦) ។

## ២.៤. មណ្ឌលសុខភាព

ដោយសារមណ្ឌលសុខភាពមានតែមួយកន្លែងក្នុងចំណោមភូមិទាំងប្រាំ(០៥) ហើយពុំមានសំភារៈបរិក្ខាថ្នាំពេទ្យសម្រាប់ប្រើប្រាស់គ្រប់គ្រាន់ធ្វើឱ្យប្រជាជនជួបការលំបាក និងបញ្ជូនអ្នកជម្ងឺមកព្យាបាលនៅក្រុងព្រះសីហនុ ឬក្រុងភ្នំពេញពេលសមាជិកគ្រួសារមានជម្ងឺ ។ ប៉ុន្តែទោះជាយ៉ាងណាក៏ដោយ ក៏មានមន្ត្រីពេទ្យជំនាញឆ្មប និងអ្នកដែលមានឆ្មប និងអ្នកមាន ប៉ុន្តែទោះជាយ៉ាងណាក៏ដោយក៏មានមន្ត្រីពេទ្យជំនាញឆ្មប និងអ្នកដែលមានជំនាញក្នុងការជួយសម្រាលទារកតាមលក្ខណៈជំនាញក្នុងការជួយសម្រាលទារកតាមលក្ខណៈបុរាណ និងសម័យផងដែរ ។ ការសំរាលទារកក្នុងមួយឆ្នាំមានចំនួន ១៩២ នាក់ ក្នុងនោះសំរាលកូនដោយគ្រូពេទ្យឆ្មបបុរាណមានចំនួនប្រមាណ ៨៦ នាក់ និងសំរាលកូនដោយគ្រូពេទ្យឆ្មបចំនួន ១០៦ នាក់ (ស្ថិតិក្រុមប្រឹក្សាឃុំ, ២០០៦) ។ កន្លងមកនៅតាមបណ្តាភូមិនីមួយៗក៏មានការជួយគាំទ្រពីអង្គការ CARE ក្នុងការជួយអប់រំផ្សព្វផ្សាយអំពីសុខភាពបន្តពូជ និងកាមរោគផងដែរ ។

# ៣. ស្ថានភាពធនធានជលផល និងផលនេសាទ

ធនធានជលផលនៅតំបន់ឆ្នេរសមុទ្រឃុំថ្មសមានភាពសំបូរបែប ដូចជាត្រី បង្គា ក្តាម មឹក គ្រែងឈាមជាដើមសរុបប្រមាណ ៣៧ ប្រភេទ ។ កន្លងមកថ្មីៗនេះ ដោយសារអ្នកនេសាទប្រមាណ ៧០-៨០% ប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ដូចជាអួនអូស (អូសជម្រៅទឹកក្រោម២០ម៉ែត្រ) ឈីបយន្ត(ឌុន) និងការប្រើសំណាញ់ក្រឡាតូចជាង ១.៥០សម បណ្តាលឱ្យប៉ះពាល់ដល់ប្រភេទត្រីមួយចំនួន និងក្តាម ខ្យង

" អណ្តើកសមុទ្រ ត្រីឆ្លាម ក្រពើ និងពស់ត្រូវបានផុតពូជពីតំបន់នេសាទឃុំថ្មស"

ក្រុមស្រាវជ្រាវដោយមន្ត្រីអភិវឌ្ឍន៍សហគមន៍នេសាទ ឆ្នាំ ២០០៥



គ្រែង ។ល។ មានការវិនាសហិនហោច និងឈានទៅជិតផុតពូជ (របាយការណ៍គម្រោងនៅឃុំថ្មសឆ្នាំ ២០០៥) ។

ផលនេសាទចាប់បានដូចជាបង្កា ត្រី និងក្តាមមានការថយ ចុះគួរឱ្យកត់សំគាល់ ។ ការថយចុះនៃផលចាប់នេះ គឺបណ្តាលមកពី កត្តាមនុស្ស និងកត្តាធម្មជាតិ ។ ការកើតមាននូវបទល្មើសនេសាទជាដើម ។ល។ ផ្អែកតាមការសំភាសន៍ជាមួយអ្នកនេសាទនៅក្នុងឃុំថ្មស ឃើញថាផលនេសាទមានការថយចុះ ជាពិសេសក្នុងរយៈកាលប៉ុន្មានឆ្នាំចុងក្រោយនេះ ។ ការថយចុះនៃផលនេសាទចាប់បាននេះ គឺស្របគ្នានឹងស្ថិតិរបស់ការិយាល័យជលផលខេត្តកោះកុងនៅក្នុងឆ្នាំ២០០៣ ផលនេសាទសមុទ្រចាប់បានសរុបទូទាំងខេត្តចំនួន ៣៩៨៨តោន ក្នុងនោះបង្កាប្រមាណ ៧០៩តោន ក្តាមប្រមាណ១,៨៤៧តោន និងត្រីប្រមាណ១,៤៣២តោន ប៉ុន្តែផលនេសាទចាប់បាននៅក្នុងឆ្នាំ២០០៥ មានការធ្លាក់ចុះមកត្រឹម១៧៨៤តោន ក្នុងនោះ បង្កា៧៤១តោន ក្តាម ៤៩៧តោន និងត្រី ៥៤៦តោនប៉ុណ្ណោះ ។

" ខ្ញុំមិនអាចចាប់ផលនេសាទឆ្លើយតបនឹងសេចក្តីត្រូវការរបស់គ្រួសារខ្ញុំបានទេ ប្រសិនបើខ្ញុំប្រើឧបករណ៍នេសាទស្របច្បាប់ព្រោះចាប់ផលនេសាទបានតិច ដូច្នេះខ្ញុំត្រូវតែបង្ខំចិត្តប្រើឧបករណ៍នេសាទខុសច្បាប់ ព្រោះខ្ញុំអាចចាប់ផលនេសាទបានច្រើន"

ប្រជានេសាទភូមិថ្មស ថ្ងៃទី ៣០ ខែ មេសា ឆ្នាំ ២០០៦ .

ស្របគ្នានេះដែរអ្នកនេសាទនៅក្នុងឃុំថ្មសក៏បានរាយការណ៍អំពីការធ្លាក់ចុះនៃផលនេសាទនៅក្នុងឃុំរបស់ខ្លួនផងដែរ ដោយបានអះអាងថាបច្ចុប្បន្ននេះ ការប្រើឧបករណ៍នេសាទសាមញ្ញមិនអាចចាប់ត្រីបានគ្រប់គ្រាន់សម្រាប់ចិញ្ចឹមគ្រួសារឡើយ ដូច្នេះបានជាអ្នកនេសាទប្រើប្រាស់ឧបករណ៍កាន់តែទំនើប។ថែមទៀត និងបទល្មើសក៏កាន់តែកើនឡើង ។

# ៤. កត្តាដែលបណ្តាលឱ្យធនធានជលផលថយចុះ

## ៤.១. ការផ្លាស់ប្តូរបច្ចេកទេសក្នុងការនេសាទ

លទ្ធផលនៃការសម្ភាសន៍ជាមួយប្រជានេសាទក្នុងភូមិថ្មស ភូមិចំការលើ ភូមិស្រែថ្មី ភូមិស្រែត្រាវបានអោយដឹងថាក្នុងអំឡុងទសវត្សឆ្នាំ៨០ ប្រជានេសាទភាគច្រើនគឺប្រើឧបករណ៍នេសាទស្របច្បាប់ដូចជាមងបង្កា មងក្តាម សន្ទូច រនងថ្មងគី និងទូកបបែលគ្មានទុយជាដើម ។ ប៉ុន្តែបន្ទាប់មកដោយសារប្រជានេសាទមានការកើនឡើង និងតម្រូវការក្នុងគ្រួសារខ្ពស់ ប្រជានេសាទបានផ្លាស់ប្តូរមកប្រើឧបករណ៍នេសាទខុសច្បាប់ដូចជាឈិបយន្ត (ឌុន) អួនអូសក្រោមជម្រៅទឹក២០ម៉ែត្រ ព្រោះថាឧបករណ៍នេសាទទាំងនេះអាចចាប់ផលនេសាទបានច្រើនគ្រប់ប្រភេទហើយត្រូវការកំលាំងពលកម្មតិចពោលគឺមនុស្សម្នាក់ក៏អាចធ្វើការនេសាទបានដែរ និងម្យ៉ាងទៀតឧបករណ៍នេសាទទាំងនេះមានប្រសិទ្ធភាពល្អ និងមានតម្លៃសមរម្យបើប្រៀប

ផ្សេបជាមួយ ឧបករណ៍នេសាទផ្សេងៗទៀត ។

ការប្រើប្រាស់ឧបករណ៍នេសាទទាំង ២ប្រភេទនេះ គឺបណ្តាលឱ្យប៉ះពាល់ និងបំផ្លិចបំផ្លាញដល់ធនធានជលផល និងខូចខាតដល់មជ្ឈដ្ឋានរស់នៅរបស់មច្ឆជាតិក្នុងការពងកូនបង្កកំណើតការរីកធំធាត់ ។

## ៤.២. កំណើនប្រជាជន

ដោយសារភាពសម្បូណ៌បែបនៃធនធានជលផលនៅតំបន់ឆ្នេរថ្មសបានធ្វើអោយប្រជាជនមកពីបណ្តាស្រុកនានា និងបណ្តាខេត្តផ្សេងទៀតបានផ្លាស់ប្តូរទីលំនៅទៅរស់នៅក្នុងទឹកដីឃុំថ្មសដើម្បីប្រកបមុខរបរចិញ្ចឹមជីវិតដោយការធ្វើនេសាទ ។ ដែលជាហេតុធ្វើឱ្យកំណើនប្រជាជនមានការកើនឡើងជាលំដាប់ដែលរហូតមកដល់ឆ្នាំ២០០៦នេះ នៅក្នុងឃុំថ្មសមានប្រជាជនប្រមាណ ១៧៥៤គ្រួសារ និងមានអត្រាកំណើនប្រជាជនប្រមាណ២ភាគរយក្នុងមួយឆ្នាំ (ស្ថិតិ ឃុំ ២០០៦) ។ ដោយសារកំណើនប្រជាជននៅក្នុងតំបន់ឆ្នេរឃុំថ្មសមានការ កើនឡើងជាហេតុបណ្តាលឱ្យបង្កើនទូវសម្ពាធទៅលើធនធានជលផលកាន់តែខ្លាំង បញ្ហានេះបានធ្វើឱ្យប៉ះពាល់ដល់ធនធានជលផលយ៉ាងខ្លាំងនៅក្នុងតំបន់ ។



អ្នកភូមិកំពុងប្រមូលឈាមខ្ចងក្រែងយកទៅលក់អោយឈ្មួញកណ្តាលនៅក្នុងឃុំ
(ថតរូបភាពដោយ ក្រុមថ្មស, ២០០៦)

## ៤.៣. តម្រូវការក្នុងគ្រួសារ បង្កើនផលចាប់ និង ប្រាក់ចំណូល

តាមតម្រូវការរបស់មនុស្សត្រូវមានទីជម្រកគ្រប់គ្រាន់ (ផ្ទះសំបែង) និងត្រូវការសម្ភារៈដ៏ច្រើនដើម្បីបំរើការរបស់ខ្លួន និងថែមទាំងបំរើអារម្មណ៍ថែមទៀត ដូចជា ទូរទស្សន៍ ម៉ាញ៉េ ទូរស័ព្ទ និងសម្ភារៈផ្សេងទៀតបានធ្វើឱ្យមនុស្សគ្រប់រូបប្រឹងប្រែងស្វែងរកប្រាក់ចំណូលតាមគ្រប់រូបភាព។ ដូចគ្នានេះដែរ ប្រជាជននៅឃុំថ្មសដែលភាគច្រើនមានមុខរបរនេសាទបាននិយាយថា:

”ដោយសារភាពសម្បូរបែបនៃសម័យកាលបច្ចុប្បន្ន និងតម្រូវការរបស់គ្រួសារខ្ញុំបានប្តូរមកនេសាទដោយប្រើឧបករណ៍នេសាទឈិបយន្ត និងអួនអួសព្រោះថាឧបករណ៍នេសាទទាំងពីរនេះអាចឱ្យខ្ញុំចាប់ផលនេសាទបានច្រើន និងគ្រប់ប្រភេទ ព្រមទាំងអាចរកប្រាក់ចំណូលផ្គត់ផ្គង់គ្រួសារទៀតផង ” ។

អ្នកនេសាទភូមិថ្មសថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៦



រកមធ្យោបាយធ្វើនេសាទតាមគ្រប់រូបភាព ដោយខិតខំកែច្នៃពីឧបករណ៍នេសាទស្របច្បាប់មកប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ដូចជា ឈិបយន្ត (ឌុន) និងអួនអូសក្រោមជម្រៅទឹក២០ម៉ែត្រ (ធ្វើនេសាទនៅទឹករាក់ៗ) អាចចាប់ផលនេសាទបានច្រើនរកបានប្រាក់ចំណូលខ្ពស់ ។

តាមការចុះសំភាសន៏ដោយផ្ទាល់ជាមួយប្រជានេសាទឃុំថ្មសដែលបានធ្វើឡើងនៅថ្ងៃទី ២៨-២៩ ខែមេសា ឆ្នាំ ២០០៦ ជាពិសេសប្រជានេសាទនៅភូមិថ្មស និងភូមិចំការលើភាគច្រើនប្រកបមុខរបរនេសាទដោយប្រើឧបករណ៍ល្មើសច្បាប់ដូចជា ឈិបយន្ត (ឌុន) និងអួនអូសនៅតំបន់ទឹករាក់ ដោយសារការល្បាតរបស់អាជ្ញាធរមានសមត្ថកិច្ចមិនសូវមានប្រសិទ្ធភាព និងមិនមានតម្លាភាពក្នុងការអនុវត្តច្បាប់ ។

"ប្រជាជនភាគច្រើន គឺជាអ្នកនេសាទខុសច្បាប់ ដោយហេតុថាអាជ្ញាធរពុំបានអនុវត្តច្បាប់អោយបានពេញលេញ ដោយសារមានការឃុមឃិតពីសំនាក់មនុស្សដែលមានអំណាច ហើយការអនុវត្តច្បាប់នៅខ្វះតម្លាភាពម្យ៉ាងវិញទៀត "

ជាទូទៅប្រជានេសាទនៅតំបន់ឆ្នេរច្រើនតែ ចេញទៅនេសាទនៅពេលយប់ ដែលជាកត្តាមួយសមស្រប និងអំណោយផលក្នុងការនេសាទល្មើសច្បាប់ ព្រោះថាអាជ្ញាធរដែនដី និងសម្ថកិច្ចជលផលពុំមានសំភារៈ និងមធ្យោបាយគ្រប់គ្រាន់ក្នុងការទប់ស្កាត់បទល្មើសឱ្យបានទាន់ពេលវេលា និងម្យ៉ាងទៀតការសហការជាមួយស្ថាប័នពាក់ព័ន្ធនៅមានកំរិតនិងមានការរាយការណ៍ជាមុនទៅដល់ជនល្មើសពេលដែលកំលាំងអាជ្ញាធរជលផលចុះបង្ក្រាបសកម្មភាពល្មើសនេសាទ ។

"មូលហេតុអ្នកនេសាទនៅភូមិ ថ្មស និងនៅចំការលើកើនឡើងនូវការប្រើប្រាស់ឧបករណ៍នេសាទល្មើសច្បាប់នៅឃុំថ្មស ដោយសារច្បាប់ជលផលចាស់មិនសមស្របតាមសភាពការណ៍បច្ចុប្បន្នមធ្យោបាយបង្ក្រាបបទល្មើសនេសាទមានសភាពចាស់ទ្រុឌទ្រោមខ្វះថវិការសំរាប់ផ្គត់ផ្គង់ពេលចេញបង្ក្រាបបទល្មើសនេសាទ មន្ត្រីជលផលមានចំនួនតិច ហើយដែននេសាទមានទំហំធំ និងកិច្ចសហការជាមួយសមត្ថកិច្ចពាក់ព័ន្ធនៅមានកំរិត"

មន្ត្រីសង្កាត់នេសាទបូទុមសាគរ ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០០៦

## ៤.៤. ការជះឥទ្ធិពលនៃការប្រើប្រាស់ឧបករណ៍ខុសច្បាប់លើធនធានជលផល

ការប្រើប្រាស់ឧបករណ៍នេសាទកាន់តែទំនើប និងទាន់សម័យនៅដែននេសាទហាមឃាត់បានធ្វើឱ្យមានការប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ធនធានជលផល ព្រោះថាឧបករណ៍នេសាទទាំងនេះបានបំផ្លាញធនធានជលផលទាំងតូចទាំងធំ និងប្រព័ន្ធអេកូ

ឡូស៊ី ។ យ៉ាងណាមិញដូចជា ការប្រើប្រាស់ឧបករណ៍នេសាទ ឈិបយន្ត (ឌុន) និងអួនអូសក្រោមជម្រៅទឹក២០ម៉ែត្រ នៅតំបន់ឆ្នេរសមុទ្រថ្មសបានធ្វើឱ្យធនធានជលផលថយចុះ និងប្រភេទធនធានជលផលមួយចំនួនត្រូវបានបាត់បង់ និង មិនហ៊ានមករស់នៅតំបន់នេះដោយសារខូចប្រព័ន្ធអេកូឡូស៊ី និងជម្រក ហើយជាមូលហេតុបង្កឱ្យមានទំនាស់រវាង

"ខ្ញុំគិតថា ក្រោយពីប្រជានេសាទបានប្រើឧបករណ៍នេសាទឈិបយន្ត និងអួនអូសមកបានធ្វើឱ្យធនធានជលផលមួយចំនួនបាត់បង់ និងមិនហ៊ានរស់នៅក្នុងតំបន់នោះដូចជា ត្រីឆ្លាមទឹកជ្រៅ ត្រីថុ ត្រីត្រសក់ ត្រីណាន់ និងត្រីប្រា "

លោក ថៃ យៀង ថ្ងៃទី ៣០ ខែមេសា ឆ្នាំ២០០៦

អ្នកនេសាទប្រើប្រាស់ឧបករណ៍ខុសច្បាប់ជាមួយអ្នកនេសាទ ប្រើប្រាស់ឧបករណ៍ស្របច្បាប់ទៀតផង ។ លើសពីនេះទៅទៀត អ្នកនេសាទល្មើសច្បាប់នៅក្នុងឃុំថ្មសមិនចាប់អារម្មណ៍ថា សកម្មភាពរបស់ខ្លួនមិនធ្វើឱ្យប៉ះពាល់ដល់ការវិនាសហិនហោចដល់ធនធានជលផលឡើយ ។

## ៤.៥. តម្រូវការទីផ្សារ

តម្រូវការទីផ្សារ គឺជាកត្តាមួយយ៉ាងសំខាន់ក្នុងការជម្រុញឱ្យប្រជានេសាទបង្កើនការនេសាទ និងការប្រើប្រាស់ឧបករណ៍នេសាទកាន់តែទំនើប ព្រោះថាឧបករណ៍នេសាទទាំងនេះអាចចាប់បានត្រីគ្រប់ប្រភេទ និងអាចឆ្លើយតបនឹងតម្រូវការក្នុងស្រុក និងក្រៅស្រុក ។ ដើម្បីសម្រួលដល់ការធ្វើចរាចរផលនេសាទទាំងនេះ ឈ្មួញកណ្តាលបានបង្កើតស្នាក់ការប្រមូលទិញផលនេសាទនៅមូលដ្ឋាន ដែលជាទំនុកចិត្តដល់ប្រជា នេសាទ ។ មានស្នាក់ការប្រមូលទិញផលនេសាទចំនួន ៧ កន្លែង នៅក្នុងឃុំថ្មស ។

ផលនេសាទ ដែលឈ្មួញប្រមូលទិញពីប្រជានេសាទ ត្រូវបាននាំចេញទៅលក់នៅក្រុងព្រះសីហនុ ក្រុងភ្នំពេញ និងប្រទេសថៃ ។ ឈ្មួញប្រមូលទិញផលនេសាទនៅក្នុងថ្មសបានផ្តល់ប្រាក់កម្ចីទៅឱ្យអ្នកនេសាទ ហើយតម្រូវឱ្យអ្នកនេសាទលក់ផលនេសាទដែលចាប់បានទៅឱ្យម្ចាស់លុយវិញ ។ ប្រជានេសាទមានការត្អូញត្អែរ

"ផលនេសាទរបស់ខ្ញុំត្រូវបានប្រមូលទិញទាំងអស់ដោយឈ្មួញកណ្តាលនៅក្នុងភូមិដោយពុំចាំបាច់យកទៅលក់នៅទីផ្សារកន្លែងផ្សេងៗឡើយ "

លោក ហ៊ី ប្រជានេសាទភូមិចំការលើ
ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៦


ពួកឈ្មួញកណ្តាលទិញកម្ពឹសពីអ្នកភូមិ
(ថតរូបភាពដោយ ក្រុមថ្មស, ២០០៦)



ថា ពួកគាត់មិនអាចតវ៉ាចំពោះថ្លៃត្រី ដែលខ្លួនលក់ឱ្យឈ្មួញដែលជាម្ចាស់លុយឡើយ ទោះបីជាថ្លៃត្រីដែលលក់ទាបជាងថ្លៃទីផ្សារក៏ដោយ ។ ពាក់ព័ន្ធនឹងតម្រូវការ ទីផ្សារនេះផងដែរ តាមសេចក្ដីរាយការណ៍របស់ប្រជាពលរដ្ឋបានឱ្យដឹងថា ថ្លៃបង្គាមានការកើនឡើងចាប់ពីប៉ុន្មានឆ្នាំកន្លងមក នេះ ជាក់ស្ដែងនៅក្នុង ២០០៤ បង្គារលេខ ១ ថ្លៃ ១៣.០០០ រៀលក្នុង ១ គីឡូក្រាម លេខ ២ ថ្លៃ ៧.០០០ រៀល និងលេខ ៣ ថ្លៃ ៥.០០០ រៀល ។ ប៉ុន្តែបច្ចុប្បន្ននេះបង្គាលេខ ២ ថ្លៃ ដល់ទៅ ១២.០០០ រៀលក្នុងមួយគីឡូក្រាម ។

ម្យ៉ាងទៀត ទោះបីជាប្រជានេសាទមួយចំនួនមិនបានផ្ដោតទៅលើតម្រូវការទីផ្សារដែលជាកត្តាជំរុញពួកគាត់ក្នុងការបង្កើនការនេសាទក៏ដោយ ក៏ការពិតប្រសិនបើផលនេសាទមិនមានតំលៃលើទីផ្សារ និងមិនមានឈ្មួញទិញនោះទេ ក៏ប្រជានេសាទមិនខិតខំធ្វើនេសាទដែរ ហើយបើមានការនេសាទក៏សម្រាប់តែតម្រូវការក្នុងគ្រួសារតែប៉ុណ្ណោះ ។ ដូចនេះ ទីផ្សារគឺជាកត្តាមួយដែលជះឥទ្ធិពលដល់ការថយចុះនៃធនធានជលផល ព្រោះថាវាបានជម្រុញឱ្យប្រជានេសាទប្រើប្រាស់ឧបករណ៍នេសាទកាន់តែទំនើបដើម្បីចាប់ត្រីឱ្យបានច្រើន ហើយឧបករណ៍នេសាទទាំងនេះបានធ្វើឱ្យប៉ះពាល់ដល់ធនធានជលផល និងខូចប្រព័ន្ធអេកូឡូស៊ីសមុទ្រ ។

## ៥. សន្និដ្ឋាន

ជារួមឃើញថា ធនធានជលផល និងប្រាក់ចំណូលបានមកពីការនេសាទមានការធ្លាក់ចុះដោយសារកំណើនប្រជានេសាទក្នុងតំបន់ និងអ្នកនេសាទប្រើប្រាស់ឧបករណ៍ខុសច្បាប់ដូចជា ឧបករណ៍ឈីបយន្ត (ឌុន) និងអួនអូសនៅក្នុងតំបន់ដែលមានជម្រៅទឹករាក់ជាង ២០ ម៉ែត្រ ជាដើម ដែលសកម្មភាពទាំងនេះមានការរាលដាលពាសពេញក្នុងតំបន់ទាំងនេះ គឺដោយសារប្រជានេសាទពុំបានយល់ពីអត្ថប្រយោជន៍ធនធានជលផល ហើយកិច្ចសហការរវាងស្ថាប័នពាក់ព័ន្ធជំនាញជាមួយអាជ្ញាធរដែនដីក្នុងការបង្ក្រាបបទល្មើសនេសាទ ក៏ពុំទាន់មានប្រសិទ្ធភាពខ្ពស់នៅឡើយ ។ ម្យ៉ាងទៀតកម្រិតផាកពិន័យជនល្មើសផ្អែកតាមច្បាប់ជលផលចាស់មិនស្របតាមស្ថានភាពបច្ចុប្បន្នដែលជាហេតុមិនអាចធ្វើឱ្យជនល្មើសរាងចាល និងបោះបង់ចោលនូវសកម្មភាពល្មើសច្បាប់របស់ខ្លួនឡើយ ។ ចំពោះសមត្ថកិច្ចជលផលក៏ពុំមានលទ្ធភាពគ្រប់គ្រាន់ក្នុងការចុះបង្ក្រាបបទល្មើសដោយមូលហេតុខ្វះថវិកា ខ្វះមធ្យោបាយ និងមន្ត្រីមានចំនួនតិច ។ កត្តាទាំងនេះហើយដែលបណ្ដាលឱ្យបទល្មើសនេសាទរីករាលដាលកាន់តែច្រើនឡើង ។ យើងឃើញថា បទល្មើសនេសាទបានធ្វើឱ្យធនធានជលផលថយចុះ និងបាត់បង់ពូជត្រីមួយចំនួន (តាមប្រសាសន៍របស់ ប្រជានេសាទភូមិថ្មស និងក្នុងភូមិចំការលើ) ដែលមានចំណាប់អារម្មណ៍ថាពូជត្រីមួយចំនួនបានផុតពូជដូចជា ត្រីឆ្លាម ក្រពើ និងពស់។ ផ្អែកតាមទិន្នផលដែលបានកត់ត្រាដោយការិយាល័យជលផលខេត្តកោះកុងក្នុងឆ្នាំ ២០០៣ និង២០០៥ បញ្ជាក់ថា ក្នុងឆ្នាំ ២០០៣ ទិន្នផលបង្គាប្រមាណ ៧០៩ តោន ក្ដាម ប្រមាណ ១,៨៤៧



និងត្រីប្រមាណ ១,៤៣២ តោន តែក្នុងឆ្នាំ ២០០៥ ទិន្នផលបង្គា ៧៤១ តោន ក្តាម ៤៥៧ តោន និងត្រីចាប់បានតែ ៥៤៦ តោនប៉ុណ្ណោះ ។ ដូច្នេះភស្តុតាងដែលធ្វើការបញ្ជាក់បានឆ្លុះបញ្ចាំងឱ្យឃើញថាផលនេសាទសមុទ្រដែលចាប់ពិតជាមានការថយចុះមែន ។

## ៦. អនុសាសន៍

អង្គការក្រៅរដ្ឋាភិបាលនិងរាជរដ្ឋាភិបាលគួរតែជួយបង្កើតមុខរបរដល់ប្រជានេសាទតាមរយៈការផ្តល់ការគាំទ្រខាងផ្នែកបច្ចេកទេស និងថវិកាដើម្បីចូលរួមចំណែកក្នុងការបង្កើតជម្រើសមុខរបរជូនដល់ប្រជាជនរស់នៅក្នុងតំបន់ជាពិសេសផ្តោតទៅលើអ្នកនេសាទ និងអ្នកដែលមានមុខរបរចិញ្ចឹមគ្រែងឈាមក្នុងកន្លែងនេសាទសហគមន៍នៅភូមិចំការលើ ។

គួរមានការបើកវគ្គសិក្សារយៈពេលខ្លីៗឱ្យបានជាញឹកញាប់ដល់គណៈកម្មការសហគមន៍នេសាទ និងស្ថាប័នពាក់ព័ន្ធស្ថាប័នជំនាញជាមួយអាជ្ញាធរដែនដី ដើម្បីស្វែងរកផលប៉ះពាល់ឱ្យបានច្បាស់លាស់ និងដើម្បីស្វែងរកដំណោះស្រាយ ។

គួរតែមានការជួយជម្រុញពាក្យស្នើសុំសិទ្ធិទទួលស្គាល់សហគមន៍នេសាទឃុំថ្មសឱ្យបានឆាប់បំផុត ។

គួរមានការសិក្សាឱ្យបានម៉ត់ចត់អំពីផលប៉ះពាល់នៃការប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ដែលធ្វើឱ្យធនធានជលផលថយចុះ ។

## REFERENCE


- Report Thmor sor commune on 2005-2006
- Report statistics of Koh Kong Provincial Fishery office (2005-2006 )(CFDU /KK )
- Report result of the Scoping activities in Thmor Sor Commune, Botum Sakor District, Koh kong Province.( March 2006 ) ( CFDO / FiA )





# ការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋក្នុង សហគមន៍នេសាទកំពង់ក្រសាំង



# ការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទកំពង់ក្រសាំង

ករណីសិក្សា ឃុំកំពង់ក្រសាំង ស្រុកបូរីជលសា ខេត្តតាកែវ

**ស្រាវជ្រាវ និងចងក្រងដោយ :**

លោក ទិត ភារ: -CFDO / FiA / IDRC

លោក អ៊ូ សុផាន -CFDU / TAKEO

លោកស្រី ចាន់រតនា -CFDO / FiA

លោក ណែម កាណូ -CFDO / FiA

លោក ប៉ែន មករា -CEPA

__សារគន្លឹះ:__ ជីវភាពរបស់ប្រជាជននៅក្នុងសហគមន៍កំពង់ក្រសាំងអាចប្រសើរឡើងដោយមានការជួយឧបត្ថម្ភលើការកសាងសមត្ថភាព និងការផ្តល់ឥណទាន

## ១. សេចក្តីផ្តើម

ខេត្តតាកែវ ជាខេត្តមួយដែលសំបូរទៅដោយប្រឡាយ និង ផ្លូវទឹកខ្វាត់ខ្វែងតភ្ជាប់ពីទីរួមខេត្តទៅតាមបណ្តាភូមិនានារហូតដល់ប្រទេសវៀតណាម ។ តាមប្រវត្តិសាស្ត្រដីយូរលង់មកនៅក្បែរទីរួមស្រុកអង្គរបូរីដែលតភ្ជាប់មកទីរួមខេត្តដោយប្រឡាយទឹកគឺជាចំណុចកណ្តាលនៃនគរហ្វូណនដែលប្រជាជនខ្មែរធ្លាប់បានដឹងថាជាសម័យរុងរឿងរបស់ខ្មែរយើងនៅក្នុងបុរាណកាល ។ ព្រែកជីក និង ប្រព័ន្ធទឹកនៅក្នុងខេត្តតាកែវ បានផ្តល់នូវសារៈសំខាន់ដ៏មានប្រសិទ្ធភាពចំពោះការធ្វើដំណើរ និង ការងារដឹកជញ្ជូនរបស់ប្រជាជនកម្ពុជា និង ប្រជាជននៃប្រទេសវៀតណាមដែលធ្វើដំណើរចេញចូលទំនាក់ទំនងជាមួយកម្ពុជាយើង ។ ព្រែកជីកមេដែលតភ្ជាប់មកទីរួមខេត្តតាកែវ គឺជាផ្លូវទឹកមួយសម្រាប់ការធ្វើដំណើរ និង ដឹកជញ្ជូនទំនិញតាមទូកទៅមកពីព្រំដែនកម្ពុជាវៀតណាម និង ទៅទីកន្លែងផ្សេងទៀតនៅក្នុងខេត្ត (Jacobson & Visakay, 2001) ។

ឃុំកំពង់ក្រសាំងស្ថិតនៅក្នុងស្រុកបូរីជលសាជាប់នឹងព្រំប្រទល់ប្រទេសវៀតណាម ហើយមានទីតាំងស្ថិតនៅទិសអាគ្នេយ៍ និងមានចម្ងាយប្រមាណ ៥០គីឡូម៉ែត្រពីទីរួមខេត្តតាកែវ ។ ឃុំនេះត្រូវបានតភ្ជាប់មកទីរួមខេត្តតាកែវ ដោយស្ទឹង

តាកែវ និង ព្រែកជីកប៉ុលសារឿន ។ ក្នុងតំបន់នេះ គឺសំបូរទៅដោយធនធានធម្មជាតិដូចជា ត្រី សត្វស្លាប ជីវៈចំរុះ និង ព្រៃលិចទឹកជាដើម ។ ឃុំកំពង់ក្រសាំងមានភូមិចំនួន ៥ គឺ ភូមិបូរីជលសា ភូមិកំពង់ក្រសាំង ភូមិក្តុលជ្រុំ ភូមិសង្គមមានជ័យ និង ភូមិថ្មបីដុំ ។ ឃុំកំពង់ក្រសាំងមាន ៧៤៧ គ្រួសារ គិតជាចំនួនមនុស្សសរុបមាន ៣.៧០៩ នាក់ ក្នុងនោះស្រ្តីមានចំនួន ១.៨៧០ នាក់។

នៅក្នុងឃុំកំពង់ក្រសាំងមានសាលាបឋមសិក្សាមួយកន្លែងដែលស្ថិតនៅក្នុងភូមិកំពង់ក្រសាំង និង អនុវិទ្យាល័យមួយកន្លែងដែលស្ថិតនៅក្នុងភូមិក្តុលជ្រុំ ។ អត្រាអ្នកមិនចេះអក្សរមានចំនួន ៤៥% ក្នុងនោះភាគច្រើនជាស្រ្តី ។ ភូមិទាំង ៥ របស់ឃុំ គឺមានទីតាំងស្ថិតនៅតាមដងស្ទឹងព្រែក និង ប្រឡាយ ហើយគ្របដណ្តប់ដោយផ្ទៃទឹកធំល្វឹងល្វើយនៅរដូវវស្សាដែលមានរយៈពេល៦ខែក្នុងមួយឆ្នាំ ។ ដោយសារទីតាំងភូមិសាស្រ្តនៅក្នុងតំបន់នេះត្រូវបានបែងចែកជាពីររដូវកាលខុសគ្នា គឺរយៈពេល ៦ ខែជាដីគោក និង រយៈពេល ៦ ខែទឹកលិច ជាហេតុធ្វើឱ្យប្រជាជនដែលរស់នៅទីនោះប្រកបមុខរបរពីរជាចម្បង គឺការធ្វើនេសាទ និង ការធ្វើស្រែ ។ មានសកម្មភាពនេសាទជាច្រើនដែលបានធ្វើឡើងនៅក្នុងប្រឡាយ និង ស្ទឹងដែលអាចផ្គត់ផ្គង់សេចក្តីត្រូវការប្រចាំថ្ងៃសម្រាប់គ្រួសារបាន ជាពិសេសនៅក្នុងរដូវបើកនេសាទចាប់ពីខែ វិច្ឆិកា ដល់ ខែមីនា ។ ចំណែកសកម្មភាពកសិកម្មវិញ គឺផ្តោតសំខាន់លើការធ្វើស្រែប្រាំងដែលអាចផ្តល់ទិន្នផលខ្ពស់សម្រាប់ផ្គត់ផ្គង់ដល់ជីវភាពរស់នៅរបស់អ្នកភូមិ ហើយមានគ្រួសារមួយចំនួនតូចបានដាំដំណាំរួមផ្សំបន្តិចបន្តួចថែមទៀតសម្រាប់ការហូបចុកប្រចាំថ្ងៃរបស់ខ្លួន ។ ដោយសារឃុំកំពង់ក្រសាំងមានទីតាំងស្ថិតនៅជាប់ព្រំដែនកម្ពុជាវៀតណាម ប្រជាជនភាគច្រើននៅក្នុងឃុំនេះជាជនជាតិកម្ពុជាក្រោមដែលបានផ្លាស់ប្តូរទីលំនៅមកពីប្រទេសវៀតណាម ចូលមករស់នៅក្នុងឃុំកំពង់ក្រសាំង ។ ខ្មែរកម្ពុជាក្រោម គឺជាជនជាតិខ្មែរដែលត្រួតត្រាដោយរដ្ឋាភិបាលវៀតណាមតាំងពីឆ្នាំ ១៩៤៩ ពីព្រោះអាណានិគមន៍បារាំងបានកាត់ទឹកដីខ្មែរឱ្យទៅវៀតណាម ។

សហគមន៏នេសាទកំពង់ក្រសាំង ត្រូវបានបង្កើតឡើងបន្ទាប់ពីមានការកែទម្រង់គោលនយោបាយវិស័យជលផលរបស់រាជរដ្ឋាភិបាលនៅចុងឆ្នាំ២០០០ ។ នៅក្នុងឆ្នាំ២០០១ ការិយាល័យជលផលខេត្តតាកែវបានចាប់ផ្តើមធ្វើការសម្របសម្រួលរៀបចំសហគមន៏នេសាទជាច្រើននៅទូទាំងខេត្តតាកែវ ក្នុងនោះសហគមន៏នេសាទកំពង់ក្រសាំងត្រូវបានរៀបចំឡើងនៅថ្ងៃ ទី ៦ ខែកញ្ញា ឆ្នាំ២០០១ ។ សហគមន៏នេសាទកំពង់ក្រសាំងមានការចូលរួមពីបណ្តាភូមិចំនួន ៣ គឺ ភូមិបូរីជលសា កំពង់ក្រសាំង និង ក្តុលជ្រុំ ។ ភូមិបូរីជលសាមាន ៩៦ គ្រួសារ គិតជាចំនួនមនុស្សមាន ៤៦០ នាក់ ក្នុងនោះស្រ្តីមានចំនួន ២១២ នាក់ ចំណែកភូមិកំពង់ក្រសាំងមាន ៦៨ គ្រួសារគិតជាចំនួនមនុស្សមាន ៣៣៦ នាក់ ក្នុងនោះស្រ្តីមានចំនួន ១៨៥ នាក់ រីឯភូមិក្តុលជ្រុំមាន ២៤០ គ្រួសារ គិតជាចំនួនមនុស្ស មាន ១.១៩១ នាក់ ក្នុងនោះស្រ្តីមានចំនួន ៦០០ នាក់ ។ ដោយមានការខិតខំប្រឹងប្រែងរបស់ផ្នែកអភិវឌ្ឍន៏សហគមន៏នេសាទនៃការិយាល័យជលផលខេត្តតាកែវ ក្នុងការចុះផ្សព្វផ្សាយជាហូរហែរបានធ្វើឱ្យសមាជិកសហគមន៏នេសាទកំពង់ក្រសាំងមានការយល់ដឹងបន្តិចម្តងៗអំពីផលប្រយោជន៏នៃការចូលរួមគ្រប់



គ្រងសហគមន៍នេសាទ ។ ចាប់ពីខែ មិថុនា ឆ្នាំ ២០០៤ មក ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទសហការណ៍ជាមួយការិយាល័យជលផលខេត្តតាកែវ ក្រោមការជួយឧបត្ថម្ភគាំទ្រពីមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍន៍អន្តរជាតិ (IDRC) បានជ្រើសរើសសហគមន៍នេសាទនេះជាសហគមន៍គោលដៅដើម្បីជួយពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ ក្នុងការចូលរួមគ្រប់គ្រងធនធានជលផលនៅក្នុងមូលដ្ឋានរបស់ខ្លួនឱ្យបានល្អ និង ផ្តល់នូវកម្មវិធីឥណទានខ្នាតតូចដល់សមាជិកសហគមន៍នេសាទ (រូបទី ៤)។

នៅក្នុងឆ្នាំ ២០០៦ ករណីវសិក្សាអំពី "ការប្រកបរបរចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋក្នុងសហគមន៍នេសាទកំពង់ក្រសាំង " ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីសិក្សាអំពីជីវិភាពរស់នៅរបស់ប្រជាជននៅក្នុងសហគមន៍នេសាទកំពង់ក្រសាំង បន្ទាប់ពីបង្កើតបានសហគមន៍នេសាទ ហើយផ្តល់នូវអនុសាសន៍សម្រាប់បន្តនូវការគាំទ្រដល់កិច្ចអភិវឌ្ឍន៍ពាក់ព័ន្ធនឹងជីវភាពរស់នៅរបស់ប្រជាជនក្នុងសហគមន៍នេសាទនេះឱ្យបានកាន់តែល្អប្រសើរថែមទៀត ។ ករណីសិក្សានេះត្រូវបានរៀបចំឡើងដោយមន្ត្រីសមភាគីគម្រោងនៃការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ មន្ត្រីសមភាគីរបស់ការិយាល័យជលផលខេត្តតាកែវ និង អង្គការដៃគូមួយចំនួនទៀត ។ ដោយឡែក វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (CBNRMLI) បានផ្តល់នូវវគ្គបណ្តុះបណ្តាលអំពីការសរសេរករណីសិក្សា និង បានជួយរៀបចំកែសម្រួលអត្ថបទករណីសិក្សានេះ ។ ករណីសិក្សានេះមាន ៤ ផ្នែកសំខាន់ៗ គឺ ស្ថានបច្ចុប្បន្ន និង បញ្ហារបស់សហគមន៍នេសាទស្ថានភាពជីវភាពរស់នៅរបស់ប្រជាជននៅក្នុងសហគមន៍ ការគាំទ្រឥណទានខ្នាតតូច ការកសាងសមត្ថភាព សហគមន៍នេសាទ សេចក្តីសន្និដ្ឋាន និង អនុសាសន៍នានា ។ វិធីសាស្ត្រដែលបានប្រើនៅក្នុងការសិក្សាស្រាវជ្រាវសម្រាប់ករណីសិក្សានេះរួមមាន: ការធ្វើសម្ភាសន៍ផ្ទាល់ ការពិភាក្សាជាក្រុម ការប្រមូលទិន្នន័យដែលមានស្រាប់ និង ការទទួលយកមតិយោបល់ពីប្រជាជន និង ការធ្វើអង្កេតផ្ទាល់អំពីស្ថានភាពជាក់ស្តែងនៅក្នុងសហគមន៍ ។

រូបភាពទី ៤: ផែនទីសហគមន៍នេសាទកំពង់ក្រសាំង (ឧបសម្ព័ន្ធទី១ )





## ២. ស្ថានភាព និងបញ្ហាប្រឈមនៅក្នុងសហគមន៍នេសាទកំពង់ក្រសាំង

សហគមន៍នេសាទកំពង់ក្រសាំងសម្បូណ៌ទៅដោយធនធានធម្មជាតិ និង មានសក្តានុពលយ៉ាងធំធេងចំពោះវិស័យកសិកម្ម ជាពិសេសការធ្វើស្រែ ប៉ុន្តែបញ្ហាសំខាន់ដែលកើតមានពាក់ព័ន្ធនឹងជីវភាពរស់នៅរបស់ប្រជាជននៅក្នុងសហគមន៍នេះ គឺការថយចុះនៃធនធានជលផលដោយមូលហេតុបណ្តាលមកពីការប្រព្រឹត្តបទល្មើសនេសាទនៅតែកើតមាន ទោះបីជាសហគមន៍នេសាទនៅក្នុងតំបន់នេះត្រូវបានបង្កើតឡើង ហើយមានការចូលរួមយាមល្បាតការពារពីសំណាក់សហគមន៍នេសាទ និង មន្ត្រីការិយាល័យជលផលខេត្តតាកែវហើយក៏ដោយ ។ អ្នកប្រព្រឹត្តបទល្មើសនេសាទភាគច្រើនគឺចូលមកពីប្រទេសវៀតណាម និង បណ្តាឃុំជិតខាង ។ អ្នកប្រព្រឹត្តបទល្មើសនេសាទទាំងនោះ គឺភាគច្រើនប្រើប្រាស់ឧបករណ៍ស្ប៉ៃមុង និង ឧបករណ៍ឆក់ចូលមកចាប់ត្រីនៅក្នុងកន្លែងនេសាទសហគមន៍ ។

នៅរដូវវស្សា ពេលទឹកឡើងខ្ពស់បានធ្វើឱ្យដែនទឹកមានទំហំធំល្វឹងល្វើយ ហើយមានខ្យល់ព្យុះជាញឹកញាប់ដែលជាឧបសគ្គចំពោះអ្នកភូមិ។ អ្នកភូមិពុំដែលបានទទួលព័ត៌មានអំពីបាតុភូតធម្មជាតិពីស្ថានីយ៍ព្យាករណ៍ និង ឧតុនិយមជាមុនឡើយ។ បាតុភូតទាំងនេះធ្វើឱ្យរាំងស្ទះដល់ការធ្វើនេសាទរបស់អ្នកភូមិ និង បាត់សម្ភារៈ ហើយជួនកាលធ្វើឱ្យមានគ្រោះថ្នាក់ដល់អាយុជីវិតប្រជានេសាទទៀតផង ។ ភាពចៃដន្យដែលកើតឡើងនៅពេលដែលប្រជានេសាទក្នុងឃុំកំពង់ក្រសាំងចេញទៅធ្វើនេសាទបានក្លាយជាបញ្ហាធ្ងន់ធ្ងរ ហើយបញ្ហានេះបានកើតឡើងនៅក្នុងរដូវទឹកឡើងរយៈពេលយ៉ាងតិចណាស់ ៦ ខែ ក្នុង ១ឆ្នាំ ។

ចំពោះការធ្វើស្រែ និងដាំដំណាំក៏ពួកគាត់ប្រឈមមុខជាមួយបញ្ហាជាច្រើនដែរ ដូចជាប្រឡាយរាក់ពុំមានទឹកគ្រប់គ្រាន់ ខ្វះបច្ចេកទេស ខ្វះដើមទុន និង ខ្វះទីផ្សារសម្រាប់លក់ផលិតផល ជាដើម។ លើសពីនេះទៅទៀត គុណភាពទឹកនៅក្នុងប្រឡាយកាន់តែមានភាពក្រខ្វក់ទៅៗ ពីព្រោះកសិករភាគច្រើន គឺប្រើប្រាស់ជីគីមី និង ថ្នាំគីមី ដោយពុំមានការយល់ដឹងអំពីរបៀបប្រើប្រាស់ឱ្យបានសមស្រប និង ផលប៉ះពាល់ដល់បរិស្ថានឡើយ ។ កសិករពុំដែលបានទទួលការណែនាំអំពីផលប៉ះពាល់ទាំងនេះពីស្ថាប័នណាមួយឡើយ ពួកគាត់បានត្រឹមតែរៀនសូត្រពីរបៀបប្រើប្រាស់ពីអ្នកលក់តែប៉ុណ្ណោះ ។ ផលិតផលកសិកម្មនៅក្នុងឃុំកំពង់ក្រសាំងពុំមានបរិមាណច្រើនឡើយ កសិករធ្វើស្រែដោយប្រើប្រាស់ពូជស្រូវ អ៊ីអ៊ែរ ៥០៤ ដែលនាំចូលពីប្រទេសវៀតណាម ។ ក្រៅពីបញ្ហាខាងលើ កសិករនៅក្នុងឃុំកំពង់ក្រសាំងពុំមានដើមទុនគ្រប់គ្រាន់ និង មានដីតិចតួចសម្រាប់ប្រកបរបរធ្វើស្រែ ដូច្នេះរាល់វិធីសាស្ត្រ និង មធ្យោបាយដែលធ្វើឱ្យទិន្នផលស្រូវកើនឡើងខ្ពស់ដោយមិនទាមទារដើមទុនច្រើន គឺជាជម្រើសដែលពួកគាត់តែងតែទទួលយក ។ ប៉ុន្តែអ្វីដែលធ្វើឱ្យកសិករពុំបានដឹង គឺការប្រើប្រាស់ថ្នាំគីមីដែលធ្វើឱ្យមានភាពក្រខ្វក់ដល់ទឹកនៅក្នុងប្រឡាយ និង ដែននេសាទផ្សេងទៀតដែលករណីនេះបណ្តាឱ្យកើតមានបញ្ហាជាច្រើនចំពោះជីវភាពរស់នៅរបស់ប្រជាជនទៅក្នុងថ្ងៃអនាគត ។ ផលិតផលស្រូវ និង ផលិតផលផ្សេងទៀតត្រូវបានដឹកជញ្ជូនដោយទូកតាមប្រឡាយ ដូច្នេះភាពចាំបាច់គឺទាមទារឱ្យមានការថែទាំប្រឡាយ និង រក្សាគុណភាពទឹកឱ្យនៅតែល្អជានិច្ច ។

បញ្ហាផ្សេងទៀតដែលកើតមាននៅក្នុងឃុំកំពង់ក្រសាំង គឺពាក់ព័ន្ធនឹងការចិញ្ចឹមជ្រូក មាន់ ទា និងត្រី ។ ប្រជាពលរដ្ឋនៅក្នុងឃុំកំពង់ក្រសាំងពុំដែលបានទទួលបច្ចេកទេសជំនាញពីវគ្គបណ្តុះបណ្តាលណាមួយឡើយ ប៉ុន្តែចំណេះដឹងបច្ចេកទេសចិញ្ចឹមសត្វដែលពួកគាត់បានអនុវត្ត គឺទទួលបានតាមការប្រាប់ពីមាត់មួយទៅមាត់មួយប៉ុណ្ណោះ ។ ប្រជាជនមួយចំនួនមិនហ៊ានចំណាយដើមទុនក្នុងការចិញ្ចឹមសត្វឡើយដោយសារខ្លាចខាត ពីព្រោះពួកគាត់ពុំមានបច្ចេកទេសច្បាស់លាស់ក្នុងការចិញ្ចឹម ហើយនៅក្នុងឃុំកំពង់ក្រសាំងពុំមានពេទ្យសត្វបម្រើការ និង ត្រួតពិនិត្យនៅឡើយ ។

ការខ្វះទីផ្សារនៅក្នុងស្រុក គឺជាបញ្ហាចំបងមួយសម្រាប់ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងឃុំ ។ ទីផ្សារនៅទីរួមខេត្តតាកែវ គឺមានចម្ងាយឆ្ងាយពីទីតាំងឃុំកំពង់ក្រសាំង ហើយពុំមានផ្លូវគោកសម្រាប់ធ្វើដំណើរឡើយ ដូច្នេះជាប្រជាជនពុំមានជម្រើសផ្សេងទៀតក្រៅពីនាំផលិតផលទៅលក់នៅប្រទេសវៀតណាម ហើយការទិញឧបករណ៍ និងសម្ភារៈសម្រាប់បង្កបង្កើនផលទាំងអស់ក៏ត្រូវធ្វើឡើងនៅទីផ្សារវៀតណាមដែរ ពីព្រោះទីតាំងឃុំកំពង់ក្រសាំង គឺនៅជាប់នឹងព្រំដែននៃប្រទេសវៀតណាម ។ បញ្ហាខ្វះទីផ្សារក្នុងស្រុកបានធ្វើឱ្យឈ្មួញមួយចំនួនឆ្លៀតឱកាសតម្លើង ឬទំលាក់ថ្លៃផលិតផលតាមទំនើងចិត្តរបស់ខ្លួន ។

## ៣. ស្ថានភាពមុខរបរចិញ្ចឹមជីវិតរបស់ប្រជាជននៅក្នុងសហគមន៍នេសាទកំពង់ក្រសាំង

មុខរបរសម្រាប់ចិញ្ចឹមជីវិតសំខាន់ៗនៅក្នុងសហគមន៍នេសាទកំពង់ក្រសាំង គឺការធ្វើស្រែប្រាំង និងការធ្វើនេសាទ ពីព្រោះស្ថានភាពភូមិសាស្ត្ររបស់ឃុំទាំងមូលគឺស្ថិតនៅតាមដងស្ទឹង ព្រែក និងប្រឡាយ។ ក្រៅពីមុខរបរធ្វើស្រែនិងនេសាទ ប្រជាជននៅក្នុងឃុំមានមុខរបរចិញ្ចឹមសត្វ និងចិញ្ចឹមត្រីជាមុខរបរបន្ទាប់បន្សំសម្រាប់រកប្រាក់ចំណូលបន្ថែមដល់គ្រួសារ។

### ៣.១. ការធ្វើនេសាទ

នៅមុនពេលបង្កើតសហគមន៍នេសាទ ស្ថានភាពនេសាទមានភាពអាណាធិបតេយ្យ ដោយអ្នកនេសាទប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ជាច្រើនដូចជា ឧបករណ៍នេសាទឆក់ ស្បៃមុងបានចូលមកធ្វើនេសាទនៅក្នុងតំបន់នេះ ជាពិសេសទំនាស់តែងតែកើតមានរវាងម្ចាស់ឡូត៍នេសាទ និងប្រជានេសាទ ពីព្រោះប្រជានេសាទត្រូវបង់ប្រាក់ឱ្យទៅម្ចាស់ឡូត៍នេសាទនៅពេលដែលខ្លួនចេញទៅធ្វើនេសាទម្តងៗនៅក្នុងតំបន់ឡូត៍នេសាទ ព្រោះពួកគាត់ពុំអាចចេញទៅនេសាទបានឆ្ងាយពីភូមិដោយខ្លាចខ្យល់ព្យុះ ហើយពុំមានទូកធំសម្រាប់ចេញទៅធ្វើនេសាទបាន ។

ប៉ុន្តែ បន្ទាប់ពីរាជរដ្ឋាភិបាលបានធ្វើការកែទម្រង់គោលនយោបាយវិស័យជលផល ដោយបានធ្វើការកាត់ បន្ថយ និងលុបនាទីឡូត៍នេសាទជូនប្រជាជនធ្វើនេសាទជាលក្ខណៈគ្រួសារ តាមរយៈការបង្កើតជាសហគមន៍នេសាទ រួចមកប្រជាជន



ក្នុងភូមិអាចចេញទៅធ្វើនេសាទបានដោយសេរី ដោយមិនចាំបាច់បង់ប្រាក់ឱ្យទៅម្ចាស់ឡូត៍នេសាទដូចមុនឡើយ បទល្មើសនេសាទដូចជាការប្រើឧបករណ៍ឆក់ ស្បៃមុងមានការថយចុះជាបណ្តើរៗ ហើយផលត្រីមានការកើនឡើង ។ នៅរដូវវស្សា ប្រជាជនក្នុងសហគមន៍ប្រកបរបរធ្វើនេសាទ គឺចាប់ពីខែ កក្កដា ដល់ខែ វិច្ឆិកា ហើយពួកគាត់ប្រើប្រាស់ឧបករណ៍នេសាទចំរុះដូចជា សន្ទូចរនង សំណាញ់ មង និងលបជាដើម ។ ចំនួនអ្នកនេសាទក្នុងសហគមន៍នេសាទនេះមាន ៣៨៥ នាក់ ក្នុងនោះចំនួន ១០% ជាអ្នកនេសាទសុទ្ធសាធ និង ៩០% ជាអ្នកនេសាទផង និងធ្វើស្រែផង ។ ប្រភេទត្រីដែលមាននៅតំបន់នេះមានដូចជា ត្រីលិញ ត្រីក្រាញ់ ត្រីកំផ្លាញ ត្រីរស់ ត្រីចង្វា ត្រីពោធិ ត្រីតាអោន ។ នៅរដូវវស្សា ប្រភេទត្រីដែលនេសាទបានច្រើនជាងគេគឺ ត្រីលិញ ដែលអ្នកនេសាទម្នាក់អាចចាប់បានពី ៨ ទៅ ៣០ គីឡូក្រាម ក្នុង ១ ថ្ងៃ ដោយប្រើប្រាស់ឧបករណ៍នេសាទលក្ខណៈគ្រួសារ ។ ទីផ្សារសម្រាប់លក់ផលត្រីទាំងនេះ គឺនាំចេញទៅប្រទេសវៀតណាមដោយមានឈ្មួញមកទិញដល់ទីកន្លែង ។ តម្លៃត្រីលិញជាមធ្យមគឺ ពី ៥០០ ទៅ ៦០០ រៀល ក្នុង ១ គីឡូក្រាម ។ ទោះបីជាផលនេសាទចាប់បានមានការកើនឡើងក្តី ប៉ុន្តែដោយសារថ្លៃសាំង និងឧបករណ៍នេសាទមានការកើនឡើងខ្លាំងបានធ្វើឱ្យការប្រកបរបរនេសាទរបស់ពួកគាត់ពុំទទួលបានប្រាក់ចំណេចច្រើនឡើយ ។ ជួនកាលអ្នកនេសាទបានលួចធ្វើនេសាទដោយប្រើប្រាស់ឧបករណ៍នេសាទខុសច្បាប់ ឬស្វែងរកការងារផ្សេងទៀត ទោះបីជាមានការលំបាកយ៉ាងណាក្តីដើម្បីបង្កើននូវប្រាក់ចំណូលរបស់ខ្លួន ។ ស្ត្រី មិនសូវចូលរួមក្នុងការងារធ្វើនេសាទទេ ដោយសារមានការបារម្ភនឹងសុវត្ថិភាពផ្ទាល់ខ្លួន ពីព្រោះនៅតំបន់នេះក្នុងរដូវវស្សាមានខ្យល់ព្យុះអាចកើតឡើងគ្រប់ពេល ដូច្នេះស្ត្រីតែងតែស្ថិតនៅក្នុងផ្ទះដើម្បីមើលថែរក្សាកូន ។



សកម្មភាពធ្វើនេសាទជាលក្ខណៈគ្រួសារ
(ថតរូបភាពដោយ ទិត ភារៈ, ២០០៦)

តាមការរៀបរាប់របស់ប្រជានេសាទនៅក្នុងឃុំកំពង់ក្រសាំងបានឱ្យដឹងថា បន្ទាប់ពីកំណែទំរង់គោលនយោបាយវិស័យជលផលរបស់រាជរដ្ឋាភិបាលដែលបានកាត់នាទីឡូត៍នេសាទជូនប្រជាពលរដ្ឋ ដើម្បីបង្កើតសហគមន៍នេសាទមកធ្វើឱ្យពួកគាត់មានដែននេសាទច្រើនជាងមុនដែលអាចធ្វើនេសាទបានគ្រប់ពេលវេលាដោយពុំចាំបាច់បង់ប្រាក់ឱ្យអាជីវករឡូត៍នេសាទឡើយ ដូច្នេះជីវិភាពរបស់ពួកគាត់បានប្រសើរជាងមុន ។

ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០០៦

## ៣.២. ការចិញ្ចឹមត្រី

ក្រៅអំពីការធ្វើនេសាទ នៅក្នុងសហគមន៍នេសាទនេះមាន ៨ គ្រួសារបានប្រកបមុខរបរចិញ្ចឹមត្រីផាលក្ខណៈគ្រួសារ ក្នុងនោះ ៥ គ្រួសារចិញ្ចឹមក្នុងប៉ែ និង ៣ គ្រួសារចិញ្ចឹមក្នុងស្រះ ។ ប្រភេទត្រីដែលពួកគាត់ចូលចិត្តចិញ្ចឹមរួមមាន: ត្រីអណ្តែង ឆ្តិន និងទីឡាព្យា។ បែត្រីដែលពួកគាត់ប្រើសម្រាប់ចិញ្ចឹម គឺមានបណ្តោយ ប្រវែង ៣ ម៉ែត្រ និងទទឹងប្រវែង ២ ម៉ែត្រ ។ ការចិញ្ចឹមត្រីក្នុងបែរ គឺធ្វើឡើងនៅក្នុងរដូវវស្សា ការប្រមូលផលត្រី គឺតែងតែធ្វើឡើងក្នុងរយៈពេល ៦ ខែម្តង ហើយប្រមូលបានផលប្រមាណ ១.៥០០ គីឡូក្រាម ។ ផលត្រីចិញ្ចឹមពុំសូវមានគុណភាពនោះទេ ដោយសារតែទឹកមានជាតិពុលបណ្តាលមកពីការប្រើប្រាស់ជី និងថ្នាំគីមីរបស់ប្រជាកសិករនៅក្នុងឃុំ ហើយកាកសំណល់ពីទូកនិងកាណូតចូលទៅក្នុងទឹក។ ជួនកាលត្រីបានពុលងាប់ដែលធ្វើឱ្យការប្រមូលផលត្រីពុំទទួលបានបរិមាណខ្ពស់ ។



សកម្មភាពចិញ្ចឹមត្រីក្នុងបែររបស់ប្រជាពលរដ្ឋ
(ថតរូបភាពដោយ ទិត ភារៈ, ២០០៦)

លោកសិរិត សៀ អាយុ៤៤ឆ្នាំ ដែលជាប្រជាពលរដ្ឋម្នាក់មានមុខរបរចិញ្ចឹមត្រីក្នុងបែរបានមានប្រសាសន៍ថា គាត់ចិញ្ចឹមត្រី ពុំបានផលល្អទេ ពីព្រោះទឹកមិនល្អ ហើយមានជម្រៅរាក់នៅរដូវប្រាំង ម្យ៉ាងទៀតដោយកាត់ពុំមានបច្ចេកទេសក្នុងការចិញ្ចឹម ដូចនេះគាត់ផ្អាកការចិញ្ចឹមរបស់គាត់ ។ ប៉ុន្តែ ប្រសិនបើគាត់បានទទួលបច្ចេកទេសចិញ្ចឹមត្រីគាត់នឹងបន្តចិញ្ចឹមទៀត ។

ថ្ងៃទី ២៧ មេសា ២០០៦

## ៣.៣. ការធ្វើស្រែ

ប្រជាជនរស់នៅក្នុងសហគមន៍កំពង់ក្រសាំង ធ្វើស្រែពីរលើកក្នុង ១ រដូវ ដោយចាប់ពីខែ ធ្នូ ដល់ខែ មិថុនា ដោយក្នុង ១លើក មានរយៈពេល ៣ខែ ។ ប៉ុន្តែប្រសិនបើអាកាសធាតុប្រែប្រួលដែលធ្វើឱ្យទឹកស្រកយឺតពួកគាត់អាចធ្វើបានតែ ១លើក ក្នុង ១ រដូវប៉ុណ្ណោះ ។ ការប្រមូលផលរបស់ពួកគាត់ក្នុង ១ ហិកតា ទទួលបានពី ៥ ទៅ ៧ តោន សម្រាប់ការប្រមូលផលលើកទីមួយ និងពី ៣ ទៅ ៤ តោនក្នុង ១ ហិចតាសម្រាប់ការប្រមូលផលលើកទី២ ។ ប្រជាជន

នៅក្នុងសហគមន៍កំពង់ក្រសាំងមានដីស្រែពី ០,៥ ទៅ ៦ ហិកតាក្នុងមួយគ្រួសារ ។ ផលស្រូវដែលផលិតបានពួកគាត់រក្សាទុកតែ ១ ទៅ ២ តោនប៉ុណ្ណោះសម្រាប់ហូបចុកក្នុងគ្រួសារ ១ ឆ្នាំ ក្រៅពីនោះចំពួកគាត់លក់ចេញទៅប្រទេសវៀតណាមក្នុងតំលៃពី ៥០០ ទៅ ៦០០ រៀល ក្នុង១គីឡូក្រាម ។ ប្រាក់ចំណូលដែលបានមកពីការលក់ស្រូវត្រូវបានទូទាត់សងទៅលើថ្លៃពូជស្រូវ ថ្លៃជីគីមី ថ្នាំសម្លាប់សត្វល្អិត និងការចំណាយផ្សេងទៀត ដូចជា ថ្លៃច្រូត និងម៉ាស៊ីនបោកដែលត្រូវជួលពីប្រទេសវៀតណាម ។ ចំពោះប្រជាជនដែលមានដីស្រែតិចតួច ការរកប្រាក់ ចំណូលរបស់ពួកគាត់មានការលំបាកណាស់ ជាពិសេសពេលដែលពួកគាត់ជួបគ្រោះធម្មជាតិជាយថាហេតុគឺធ្វើឱ្យពួក គាត់មានការលំបាកកាន់តែខ្លាំង ។

ដើម្បីបង្កើនប្រាក់ចំណូលដែលបានមកពីការធ្វើស្រែ ប្រជាជនត្រូវបង្ខំចិត្តប្រើប្រាស់ជីគីមី ហើយផលិតផលទាំងនេះបាននាំចូលពីប្រទេសវៀតណាមដូចជា ជីអ៊ុយរ៉េ ថ្នាំសម្លាប់សត្វល្អិត ថ្នាំបំផ្លាញស្មៅ ថ្នាំប៉ូវផ្លែ ។ ដំណាំរួមផ្សំដែលប្រជាជនបានដាំ គឺសំរាប់តែហូបក្នុងគ្រួសារតែប៉ុណ្ណោះ ដោយសារតែទិន្នផលទទួលបានមានចំនួនតិចតួច ដូចជា ពោត សណ្តែក ត្រសក់ ននោង ត្រប់ ប៉េងប៉ោះ ល្ពៅ ជាដើម ។



សកម្មភាពសម្ភាសន៍ប្រជាពលរដ្ឋធ្វើស្រែ
(ថតរូបភាពដោយ ទិត ភារៈ, ២០០៦)

តាមប្រសាសន៍របស់លោកពូ ផៃ យឿន អាយុ ៤២ឆ្នាំរស់នៅក្នុងភូមិកំពង់ក្រសាំងបាននិយាយថាគាត់មានការលំបាកណាស់ក្នុងការធ្វើស្រែដោយត្រូវជួបប្រទះសត្វកណ្តុរកាត់ស្រូវមានជំងឺក្រាស៊ី ហើយត្រូវចំណាយច្រើនទៅលើការទិញជី និងថ្នាំសម្លាប់សត្វល្អិត លើសពីនេះទៅទៀត គឺត្រូវចំណាយទៅលើការជួលសម្ភារៈសំរាប់ធ្វើស្រែដូចនេះហើយទើបពួកគាត់ធ្វើស្រែពុំសូវទទួលបានផលចំណេញ គឺអាចគ្រប់គ្រាន់សម្រាប់ដោះស្រាយក្នុងគ្រួសាររបស់ពួកគាត់ប៉ុណ្ណោះ ។

ថ្ងៃទី ២៨ មិនា ២០០៦

តាមប្រសាសន៍របស់លោកពូ យាង ញ៉ន មានមុខរបរធ្វើនេសាទ និងធ្វើស្រែដោយសារគាត់គ្មានដើមទុនគ្រប់គ្រាន់ធ្វើឱ្យគាត់ពុំមានលទ្ធភាពធ្វើស្រែឱ្យអស់ដីរបស់គាត់ឡើយ ដូចនេះហើយទើបជីវភាពគ្រួសារគាត់មានការលំបាក ប៉ុន្តែក្រោយពីបានទទួលប្រាក់ឥណទាន គាត់បានពង្រីកការធ្វើស្រែរបស់គាត់រហូតអស់ដី ជាហេតុធ្វើឱ្យគ្រួសារគាត់មានជីវិភាពប្រសើជាងមុន ។

ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០០៦



សកម្មភាពប្រមូលផលស្រូវគ្រួសារ ពូ ញ៉ន
(ថតរូបភាពដោយ ទិត ភារៈ, ២០០៦)



## ៤. កម្មវិធីឥណទាន

គម្រោងមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍន៍អន្តរជាតិ IDRC បានផ្តល់ជាប្រាក់ឥណទានខ្នាតតូចដល់ប្រជាជនចំនួន ៤៤ គ្រួសារនៅក្នុងសហគមន៍នេសាទកំពង់ក្រសាំងចាប់តាំងពីខែ មិនា ឆ្នាំ ២០០៥ មក ។ ការផ្តល់ឥណទានត្រូវបានរៀបចំឱ្យខ្ចី ដើម្បីយកទៅប្រកបរបរ និងពង្រីកមុខរបរបន្ថែមដូចជា ធ្វើស្រែ ធ្វើនេសាទ និងចិញ្ចឹមសត្វ ។ កម្មវិធីឥណទាននេះតម្រូវឱ្យមានការរៀបចំជាក្រុមតូចៗដែលឱ្យឈ្មោះថាក្រុមជួយខ្លួនឯង ។ ក្នុង១ក្រុមមានសមាជិក ៧ គ្រួសារ។ សមាជិកក្រុមម្នាក់ៗទទួលបានប្រាក់កម្ចីជាអតិបរមា ចំនួន ២០០.០០០ រៀលស្មើនិង ៥០ ដុល្លា ។ ប្រសិនបើសមាជិកក្រុមណាម្នាក់មិនបានសងប្រាក់កម្ចីនោះសមាជិកក្រុមចំនួន ៦ នាក់ ទៀតត្រូវទទួលខុសត្រូវលើប្រាក់កម្ចីនេះមុនរយៈពេល ៦ ខែ ក្នុងតម្លៃអត្រាការប្រាក់ ២% ក្នុង ១ ខែ សម្រាប់ជំហានទី១ ។ ការប្រាក់ដែលសហគមន៍ទទួលបានត្រូវបានប្រើក្នុងគោលបំណងដូចតទៅ:

- ៥០% ត្រូវបានដំកល់ទុកក្នុងបេឡាសហគមន៍នេសាទដើម្បីពង្រីកទុន
- ១០% សម្រាប់លើកទឹកចិត្តដល់ប្រធានគណៈកម្មកាសហគមន៍នេសាទ
- ២០% សម្រាប់លើកទឹកចិត្តប្រធានក្រុមសន្សំនីមួយៗ
- ៥% សម្រាប់លើកទឹកចិត្តដល់អជ្ញាធរភូមិឃុំ
- ១៥% សម្រាប់អនុវត្តសកម្មភាពការងារក្នុងការគ្រប់គ្រងសហគមន៍នេសាទ

កម្មវិធីផ្តល់ឥណទាននេះ គឺត្រូវបានធ្វើកិច្ចព្រមព្រៀងរវាងសហគមន៍ជាមួយសមាជិកក្រុមសន្សំជួយខ្លួនឯង ហើយសមាជិកក្រុមមានសេរីភាពក្នុងការជ្រើសរើសមុខរបរទៅតាមគម្រោងរបស់ពួកគាត់ ឧទាហរណ៍ការប្រកបរបរចិញ្ចឹមជីវិតនៅក្នុងសហគមន៍នេសាទនេះ គឺការចិញ្ចឹមសត្វនៅរដូវប្រាំងដែលជាមុខរបរបន្ថែមសម្រាប់ជួយទ្រទ្រង់ដល់ជីវភាពរបស់ពួកគាត់ ។ ការចិញ្ចឹមសត្វរួមមាន ជ្រូក មាន់ និងទា ក្នុងនោះការចិញ្ចឹមជ្រូកក្នុង ១ គ្រួសារមានចំនួនពី ១-២០ ចំណែកការចិញ្ចឹមមាន់ ទា មានចំនួន ២០-៥០០ ។ សត្វដែលពួកគាត់ចិញ្ចឹមបានទាំងអស់ គឺយកទៅលក់នៅទីផ្សារក្នុងប្រទេសវៀតណាម ឬ ឈ្មួញកណ្តាលនៅក្នុងភូមិប្រមូលទិញដើម្បីយកទៅលក់បន្ត ។ គ្រួសារភាគច្រើនបានប្រើប្រាស់ប្រាក់កម្ចីទាំងនោះសំរាប់ចិញ្ចឹមសត្វ ។





សកម្មភាពចិញ្ចឹមទារបស់ប្រជាពលរដ្ឋ

(ថតរូបភាពដោយ ទិត ភារ:, ២០០៦)

បងប្រុស ញ៉ែម សារុំ អាយុ ២៦ឆ្នាំរស់នៅក្នុងភូមិប្ញូរី ជលសាបាននិយាយថា គ្រួសាររបស់គាត់មានរបរធ្វើស្រែ និងធ្វើនេសាទដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ខ្លួន។ គ្រួសារគាត់តែងតែជួបប្រទះនឹងការលំបាក ពីព្រោះការធ្វើស្រែបានត្រឹមតែការហូបនៅក្នុងគ្រួសារប៉ុណ្ណោះ ប៉ុន្តែក្រោយពីបានទទួលប្រាក់ឥណទានពីសហគមន៍នេសាទគាត់ មានមុខរបរ១ទៀត គឺការចិញ្ចឹមទាធ្វើឱ្យជីវភាពប្រសើរឡើង ។

ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ២០០៦

បងស្រី អ៊ុន ស្រីពេជ ជាសមាជិកក្រុមឥណទាន ហើយជាប្រធានសមាគមន៍គ្រោះមហន្តរាយនៃភូមិ ក្តុលជ្រុំ ហើយក៏ជាបេឡាសហគមន៍នេសាទកំពង់ក្រសាំង គាត់មានមុខរបរធ្វើស្រែ និងការធ្វើនេសាទបន្តិចបន្តួច តែប៉ុណ្ណោះកាលពីមិនទាន់បង្កើតជាសហគមន៍នេសាទ ប៉ុន្តែក្រោយពេលបង្កើតសហគមន៍នេសាទមក គាត់បានទទួលប្រាក់ឥណទានពីគម្រោង IDRC ធ្វើឱ្យគាត់មានលទ្ធភាពប្រកបមុខរបរបន្ថែមមួយទៀត គឺការចិញ្ចឹមជ្រូកដែលធ្វើឱ្យជីវិភាពរបស់គាត់ប្រសើជាងមុន ។



សកម្មភាពចិញ្ចឹមជ្រូករបស់សមាជិកឥណទាន

(ថតរូបភាពដោយ ទិត ភារ:, ២០០៦)

បងស្រី អ៊ុន ស្រីពេជ អាយុ ៤១រស់នៅក្នុងភូមិ ក្តុលជ្រុំ បាននិយាយថា កាលពីមុនខ្ញុំមានមុខរបរធ្វើស្រែ និងធ្វើនេសាទតែប៉ុណ្ណោះ ជីវភាពរបស់ខ្ញុំមានការលំបាកណាស់ ប៉ុន្តែក្រោយពីបានទទួលប្រាក់ឥណទានពីសហគមន៍យកមកចិញ្ចឹមជ្រូកចំនួន ២ក្បាល លក់អស់ ១ ក្បាល នៅសល់ ១ ក្បាល ជីវិភាពរបស់ខ្ញុំបានធូរធារជាងមុន ។

ថ្ងៃទី ២៨ មេសា ២០០៦



# ៥. កម្មវិធីកសាងសមត្ថភាពនៅក្នុងសហគមន៍

ស្ថាប័នជំនាញ និងអង្គការនានាដែលបានចូលមកធ្វើការបណ្តុះបណ្តាលអប់រំ និងផ្សព្វផ្សាយអំពីការគ្រប់គ្រងធនធានជលផលនៅក្នុងសហគមន៍កំពង់ក្រសាំង មានគម្រោងគ្រប់គ្រងសហគមន៍នេសាទនៃការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទរបស់រដ្ឋបាលជលផល វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ អង្គការចំរើនជាតិខ្មែរ កម្មវិធីសិលា អង្គការ PAP មណ្ឌលសុខភាព មន្ទីរកសិកម្ម និងអង្គការមូលនិធិសង្គម ។

ទោះបីជាកសិករនៅក្នុងសហគមន៍កំពង់ក្រសាំងបានទទួលវគ្គបណ្តុះបណ្តាលមួយចំនួន អំពីបច្ចេកទេសធ្វើស្រែក៏ដោយ ប៉ុន្តែចំណេះដឹងទាំងនេះមានការពិបាកក្នុងការទទួលយក និងមិនសមស្របសម្រាប់កសិករនៅទីនោះឡើយ ពីព្រោះលក្ខណៈដី និងអាកាសធាតុមានលក្ខណៈខុសគ្នា ។ ពូជថ្មីត្រូវបានជ្រើសរើសយកទៅដាំ ប៉ុន្តែពូជនោះវាមិនផ្តល់ទិន្នផលខ្ពស់ទេ។ ការធ្វើស្រែនៅប្រទេសហ្វីលីពីនមានបច្ចេកទេសផ្សេងមិនអាចអនុវត្តដូចគ្នានៅក្នុងសហគមន៍កំពង់ក្រសាំងបានឡើយ។

វគ្គបណ្តុះបណ្តុះដល់គណៈកម្មការសហគមន៍គឺមានអត្ថប្រយោជន៍ ពីព្រោះពួកគាត់បានប្រើប្រាស់ក្នុងការរៀបចំធ្វើផែនការ ការធ្វើរបាយការណ៍ ការបែងចែកភារកិច្ចរបស់គណៈកម្មការ ការចងក្រងក្រុមល្បាត ក្រុមផ្សព្វផ្សាយបន្ត និងក្រុមទំនាក់ទំនង សហប្រតិបត្តិការជាដើម។ ប្រជាជននៅក្នុងសហគមន៍នេះនៅតែមានភាពទន់ខ្សោយចំពោះការទប់ស្កាត់បទល្មើសនេសាទ ប៉ុន្តែពួកគាត់ភាគច្រើនបានផ្សព្វផ្សាយពីសារៈសំខាន់នៃការបង្កើតសហគមន៍ដើម្បីធានានូវនិរន្តរភាពនៃធនធានជលផល ។ ប្រជាជនទាំងនេះជានិច្ចកាលបានចូលរួមយ៉ាងសកម្មជាមួយការងារសហគមន៍ ។ ប្រជាជនបានចូលរួមប្រជុំប្រចាំខែ ហើយគណៈកម្មការសហគមន៍នេសាទមានលទ្ធភាពនេះចេះធ្វើរបាយការណ៍ និងកំណត់ហេតុក្នុងអង្គប្រជុំដោយខ្លួនឯង ។

### វគ្គបណ្តុះបណ្តាលផ្នែកបច្ចេកទេស

- ការបង្កាត់ពូជស្រូវ ដែលផ្តល់ដោយអង្គការ ប្រាសាក់
- របៀបស្ទូងស្រូវតាមប្រទេសហ្វីលីពីន
- ការគ្រប់គ្រងសហគមន៍នេសាទរួមបញ្ចូលវគ្គបណ្តុះបណ្តាលរបៀបគ្រប់គ្រង របៀបធ្វើផែនការ នីតិវិធីនៃការដោះស្រាយទំនាស់ របៀបធ្វើកំណត់ហេតុ និងសរសេររបាយការណ៍ គម្រោងស្នើសុំថវិកា



**ការអប់រំ ផ្សព្វផ្សាយ**

- ការប្រើប្រាស់ និងអនាម័យទឹកស្អាត
- ការពន្យាកំណើត
- អំពើហិង្សាក្នុងគ្រួសារ
- យេនឌ័រ
- ជំងឺគ្រុនផ្ដាសាយបក្សី
- ព្រះរាជក្រឹត្យ និងអនុក្រឹត្យ ស្ដីពីការគ្រប់គ្រងសហគមន៍នេសាទ
- សារៈសំខាន់នៃព្រៃលិចទឹក



សកម្មភាពបណ្ដុះបណ្ដាលគណៈកម្មកាសហគមន៍
(ថតរូបភាពដោយ ទិត ភារៈ, ២០០៦)

តាមប្រសាសន៍គណៈកម្មការសហគមន៍បានឱ្យដឹងថា ក្រោយពីគម្រោងគ្រប់គ្រងសហគមន៍នេសាទការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៃនាយកដ្ឋានជលផល ឧបត្ថម្ភដោយអង្គការ IDRC បានជួយបណ្ដុះបណ្ដាលអំពីការសរសេរកំណត់ហេតុ និងរបាយការណ៍រួចមកគណៈកម្មការសហគមន៍មានការយល់ដឹងច្រើនជាងមុន ។

ថ្ងៃទី ១៥ ខែ វិច្ឆិកា ២០០៤

វគ្គបណ្ដុះបណ្ដាលបានផ្ដល់អោយសហគមន៍នេសាទ ជាជំហ៊ានដំបូងគឺក្នុងគោលបំណងកសាងសមត្ថភាពរបស់ប្រជាជន។ វគ្គបណ្ដុះបណ្ដាលនេះបានផ្ដល់ជំនាញដោយផ្ទាល់ដែលទាក់ទងនឹងការប្រកបមុខរបរចិញ្ចឹមជីវិតដូចជាបច្ចេកទេសធ្វើស្រែ និងជំនាញអភិវឌ្ឍផ្សេងៗទៀតដែលទាក់ទងនឹងការគ្រប់គ្រងធនធានជលផល។ ប្រជាជនមិនមានចំណេះដឹងខ្ពស់ ប៉ុន្តែនេះក៏មិនបានបញ្ឈប់ពួកគាត់អំពីចំណាប់អារម្មណ៍ក្នុងការរៀនសូត្របន្ថែមពីបច្ចេកទេសថ្មីឡើយ ជាពិសេសអំពីជំនាញប្រកបមុខរបរប្រចាំជីវិត។ ផ្អែកតាមគណៈកម្មការសហគមន៍ នេសាទបានឱ្យដឹងថាពួកគាត់បានទទួលវគ្គបណ្ដុះបណ្ដាលលើប្រធានបទសំខាន់ៗមួយចំនួនដូចខាងក្រោម:

* វគ្គបណ្ដុះបណ្ដាលស្ដីពីការប្រើប្រាស់ដីត្រឹមត្រូវនូវជីគីមី ថ្នាំសំលាប់សត្វល្អិត និងផលិតផលគីមីផ្សេងទៀត



- ✱ វគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមសត្វ
- ✱ វគ្គបណ្តុះបណ្តាលពីការចិញ្ចឹមត្រី
- ✱ វគ្គបណ្តុះបណ្តាលពីជំនាញបច្ចេកទេសធ្វើម៉ាស៊ីន
- ✱ ការផ្សព្វផ្សាយ និងអប់រំពីច្បាប់ភូមិបាល
- ✱ ការអប់រំ និងផ្សព្វផ្សាយស្តីពីបញ្ហាយេនឌ័រ និងសារៈសំខាន់នៃការចូលរួមរបស់ស្ត្រី
- ✱ ការផ្សព្វផ្សាយពីបញ្ហាបរិស្ថាន

## ៦. សន្និដ្ឋាន និងអនុសាសន៍

សហគមន៍នេសាទកំពង់ក្រសាំងគឺពឹងផ្អែកលើការធ្វើស្រែនៅរដូវប្រាំងនិងនេសាទសម្រាប់ជីវភាពរស់នៅរបស់ខ្លួន។ ប្រជាជនមិនមានឱកាសច្រើនក្នុងការប្រកបមុខរបរសមស្របដើម្បីចិញ្ចឹមជីវិតដូចជា ការចិញ្ចឹម សត្វ ឬការដាំដំណាំផ្សេងៗ ពីព្រោះស្ថានភាពភូមិសាស្ត្រ និង អាកាសធាតុនៅក្នុងតំបន់នោះមានការលំបាក ម្យ៉ាងវិញទៀត ការខ្វះជំនាញបច្ចេកទេស និង ទុនសម្រាប់ការចាប់ផ្តើមនូវមុខរបរសមស្របនោះជាបញ្ហាមួយដែលកើតមានផងដែរ ។

លក្ខខណ្ឌរស់នៅក្នុងសហគមន៍នេះ គឺមានសភាពក្រីក្រសំរាប់គ្រួសារភាគច្រើន នេះមិនត្រឹមតែប្រជាជនពុំមានឱកាសច្រើនសម្រាប់ប្រកបមុខរបរសមស្របប៉ុណ្ណោះទេ ប៉ុន្តែដោយសារការចំណាយដើមទុនច្រើនសម្រាប់ទិញពូជ ជីគីមី ថ្នាំសំលាប់សត្វល្អិត ប្រេង និងផលិតផលផ្សេងៗទៀតដែលបាននាំមកពីប្រទេសវៀតណាម ។ ម្យ៉ាងទៀត ដោយសារថ្លៃដើមនៃការចំណាយទាំងនោះឡើងថ្លៃ បានបន្ថយនូវប្រាក់ចំណូលរបស់ប្រជាជននៅក្នុងមូលដ្ឋានដែលបានពីការលក់ស្រូវ និងត្រី ។ ដោយសារនៅក្នុងតំបន់នោះពុំមានទីផ្សារសមស្រប ដូច្នេះប្រជាជនមានជម្រើសតែមួយគត់ គឺទិញ និងលក់ផលិតផលទាំងនោះទៅប្រទេសវៀតណាម ។

ការខ្វះខាតប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ដូចជាផ្លូវថ្នល់ ស្ពាន ក៏ជាមូលហេតុដ៏លំបាកសម្រាប់ប្រជាជនរស់នៅ និងការប្រកបមុខរបរចិញ្ចឹមជីវិតផងដែរ ។ កុមារមួយចំនួនពុំមានឱកាសបានចូលសាលារៀនដោយសារតែកង្វះ ផ្លូវថ្នល់នេះដែរ ។ ដោយឡែក សេវាថែទាំសុខភាពក៏មានកំណត់ដែរនៅក្នុងសហគមន៍នេះ ។

ការកសាងសមត្ថភាព និងការគាំទ្រកម្មវិធីឥណទានខ្នាតតូចគឺជាការចាប់ផ្តើមដ៏ប្រសើរសម្រាប់ជីវភាពរស់នៅរបស់ប្រជាជននៅក្នុងសហគមន៍នេសាទកំពង់ក្រសាំង ។ គណៈកម្មការសហគមន៍នេសាទបានបង្កើននូវសមត្ថភាពជំនាញ និងការទទួលខុសត្រូវក្នុងការចាត់ចែងសហគមន៍ដោយខ្លួនឯង បន្ទាប់ពីពួកគាត់បានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រង



សហគមន៍នេសាទ ។ ពួកគាត់មានលទ្ធភាពផ្លាស់ប្តូរបទពិសោធន៍ជាមួយអ្នកដទៃ ដើម្បីចងក្រងករណីសិក្សាជាច្រើននៅក្នុងសហគមន៍នៃខេត្តផ្សេងៗទៀត ។ បច្ចុប្បន្ននេះ ប្រជាជនមានការយល់ដឹងច្រើនអំពីសារប្រយោជន៍នៃកិច្ចការពារធនធានធម្មជាតិ ។ លើសពីនេះទៀត ការបង្កើតក្រុមសន្សំដើម្បីផ្តល់ប្រាក់កម្ចីដែលមានអាត្រាការប្រាក់ទាបបានធ្វើឱ្យពួកគាត់មានជម្រើសជាច្រើនក្នុងការប្រកបមុខរបរចិញ្ចឹមជីវិតដូចជា ចិញ្ចឹម សត្វចិញ្ចឹមត្រី និងមានលទ្ធភាពទិញពូជ និងសម្ភារៈកសិកម្ម ដែលអាចធ្វើឱ្យគាត់រស់នៅបានតាមកម្រិតជីវភាពបានប្រសើរឡើង ។ ប្រភេទនៃការគាំទ្រដែលបានផ្តល់ដល់ប្រជាជនមូលដ្ឋាន គឺជាវិធីសាស្ត្រមួយក្នុងការកាត់បន្ថយភាពក្រីក្រ និងធ្វើឱ្យធនធានធម្មជាតិអាចប្រើប្រាស់បានយូរអង្វែង ។ វគ្គបណ្តុះបណ្តាលស្តីពីអំពើហឹង្សាក្នុងគ្រួសារក៏បានផ្តល់ផងដែរទៅដល់សហគមន៍ ដើម្បីធានាបាននូវការមិនរំលោភសិទ្ធិទៅលើស្ត្រី ។ ដោយសារវគ្គបណ្តុះបណ្តាលនេះហើយដែលធ្វើឱ្យស្ត្រីមានការចូលរួមយ៉ាងសកម្មនៅក្នុងកម្មវិធីឥណទាន ហើយអត្រាអំពើហឹង្សាបានថយចុះ ។ ស្ត្រីមួយចំនួនត្រូវបានលើកកំពស់តួនាទីយ៉ាងស័កសមនៅក្នុងឃុំ ។

ទោះបីសហគមន៍នេសាទបានទទួលនូវការគាំទ្រជាច្រើនពីគម្រោង និងអង្គការនានាក្តី ប៉ុន្តែនៅមានកិច្ចការជាច្រើនដែលត្រូវអនុវត្តបន្ត ដើម្បីលើកតម្កើងជីវភាពរស់នៅរបស់ប្រជាជននៅមូលដ្ឋានឱ្យកាន់តែល្អប្រសើរឡើង ថែមទៀត។ ខាងក្រោមនេះគឺជាអនុសាសន៍សម្រាប់ធ្វើបន្តនូវជំហានក្រោយ :

* ម្ចាស់ជំនួយ និងរាជរដ្ឋាភិបាលគួរតែផ្តល់ហេដ្ឋារចនាសម្ព័ន្ធទៅសហគមន៍កំពង់ក្រសាំងដូចជា ការបង្កើតទីផ្សារនៅមូលដ្ឋាន ការបង្កើតស្ថានីយ៍ឧតុនិយមដើម្បីឱ្យដឹងពីពេលវេលាជាក់លាក់នៃខ្យល់ព្យុះ ឬគ្រោះមហន្តរាយផ្សេងៗទៀត ការកសាងផ្លូវ និងប្រព័ន្ធទឹកស្អាតនៅក្នុងឃុំ
* ស្ថាប័នពាក់ព័ន្ធផ្សេងៗ និង NGOs អាចរួមគ្នាសម្របសម្រួលរៀបចំវគ្គបណ្តុះបណ្តាល ដែលទាក់ទងទៅនឹងការប្រើប្រាស់ដីគីមី ដើម្បីបង្កើនផលិតផលកសិកម្មដូចជា ការជ្រើសរើសពូជ ការចិញ្ចឹមសត្វ ការចិញ្ចឹមត្រី ការថែទាំសុខភាព និងយេនឌ័រ
* ការិយាល័យជលផលខេត្តគួរតែបន្តធ្វើការជាមួយគ្នាអំពីការជួយកម្មវិធីឥណទានខ្នាតតូចដល់ប្រជាជននៅក្នុងសហគមន៍កំពង់ក្រសាំងឱ្យកាន់តែបានដល់សមាជិកជាច្រើននៅក្នុងសហគមន៍
* អ្នកដឹកនាំ និងសមាជិកសហគមន៍នេសាទគួរខិតខំធ្វើការ និងគួរមានឆន្ទៈក្នុងការគ្រប់គ្រងការងារសហគមន៍ដើម្បីទទួលនូវភាពជោគជ័យ ពីព្រោះម្ចាស់ជំនួយអាចផ្តល់ថវិកា និងជំនួយបច្ចេកទេសតែប៉ុណ្ណោះ ប៉ុន្តែការប្តេជ្ញាចិត្ត និងឆន្ទៈរបស់ប្រជាជនជារឿងសំខាន់ ។

# REFERENCE


* Report Statistics of population Kompong Krosing ( 2005 -2006 )
* Report Credit of CFDO ( September 2005 ) ( CFDO / FiA )
* Jacobson and Visakay, 2001
* Report on Regulation of Community Fishery in Kompong Krosing ( March 2005) ( CFDO / FiA )
* Report activities Takeo Provincial Fishery office (2005 ) ( CFDO / FiA )
* Report result of the Scoping activities in Kompong Krosing CF ( March 2006 ) ( CFDO / FiA )





# កិច្ចសហប្រតិបត្តិការណ៍របស់អ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព



# កិច្ចសហប្រតិបត្តិការណ៍របស់អ្នកពាក់ព័ន្ធក្នុងការគ្រប់គ្រងធនធានជលផល ប្រកបដោយនិរន្តរភាព

ករណីសិក្សា នៅសហគមន៍នេសាទភ្នៀត-កោះពងសត្វ ឃុំភ្នៀត និងកោះពងសត្វ ស្រុកសិរីសោភ័ណ ខេត្តបន្ទាយមានជ័យ


**រៀបរៀង និង ស្រាវជ្រាវដោយ**

លោក ជាម ប៉េអា, អ្នកដឹកនាំគម្រោង

លោក រុន វិសិទ្ធិ, មន្ត្រីជលផលខេត្តបន្ទាយមានជ័យ

កញ្ញា យិន គឹមសួរ, បុគ្គលិកអង្គការក្រុមទ្រទ្រង់ភូមិ

លោក ស៊ុក រិន, មន្ត្រីការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ

លោក នូវ លាង, មន្ត្រីជលផលខេត្តបន្ទាយមានជ័យ



**ពត៌មានចម្បង:** កិច្ចសហប្រតិបត្តិការរបស់អ្នកពាក់ព័ន្ធនៃសហគមន៍នេសាទភ្នៀត កោះពងសត្វ ក្នុងការគ្រប់គ្រងធនធានជលផលប្រកបដោយចេរភាព


## ១. សេចក្តីផ្តើម

សហគមន៍នេសាទភ្នៀតកោះពងសត្វជាអតីតឡូត៍នេសាទលេខ០៤ស្ថិតនៅតាមដងស្ទឹងសិរីសោភ័ណខេត្តបន្ទាយមានជ័យលាតសន្ធឹងពីចំណុចតាទង់ទៅដល់អន្លង់តាស្រី (បច្ចុប្បន្នបានប្តូរទៅកន្លែងអន្លង់សង្កែវិញ) ។ សហគមន៍នេសាទនេះស្ថិតនៅក្នុងឃុំពីរ គឺឃុំភ្នៀតដែលមានចំនួន៦ភូមិ និងឃុំកោះពងសត្វមានចំនួន៥ភូមិ ។ សហគមន៍នេសាទភ្នៀតកោះពងសត្វមានផ្ទៃដីសរុបចំនួន ៣.៩៦៤,២៣ហិកតា ក្នុងនោះផ្ទៃដីកសិកម្មមានចំនួន៣.៤៤២ហិកតា ស្មើ៨៧% នៃផ្ទៃដីសរុប និងដីលំនៅដ្ឋានចំនួន ៥២២,២៣ហិកតាស្មើ១៣% នៃផ្ទៃដីសរុប ។ កន្លែងនេសាទរបស់សហគមន៍រួមមានបឹងចំនួន៦៣ ព្រែក១៣ ស្រះ៩ និងស្ទឹងប្រវែង១៨គីឡូម៉ែត្រ ដែលមានត្រី វារីរុក្ខជាតិ វារីសត្វ និងព្រៃលិចទឹក ពិសេសទៅទៀតនោះជាតំបន់លិចទឹកនៅរដូវវស្សា ។ សហគមន៍នេសាទភ្នៀត-កោះពងសត្វមានអន្លង់អភិរក្សចំនួន ៥ កន្លែង រួមមាន អន្លង់កន្ទួត ដូនឥដ្ឋ វត្តកោះពងសត្វ ភ្នៀត និងស្រះវត្តអង្គាបុស្ស ។ អន្លង់អភិរក្សនេះ គឺមានជម្រៅជ្រៅបំផុតពី ៧-១០ ម៉ែត្រ នៅរដូវវស្សា និង ១,៥-២ ម៉ែត្រ នៅរដូវប្រាំង ។ ជម្រៅទឹកនេះអាចធានាបាននូវការរស់នៅរបស់ត្រីគ្រប់ប្រភេទ ជាពិសេសនៅរដូវប្រាំង ។



សហគមន៍នេសាទនេះត្រូវបានបង្កើតឡើងនៅឆ្នាំ ២០០១ បន្ទាប់ពីរាជរដ្ឋាភិបាលបានធ្វើការកំណែទម្រង់វិស័យជលផលដោយបានលុប និងកាត់បន្ថយនាទីឡូត៍នេសាទប្រមាណ ៥៣៨.៥៥២ ហិកតា នៅទូទាំងប្រទេស ដើម្បីប្រគល់ជូនប្រជាជននៅតាមមូលដ្ឋានចូលរួមគ្រប់គ្រងធនធានជលផល តាមរយៈការរៀបចំសហគមន៍នេសាទ ។ ប្រជាជនសរុបនៅក្នុងឃុំទាំង ២ នេះមានចំនួន ១.៥៤០ គ្រួសារ ប៉ុន្តែមានប្រជាជនតែ ១.០៥០ គ្រួសារ (ស្មើនឹង ៦៨%) ប៉ុណ្ណោះដែលបានចូលជាសមាជិកសហគមន៍នេសាទ (រូបភាពទី ៥) ។

ស្ថានភាពផ្ទះសម្បែងនៅក្នុងសហគមន៍នេះមាន: ផ្ទះប្រក់សង្កសី ឬហ្វីបប្រូស៊ីម៉ង់ ៤៥% ផ្ទះស្លឹក ៣៥% និងផ្ទះប្រក់ក្បឿង ២០%។ ប្រជាជនភាគច្រើនពុំមានអណ្តូងទឹកទេ ដូច្នេះពួកគាត់ប្រើប្រាស់ទឹកស្ទឹង បឹង ឬស្រះសំរាប់បោកគក់ងូតទឹក និងចំអិនម្ហូបអាហារប្រចាំថ្ងៃ ។ ប្រជាជនប្រើប្រាស់អាគុយក្នុងការបំភ្លឺទូរទស្សន៍និងវិទ្យុហើយប្រជាជនដែលក្រីក្រប្រើប្រាស់ចង្កៀងប្រេងកាត ។ ជាទូទៅ ប្រជាជននៅក្នុងសហគមន៍នេសាទភ្លៀតកោះពងសត្វប្រើប្រាស់អុសក្នុងការចំអិនម្ហូបអាហារ ។ ចំពោះផ្នែកសិក្សាអប់រំនៅក្នុងសហគមន៍នេសាទនេះមានសាលាបឋមសិក្សា១កន្លែងដែលមាន៤៨បន្ទប់ និងអនុវិទ្យាល័យ១កន្លែងមាន២បន្ទប់ ។ ផ្នែកសុខភាពមានមណ្ឌលសុខភាព១កន្លែងដែលមានមន្ត្រីសុខាភិបាល៩នាក់ ឆ្មបបុរាណ១២នាក់ និងគិលានុបដ្ឋាយិការ៦នាក់ បម្រើការងារនៅក្នុងមណ្ឌលសុខភាពនេះ ។ ក្រៅពីមន្ត្រីសុខាភិបាលទាំងនេះមានពេទ្យបុរាណ១៤នាក់ សម្រាប់ជួយផ្តល់សេវាថែទាំ និងព្យាបាលសុខភាពដល់ប្រជាជននៅក្នុងឃុំ ។

ការប្រកបមុខរបរចិញ្ចឹមជីវិតសំខាន់ៗរបស់ប្រជាជននៅក្នុងសហគមន៍នេសាទនេះ គឺធ្វើនេសាទ និងធ្វើស្រែចំការ។ អ្នកនេសាទមានចំនួន១.៦៨៥នាក់ក្នុងនោះអ្នកនេសាទជាប្រចាំចំនួន៨៥% និងនេសាទម្តងម្កាល៥%ក្នុងនោះមានស្ត្រីចំនួន១០%។ ការប្រើប្រាស់ឧបករណ៍ក្នុងតំបន់នេះមានសំណាញ់ មង សន្ទូច សម្រាស់ លប និងលាន់ ។ ប្រភេទត្រីដែលយើងចាប់បានមានត្រីរ៉ស់ ត្រីអណ្តែង Bronze feather back, and Mimic threadfin ។ ផលនេសាទចាប់បានជាមធ្យមមិនច្រើនជាង៣គីឡូក្រាមក្នុង១នាក់ក្នុង១ថ្ងៃនៅរដូវវស្សា និង១,៥គីឡូក្រាមក្នុង១នាក់ក្នុង១ថ្ងៃនៅរដូវប្រាំង ។ អ្នកនេសាទបាននាំផលិតផលទាំងនោះទៅលក់នៅផ្សារមង្គលបូរី និងសិរីសោភ័ណ ។ ត្រីរ៉ស់មានតម្លៃ៣.៥០០ រៀលក្នុង១គីឡូក្រាម ខណៈពេលដែលត្រីសមានតមៃ១.២០០ រៀលក្នុង ១គីឡូក្រាម (ក្នុងខែ មិនា ឆ្នាំ ២០០៤) ។ ការនេសាទបានធ្វើពេញ១ឆ្នាំ ប៉ុន្តែរដូវដែលធ្វើនេសាទខ្លាំងពីខែមិថុនាដល់ធ្នូ ។ មុនការបង្កើតសហគមន៍នេសាទ សកម្មភាពនេសាទល្មើសច្បាប់មានដូចជាការប្រើប្រាស់ឧបករណ៍ឆក់ អួនក្រឡាតូច និង ការដាក់សម្រាស់ ប៉ុន្តែបច្ចុប្បន្ននេះការនេសាទល្មើសច្បាប់ទាំងនោះត្រូវបានកាត់បន្ថយមួយចំនួនធំ។

ប្រជាជនអាចធ្វើស្រែបានពេញ ១ ឆ្នាំ ហើយក៏អាចដាំដំណាំរួមផ្សំមួយចំនួនដូចជា ពោត និងបន្លែផងដែរ ។ មុនពេលបង្កើតសហគមន៍នេសាទមានការកាប់រានព្រៃលិចទឹកដើម្បីធ្វើស្រែប្រាំងដែលមានរយៈពេល៥ខែ ក្នុង១ឆ្នាំ និងបូមទឹក



ពីស្ទឹងបញ្ចូលក្នុងស្រែដែលធ្វើឱ្យទឹកស្ទឹងរីងរាក់នៅរដូវប្រាំងប៉ុន្តែចាប់តាំងពីសហគមន៍នេះត្រូវបានបង្កើតឡើងសកម្មភាពធ្វើស្រែចំការនោះត្រូវបានទប់ស្កាត់ជាបណ្តើរៗដោយសហគមន៍នេសាទ និងអាជ្ញាធរមូលដ្ឋាន ។

ប្រជាជនមូលដ្ឋាន ជាពិសេសសមាជិកសហគមន៍នេសាទបានចូលរួមយ៉ាងកុះករនៅក្នុងសកម្មភាពការងារសហគមន៍នេសាទជាច្រើនដូចជាការទប់ស្កាត់បទល្មើស និងការពារអន្លង់អភិរក្សជាដើម ។ ពួកគេក៏បានចូលរួមផងដែរនូវការប្រជុំនិងការពិភាក្សាបញ្ហាផ្សេងៗ ស្តីអំពីការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ ។ សមាជិកភាគច្រើនក៏បានចូលរួមក្នុងការផ្សព្វផ្សាយដល់ប្រជាជនក្នុងមូលដ្ឋានដូចជា ច្បាប់ជលផល និងលិខិតបទដ្ឋាននានា រួមទាំងតួនាទី និងការទទួលខុសត្រូវរបស់សហគមន៍នេសាទផងដែរ ។

កិច្ចសហប្រតិបត្តិការរបស់អ្នកពាក់ព័ន្ធមានចារិកលក្ខណៈប្លែកៗគ្នា នៅក្នុងសហគមន៍នេសាទភ្លៀត–កោះពងសត្វ ជាពិសេសអាជ្ញាធរមូលដ្ឋានបានចូលរួមយ៉ាងសកម្មជាមួយសមាជិកសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធផ្សេងៗទៀតក្នុងការជួយសម្របសម្រួលក្នុងដំណើរគ្រប់គ្រងសហគមន៍នេសាទ ។ ដូច្នេះគោលបំណងនៃករណីសិក្សានេះ គឺផ្តោតទៅលើកិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធទាំងអស់នៅក្នុងដំណើរការគ្រប់គ្រងសហគមន៍នេសាទភ្លៀត–កោះពងសត្វ ជាពិសេសគឺដើម្បីរកឱ្យឃើញស្ថាប័នពាក់ព័ន្ធ តួនាទីរបស់ពួកគេ និងស្វែងយល់អំពីបទពិសោធន៍នានានៃកិច្ចសហការក្នុងការងារគ្រប់គ្រងធនធានជលផល ។ ករណីសិក្សានេះក៏បង្ហាញឱ្យឃើញផងដែរអំពីអ្នកពាក់ព័ន្ធដោយផ្ទាល់ ឬ ដោយប្រយោល និងការទទួលខុសត្រូវរបស់ពួកគេក្នុងការគ្រប់គ្រងសហគមន៍នេសាទ ព្រមទាំងផ្តល់នូវទស្សនៈយ៉ាងស៊ីជម្រៅនៃចំនុចខ្លាំងរបស់អ្នកពាក់ព័ន្ធក្នុងការចូលរួមគ្រប់គ្រងសហគមន៍នេសាទភ្លៀត–កោះពងសត្វ ។

# ២. ភាគីពាក់ព័ន្ធនៅក្នុងដំណើរការសហគមន៍នេសាទ

## ២.១. ភាគីពាក់ព័ន្ធ

ឧបករណ៍វែនដ្យាក្រាមនៃវិធីសាស្ត្រត្រូវបានប្រើនៅក្នុងករណីសិក្សានេះសម្រាប់ធ្វើការវិភាគអំពីភាគីពាក់ព័ន្ធ ហើយក្នុងនោះលទ្ធផលដែលទទួលបានគឺមានបង្ហាញដូចក្នុងគំនូសបំព្រួយខាងក្រោម ។នៅក្នុងគំនូសបំព្រួញនេះបង្ហាញអំពីតំណាងរបស់អង្គភាពនីមួយៗនិងទំនាក់ទំនងរវាងអង្គភាពនីមួយៗជាមួយគ្នាដែលមានគំនូសព្រួញជាសញ្ញាបញ្ជាក់ ក្នុងនោះសញ្ញាព្រួញដែលគូសដាច់ៗសំគាល់ថា មានទំនាក់ទំនងគ្នាម្តងម្កាល និង គំនូសព្រួញដែលគូសជាប់សំគាល់ថា មានទំនាក់ទំនងញឹកញាប់។ (គំនូសបំព្រួញទី១ : ទំនាក់ទំនងរបស់អ្នកពាក់ព័ន្ធនៃសហគមន៍ភ្លៀត–កោះពងសត្វ) ។

## គំនូសបំព្រួញ ៦: បណ្តាអ្នកពាក់ព័ន្ធនៅក្នុងសហគមន៍នេសាទភ្សៀត-កោះពងសត្វ




### ២.២. តួនាទី និង ភារៈកិច្ចរបស់អ្នកពាក់ព័ន្ធក្នុងកិច្ចសហការណ៍

អ្នកពាក់ព័ន្ធនៅក្នុងសហគមន៍នេសាទភ្សៀត-កោះពងសត្វ មានពីរប្រភេទគឺ អ្នកពាក់ព័ន្ធដោយផ្ទាល់ និងអ្នកពាក់ព័ន្ធដោយប្រយោល។ អ្នកពាក់ព័ន្ធទាំងនេះ មានតួនាទី និង ការទទួលខុសត្រូវដូចខាងក្រោម:

### ២.២.១. អ្នកពាក់ព័ន្ធដោយផ្ទាល់

**អ្នកភូមិ និង សមាជិកសហគមន៍នេសាទ:** បានតាមដាន និងរាយការណ៍ពីសកម្មភាពបទល្មើសនេសាទចូលរួមផ្សព្វផ្សាយលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទសហការជាមួយស្ថាប័នដែលទទួលខុសត្រូវដើម្បីជួយទប់ស្កាត់បទល្មើសនេសាទ និងចូលរួមក្នុងកិច្ចការអភិវឌ្ឍន៍របស់សហគមន៍ ។



**អាជ្ញាធរភូមិ :** បានទទួលស្គាល់ និងប្រតិបត្តិតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ ។ ជាមួយគ្នានេះផងដែរ ពួកគាត់ក៏បានចូលរួមយាមល្បាតនៅកន្លែងអន្លង់អភិរក្ស និងកន្លែងនេសាទសហគមន៍ដើម្បីទប់ស្កាត់នេសាទខុសច្បាប់ ជាពិសេស ពួកគាត់បានចូលរួមប្រជុំប្រចាំត្រីមាស ឆមាស ប្រចាំឆ្នាំ និងជាសមាជិកក្រុមជួយខ្លួនឯងលើការវិនិយោគឥណទានខ្នាតតូច ហើយក៏ជាទីប្រឹក្សាពិគ្រោះយោបល់រាល់ការងាររបស់សហគមន៍នេសាទផងដែរ ។

**រដ្ឋបាលឃុំ :** សហការចុះល្បាតកន្លែងអភិរក្ស និងកន្លែងនេសាទសហគមន៍ ជួយផ្សព្វផ្សាយឯកសារពាក់ព័ន្ធសហគមន៍នេសាទ ជាទីប្រឹក្សារបស់សហគមន៍នេសាទ រៀបចំប្រជុំប្រចាំខែគណៈបញ្ជាការកងឯកភាពឃុំ ជួយជម្រុញនូវសកម្មភាពអភិវឌ្ឍន៍សហគមន៍នេសាទចូលរួមសហការរៀបចំការបណ្តុះបណ្តាលដល់អនុគណៈកម្មការ និងគណៈកម្មការសហគមន៍នេសាទហើយជួយធ្វើកំណត់ហេតុ និងកិច្ចសន្យាបទល្មើសនេសាទ ។

**ប៉ូលីស :** ជួយផ្សព្វផ្សាយអនុវត្តលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងអន្តរាគមន៍ទប់ស្កាត់បទល្មើសនេសាទសហការចុះល្បាតតំបន់អភិរក្ស (ពីរទៅបីថ្ងៃម្តង) និងជួយធ្វើកំណត់ហេតុនិងកិច្ចសន្យាបទល្មើសនេសាទ ។

**ក្រុមប្រឹក្សាឃុំ :** ប្រជុំអនុម័តកម្មវិធីអភិវឌ្ឍន៍នានារបស់សហគមន៍នេសាទដូចជា កម្មវិធីឥណទាន អនុម័តគាំទ្ររចនាសម្ព័ន្ធគ្រប់គ្រងសហគមន៍នេសាទ និងចូលរួមរៀបចំមហាសន្និបាតសហគមន៍ ។

**ការិយាល័យជលផលខេត្ត :** ផ្តល់បច្ចេកទេសក្នុងការរៀបចំសហគមន៍នេសាទជួយសម្របសម្រួលរៀបចំសេចក្តីព្រាងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហការបង្រ្កាបបទល្មើសជលផល ជួយស្វែងរកអង្គការដែលជាដៃគូដើម្បីគាំទ្រលើគម្រោងអភិវឌ្ឍន៍សហគមន៍នេសាទជួយបណ្តុះបណ្តាលគណៈកម្មការ អនុគណៈកម្មការរៀបចំដំណើរការទស្សនៈកិច្ចសិក្សាក្រៅខេត្ត ជួយសម្របសម្រួលរៀបចំផែនការគ្រប់គ្រង និងអភិវឌ្ឍន៍សហគមន៍នេសាទ គាំទ្របង្កើតតំបន់អភិរក្ស ជួយរៀបចំកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ និងជួយដោះទំនាស់នានាដែលកើតមាននៅក្នុងសហគមន៍ ។

**ព្រះសង្ឃ :** ជួយការពារកន្លែងអន្លង់អភិរក្ស ផ្សព្វផ្សាយដល់ពុទ្ធបរិស័ទចំណុះជើងវត្តក្នុង និងក្រៅពិធីបុណ្យផ្សេងៗ ជួយផ្សព្វផ្សាយលក្ខន្តិកៈសហគមន៍នេសាទ និងផ្តល់ទីកន្លែងសំរាប់សហគមន៍នេសាទប្រជុំ និងបណ្តុះបណ្តាល ។

**គម្រោង IDRC :** ជួយសិក្សាស្រាវជ្រាវពីតំរូវការរបស់សហគមន៍នេសាទ រៀបចំផែនទីសហគមន៍នេសាទបណ្តុះបណ្តាលជំនាញបច្ចេកទេស រៀបចំដំណើរទស្សនៈកិច្ចសិក្សាក្រៅខេត្ត សម្របសម្រួលធ្វើផែនការរៀបចំសិក្ខាសាលាចែករំលែកបទពិសោធន៍ រៀបចំបង្កើតតំបន់អភិរក្ស (ស្លាកសញ្ញា និងក្តារព័ត៌មាន) បង្កើតក្រុមជួយខ្លួនឯងចំនួន ៦០ គ្រួសារដែលបែងចែកជា ១២ ក្រុម ដើម្បីគ្រប់គ្រងថវិកាដែលគម្រោងបានផ្តល់អោយជាថវិកា ឥណទានកម្ចីខ្នាតតូចដែលមានទឹកប្រាក់សរុបចំនួន ៣.០០០ ដុល្លា និងតាមដាន និងត្រួតពិនិត្យដំណើរការកម្មវិធីឥណទាន សម្របសម្រួលកិច្ចប្រជុំគណៈកម្មការ និងអនុគណៈកម្មការប្រចាំត្រីមាស និងប្រចាំឆ្នាំ រៀបចំសេចក្តីព្រាងលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ សេចក្តីព្រាងផែនការគ្រប់គ្រង សេចក្តីព្រាងកិច្ចព្រមព្រៀង ចុះឈ្មោះសមាជិកសហគមន៍ និងជួយរៀបចំការបោះឆ្នោតជ្រើសរើសគណៈកម្មការគ្រប់គ្រងសហគមន៍នេសាទ ។

### ២.២.២.អ្នកពាក់ព័ន្ធដោយប្រយោល

**អាជ្ញាធរស្រុក:** ជួយផ្តល់កំលាំងជំនួយគាំទ្រក្នុងការទប់ស្កាត់បទល្មើសនេសាទសហការក្នុងការចុះកំណត់ព្រំប្រទល់កន្លែងនេសាទសហគមន៍ និងជួយផ្តល់ពត៌មានថ្មីៗដែលទាក់ទងនិងសហគមន៍នេសាទ ។

**មន្ទីរបរិស្ថាន:** ជួយផ្សព្វផ្សាយតាមរយៈវិទ្យុ និងប្រជុំថ្នាក់ឃុំដើម្បីណែនាំអំពីផលវិបាកនៃការកាប់ព្រៃលិចទឹក ការប្រើជីគីមី និងថ្នាំគីមី នៅក្នុងការងារកសិកម្មជិតដែននេសាទសហគមន៍នេសា និងជួយផ្សព្វផ្សាយអំពីវិធានការទប់ស្កាត់ការបង្ហូរកាកសំណល់ចូលទៅក្នុងស្ទឹង ។

**គ្រូបង្រៀន:** ជួយផ្សព្វផ្សាយពីលក្ខន្តិកៈសហគមន៍នេសាទ ប្រកាសលេខ ០២ របស់រាជរដ្ឋាភិបាល អនុក្រិត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទដល់សិស្ស និងចូលរួមប្រជុំប្រចាំខែជាមួយកងឯកភាពឃុំដើម្បីផ្តល់យោបល់នានាពាក់ព័ន្ធនឹងការអភិវឌ្ឍន៍មូលដ្ឋាន ជាពិសេសពាក់ព័ន្ធនឹងការគ្រប់គ្រងសហគមន៍នេសាទ ។



ក្រុមសហគមន៍នេសាទពិភាក្សាជាមួយក្រុមប្រឹក្សាឃុំ
(រូបថតភាពដោយៈ ក្រុមបន្ទាយមានជ័យ, ២០០៦)

**មណ្ឌលសុខភាព:** ផ្តល់ការព្យាបាលជម្ងឺ ការថែទាំសុខភាពដល់សមាជិកសហគមន៍នេសាទ និងជួយផ្សព្វផ្សាយព័ត៌មានពាក់ព័ន្ធនឹងសហគមន៍នេសាទ ។

**មន្ទីរកសិកម្ម:** សហការតាមរយៈការិយាល័យជលផល និងលើកទឹកចិត្តពីស្នាដៃដែលអនុវត្តបាន (ទទួលបានមេដៃប្រាក់) ។

**សហគមន៍ភូមិ:** ជួយផ្តល់ថវិកាកម្ចីតាមរយៈមេភូមិដល់សមាជិកសហគមន៍នេសាទដែលជួបការលំបាកនិងជួយផ្សព្វផ្សាយពីលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុង ។

**UNDP:** ជួយតាមរយៈការិយាល័យជលផលក្នុងការបណ្តុះបណ្តាលសមាជិកគណៈកម្មការ២នាក់ ។

**VSG:** ជួយតាមរយៈការិយាល័យជលផលក្នុងការពង្រឹងសមត្ថភាព និងបណ្តាញប្រជានេសាទ ។

## ២.៣. សកម្មភាព និងលទ្ធផលនៃកិច្ចសហការរបស់អ្នកពាក់ព័ន្ធនៅក្នុងសហគមន៍នេសាទ

ដៃគូយ៉ាងសំខាន់នៃសហគមន៍នេសាទភ្លៀត-កោះពងសត្វ គឺអាជ្ញាធរមូលដ្ឋាន ការិយាល័យជលផលខេត្ត និងព្រះសង្ឃនៅក្នុងឃុំ ។ អ្នកពាក់ព័ន្ធទាំងនេះ គឺចូលរួមយ៉ាងសកម្មនៅក្នុងការឃ្លាំមើល និងការពារទប់ស្កាត់បទល្មើសនេសាទទាំងនៅក្នុងតំបន់អភិរក្ស និងដែននេសាទសហគមន៍ ។ ក្រៅពីនេះអ្នកពាក់ព័ន្ធដោយផ្ទាល់ក៏ដើរតួនាទីយ៉ាងសកម្មក្នុងការ



សម្រសម្រួលបង្កើតលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងផែនទី ផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀងរបស់សហគមន៍នេសាទដោយផ្តល់នូវតម្លៃនៃការគ្រប់គ្រងវិស័យជលផលជាមួយដៃគូសំខាន់ៗសម្រាប់ស្វែងរកការគាំទ្រសហគមន៍នេសាទ ។ ដោយឡែកការគាំទ្រពីប៉ូលីស គឺវាមានសារៈសំខាន់ណាស់ដើម្បីបញ្ឈប់នូវសកម្មភាពនេសាទល្មើសច្បាប់ ពីព្រោះពួកគេគឺជាអាជ្ញាធរស្របច្បាប់មួយដែលកំពត់ក្នុងការឃុំឃាំងបុគ្គលណាម្នាក់ ។ គម្រោង IDRC បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការផ្តល់នូវថវិកា និងជំនួយបច្ចេកទេសដល់សហគមន៍នេសាទ ។

ចំពោះអ្នកពាក់ព័ន្ធដោយប្រយោលរួមមានមណ្ឌលសុខភាព គ្រូបឋមសិក្សា សហគមន៍ភូមិ មន្ទីរបរិស្ថាន ក្រុមប្រឹក្សាឃុំ អាជ្ញាធរស្រុក និងមន្ទីរកសិកម្មខេត្តកន្លងមកបានចូលរួមជម្រុញនិងលើកទឹកចិត្ត ហើយនិងផ្សព្វផ្សាយបន្តរបស់សហគមន៍ នេសាទឱ្យមានដំណើរការល្អ ។

លោក មួង ហៃន អនុប្រធានគណៈកម្មការគ្រប់គ្រងសហគមន៍នេសាទ វៀតកោះ-ពងសត្វបានឱ្យដឹងថា ក្រៅពីការងារទប់ស្កាត់បទល្មើសនៅក្នុងសហគមន៍មានសមិទ្ធិផលជាច្រើនផ្សេងទៀត ដែលកើតឡើងដោយការជួយឧបត្ថម្ភគាំទ្រ និងកិច្ចសហការល្អដូចជា ការបង្កើតអន្លង់អភិរក្ស ០៥ កន្លែង ការបង្កើតក្រុមជួយខ្លួនឯង ១២ ក្រុម ដើម្បីទទួលឥណទានខ្នាតតូចពីគម្រោង IDRC ចំនួន ៣.០០០ ដុល្លា និងវគ្គបណ្តុះបណ្តាលដល់គណៈកម្មការសហគមន៍នេសាទ និងអនុគណៈកម្មការសហគមន៍នេសាទទាំង៥៥រូបដែលធ្វើឱ្យសមត្ថភាពគ្រប់គ្រងរបស់គណៈកម្មទាំងអស់មានការកើនឡើង ។
២០០៦

កិច្ចសហប្រតិបត្តិការរបស់សហគមន៍នេសាទ និងអ្នកពាក់ព័ន្ធដោយផ្ទាល់ក្តី ឬ ដោយប្រយោលក្តីបាននាំមកនូវអត្ថប្រយោជន៍យ៉ាងច្រើនដល់សមាជិកសហគមន៍នេសាទដូចជា ការរក្សាបាននូវភាពគង់វង្សនូវព្រៃលិចទឹកផលនេសាទកើនឡើងវិញនៅក្នុងកន្លែងនេសាទសហគមន៍ និងជីវភាពរស់នៅរបស់សមាជិកសហគមន៍នេសាទឱ្យមានភាពល្អប្រសើរឡើងជាបណ្តើរៗ ។ ជាឧទាហរណ៍ យោងតាមការអង្កេតក្នុងចំណោមអ្នកភូមិទាំងនោះ ជាពិសេសលោកប៊ុនអាត ប្រធានក្រុមប្រឹក្សាឃុំកោះពងសត្វបានបញ្ជាក់ថា ប្រជាជនដែលរស់នៅក្នុងសហគមន៍នេះបានប្រើប្រាស់ទឹកស្អិតស៊ីវិសោភ័ណមានភាពថ្លាដែលបន្ថយបាននូវជំងឺគាំងនោម ។ ដោយពេលមុនមានអ្នកជំងឺពី ៥០ ទៅ ៦០នាក់ដែលបានកើតជំងឺនេះ ហើយសព្វថ្ងៃនេះមានតែ ១០ នាក់ ប៉ុណ្ណោះ ដែលកើតមានជំងឺនេះ ។

## ៣. ការចូលរួមរបស់ស្ត្រីក្នុងការគ្រប់គ្រងធនធានជលផល

### ៣.១. លក្ខណៈសម្បត្តិរបស់ស្ត្រី

ស្ត្រីជាមាតាពិភពលោក ហើយក៏ជាអ្នកចាត់ចែងចម្បងក្នុងគម្រោងការងាររបស់អង្គភាព ស្ថាប័ន ឬសង្គមគ្រួសារ។ តាមទំលាប់របស់សង្គមខ្មែរតាំងពីយូរយារមកការហៅឈ្មោះតួនាទីអ្នកដឹកនាំថ្នាក់ភូមិ ឃុំ និងស្រុកឬក្នុងគ្រួសារថាជាមេភូមិ មេឃុំ មេស្រុក ឬ មេគ្រួសារបានក្លាយជាពាក្យប្រើប្រាស់ជាផ្លូវការរហូតមកដល់បច្ចុប្បន្ន នៅសហគមន៍នេសាទភ្លៀត-កោះពងសត្វ ។ នៅឆ្នាំ ២០០១ សមាជិកសហគមន៍នេសាទប្រមាណជាង ១.០០០ នាក់បានបោះឆ្នោតផ្តល់នូវការទុកចិត្តជ្រើសរើសស្ត្រីជាប្រធានសហគមន៍នេសាទតួយ៉ាងដូចជាអ្នកស្រី តាន់ គីមគួយ ។ គាត់ គឺជាពេទ្យឈ្នួលដែលបំរើសេវាសុខភាព និងជាសមាជិកល្អម្នាក់ក្នុងសហគមន៍នេសាទ ។


សហគមន៍នេសាទបានទទួលមេឌាយប្រាក់ពីសម្តេចនាយករដ្ឋមន្ត្រី កាលពីឆ្នាំ ២០០៤

ជាកិត្តិយសខ្លាំងណាស់ដែលគាត់មានសេចក្តីក្លាហានក្នុងការនិយាយស្តី និងមានសទ្ធាចិត្តក្នុងការជួយបំរើការងារសហគមន៍នេសាទឱ្យសមាជិកសហគមន៍នេសាទបោះឆ្នោតឱ្យគាត់ជាប់ជាប្រធានសហគមន៍នេសាទ ។ តួយ៉ាងដូចជាលោកគួន គុច សមាជិកក្រុមប្រឹក្សាឃុំកោះពងសត្វបានផ្តល់យោបល់អំពីគុណសម្បត្តិមួយចំនួនរបស់គាត់រួមមាន: ការជាប់ឆ្នោតរបស់គាត់ គឺស្របតាមគោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលចំពោះស្ត្រីក្នុងសហគមន៍នេសាទ ការគ្រប់គ្រងរបស់សហគមន៍នេសាទបានដំណើរការយ៉ាងល្អប្រសើរស្ថិតក្រោមភាពដឹកនាំរបស់ស្ត្រីនិងសហគមន៍នេសាទនេះបានទទួលស្គាល់ដោយរាជរដ្ឋាភិបាលនិងមហាជន ។ ហើយលោកស្រីតាន់ គីមគួយ ក៏បានទទួលស្គាល់ផងដែរថាជាស្ត្រីដែលមានស្នាដៃល្អប្រសើរណាស់ក្នុងការដឹកនាំការងារសហគមន៍នេសាទ ។ ទោះបីជាមានបញ្ហាពិបាកចំពោះមុខមួយចំនួនដែលស្ត្រីបានជួបប្រទះក្នុងភាពជាអ្នកដឹកនាំដូចជាស្ត្រីមិនអាចចុះយាមល្បាតពិសេសនៅពេលយប់មិនអាចចូលរួមប្រជុំទៀតទាត់ និងពិបាកធ្វើដំណើរទៅឆ្ងាយពីផ្ទះ ឬ ទៅខាងក្រៅសហគមន៍នេសាទជាដើម ។

ថ្មីៗនេះមន្ទីរកសិកម្មខេត្តបន្ទាយមានជ័យបានវាយតម្លៃខ្ពស់ចំពោះសហគមន៍នេសាទភ្លៀត-កោះពងសត្វ ដែលទទួលបានមេដៃប្រាក់ជាកិត្តិយសផ្ទាល់ពីសម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានៅក្នុងឆ្នាំ២០០៤។ នេះជាប្រសាសន៍លោកស្រី តាន់ គីមគួយ ប្រធានសហព័ន្ធ សហគមន៍ភ្លៀត-កោះពងសត្វឆ្នាំ ២០០៦ ។



## ៣.២. សកម្មភាពនានាដែលស្ត្រីបានចូលរួមកន្លងមក

នៅក្នុងសហគមន៍នេសាទភៀត–កោះពងសត្វ ស្ត្រីក៏មានសកម្មភាពចូលរួមដូចបុរសដែរ នៅក្នុងដំណើរការគ្រប់គ្រងសហគមន៍នេសាទដែលសកម្មភាពទាំងនោះមានដូចជា:

- ☆ **ការប្រជុំ:** ដោយសារការគាំទ្រពីសមាជិកសហគមន៍ទើបបានផ្តល់ឱកាសឱ្យលោកស្រីតាន គីមគួយ ក្នុងការដឹកនាំប្រជុំសហគមន៍រាងរាល់៣ខែម្តង ។ ការប្រជុំនេះភាគច្រើនសម្របសម្រួលបានជោគជ័យទៅតាមរបៀបវារៈដែលបានគ្រោងទុក ។
- ☆ **ការផ្សព្វផ្សាយ:** ការផ្សព្វផ្សាយ គឺជាមធ្យោបាយមួយជួយដាស់អារម្មណ៍ដល់ជនទាំងឡាយណាដែលពុំសូវយល់ធ្វើឱ្យមានការចាប់អារម្មណ៍ឡើងវិញហើយការផ្សព្វផ្សាយបានល្អទូលំទូលាយចាំបាច់ត្រូវមានការចូលរួមពីស្ថាប័នផ្សេងៗ ។ តាមបទពិសោធន៍កន្លងមកការផ្សព្វផ្សាយពីសហគមន៍នេសាទស្តីពីលក្ខន្តិកៈបទបញ្ជាផ្ទៃក្នុងអនុក្រឹត្យសហគមន៍នេសាទ និងច្បាប់ជលផលនៅក្នុងសហគមន៍នេសាទភៀត–កោះពងសត្វក្នុង ១ឆ្នាំមានសមាជិកសហគមន៍ចូលរួមយ៉ាងតិចពីរលើកដែលមួយលើកមានចំនួនពី ២០០ ទៅ ៣០០ នាក់ ។ លទ្ធផលនេះក៏បានមកពីការសហការគ្នាល្អជាមួយស្ថាប័នជំនាញអាជ្ញាធរដែនដី និងព្រះសង្ឃ ។
- ☆ **ការធ្វើផែនការអភិវឌ្ឍន៍សហគមន៍នេសាទ:** ដោយសារមានការជួយសម្របសម្រួលពីការិយាល័យជលផល និង IDRC សហគមន៍នេសាទនេះបានសិក្សាអំពីតម្រូវការ និងបានបង្កើតផែនការប្រចាំឆ្នាំនិងផែនការ៣ឆ្នាំសំរាប់ស្វែងរកថវិកាគាំទ្រ ។

លោក យិន យីន សមាជិកគណៈកម្មការសហគមន៍នេសាទបានអះអាងថាកន្លងមកអ្នកស្រីប្រធានសហគមន៍នេសាទបានដឹកនាំប្រជុំដើម្បីប្រមូលកំលាំងរកសម្រាស់ សម្រាស់ដាក់ក្នុងអន្លង់អភិរក្សបានទទួលជោគជ័យដោយសមាជិកសហគមន៍បានស្ម័គ្រចិត្តរកគល់ឈើដើម្បីដាក់នៅក្នុងអន្លង់អភិរក្ស ។

២០០៦

- ☆ **ការចូលរួមវេទិកាសង្គម:** លោកស្រី តាន់ គីមគួយមានវត្តមានច្រើននៅក្នុងវេទិកាសង្គមទាំងក្នុងនិងក្រៅសហគមន៍ ។ ជារួមគាត់បានចូលរួមក្នុងសកម្មភាពនេះជាច្រើនដូចជាសិក្ខាសាលា វគ្គបណ្តុះបណ្តាល ទស្សនៈកិច្ចសិក្សា វិភាគទានសង្គម និងកម្មវិធីលើកទឹកចិត្តចាស់ជរានៅក្នុងសហគមន៍ ។

## ៣.៣. សកម្មភាពលេចធ្លោរបស់ស្ត្រី

កាលានុវត្តភាពការងាររបស់ស្ត្រីមានច្រើនជាងបុរសដូចជាការទំនាក់ទំនងទីផ្សារការចងក្រងក្រុមប្រជានេសាទការចរចារការកៀងគរមូលនិធិអភិវឌ្ឍ ការផ្សព្វផ្សាយ ឬការងារ ផ្សេងៗទៀតដែលមាននៅក្នុងសកម្មភាពអភិវឌ្ឍមូលដ្ឋាន ។



លោក ស្រី តាន់ គីមគួយ គឺជាអ្នកដឹកនាំដ៏ឆ្នើមមួយធ្លាប់ទទួលបានលទ្ធផល ដ៏ច្រើនក្នុងការគ្រប់គ្រង និងចាត់ចែងរៀបចំដំណើរការក្នុងសហគមន៍នេសាទ ។ គាត់បានទទួលមេដៃប្រាក់ពីសម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ក្នុងឆ្នាំ២០០៤ ។ ដោយសារតែគាត់បានដឹកនាំក្រុមល្បាតចុះបង្ក្រាបរៀងរាល់ឆ្នាំជាមធ្យមរឹបអូសបាន ឧបករណ៍ល្មើសគឺម៉ូទ័រឆក់ ៤៩ គ្រឿង អាគុយ ៧ គ្រឿង សំណាញ់ ៣ម៉ែត្រ ចំនួន ៣០ វង់ អាយស្បៃមុង ០១ អួនស្បៃ មុង ១៥ ម៉ែត្រ នៃឆ្នាំនីមួយៗ ។ គាត់បានដឹកនាំបង្កើតតំបន់អភិរក្សអន្លង់វត្តភ្នៀត ៥កន្លែង ដែលបានទាក់ទាញនូវភ្ញៀវទេសចរយ៉ាងច្រើនទៅកំសាន្តនៅទីនោះ និងវាបានក្លាយជាប្រភពនៃប្រាក់ចំណូលសំរាប់ទ្រទ្រង់សហគមន៍នេសាទ ។ លើសពីនេះទៅទៀត គាត់អាចធ្វើការទាក់ទងជាមួយអាជ្ញាធរភូមិ–ឃុំឱ្យមកចូលរួមប្រជុំផ្សព្វផ្សាយ និងសហការក្នុងការចុះបង្ក្រាបបទល្មើសបានល្អទៀតផង ។

ប្រសិនបើមានស្ត្រីចូលរួមនាំឱ្យកិច្ចការទាំងឡាយដែលពាក់ព័ន្ធជាមួយស្ត្រីគឺមានភាពងាយស្រួលទំនាក់ទំនងគ្នាព្រោះថាស្ត្រីដូចគ្នាទើបយល់នូវអ្វីដែលស្ត្រីត្រូវការនេះ គឺភាពជោគជ័យរបស់ស្ត្រីនិងស្នា–ដៃដ៏អស្ចារ្យក្រោមការដឹកនាំរបស់ស្ត្រីដែលជាមេ–ដឹកនាំ ។
(លោកស្រី ធុយ ប៉ាច នៅភូមិអង្គាបុស ឆ្នាំ ២០០៦)

## ៤. កិច្ចសហការរបស់អ្នកពាក់ព័ន្ធបានធ្វើឱ្យធនធានជលផលកើនឡើង

នៅទូទាំងខេត្តបន្ទាយមានជ័យ គឺផលនេសាទទឹកសាបបានគេសំគាល់ថាមានការកើនឡើងយឺតបើប្រៀបធៀបទៅនឹងឆ្នាំមុន ។ ជាពិសេសនៅក្នុងឆ្នាំ២០០០ ផលនេសាទចាប់បាននៅក្នុងខេត្តបន្ទាយមានជ័យសរុបចំនួន ៨៩៥ តោន ក្នុងនោះផលនេសាទស្រស់ចំនួន៦៧០តោន និងកែច្នៃចំនួន ២២៥ តោន ។ នៅឆ្នាំ២០០៥ ផលនេសាទសរុបចំនួន ១.៨៦៥ តោន ក្នុងនោះផលនេសាទត្រីស្រស់ចំនួន ១.៦៣៥ តោន និងកែច្នៃចំនួន ២៣០ តោន ។ ដោយឡែកនៅឆ្នាំ២០០៦ ផលត្រីចាប់បានសរុបមានតែ ១.៩២៥ តោន តែប៉ុណ្ណោះ ។ យ៉ាងណាមិញ បើយើងពិនិត្យមើលនៅក្នុងសហគមន៍នេសាទភ្នៀត–កោះពងសត្វបន្ទាប់ពីបានបង្កើត និងមានដំណើរការអស់រយៈពេលជាង ៥ឆ្នាំកន្លងមក ប្រជាជននៅក្នុងសហគមន៍បានអះអាងថាធនធានជលផលមានការកើនឡើង និងលក្ខខ័ណ្ឌជីវភាពរស់នៅរបស់ប្រជាជនមានភាពល្អប្រសើរឡើងជាងមុន ។ អ្នកនេសាទបានឱ្យដឹងថាក្រោយពេលបង្កើតសហគមន៍នេសាទមកគ្រួសារខ្ញុំពុំចាំបាច់ផ្លាស់ទីទៅរកទៅរកនេសាទនៅកន្លែងឆ្ងាយៗនោះទេ គឺអាចរកបាននៅក្បែរៗផ្ទះ ។ ការនេសាទនេះ គឺចំណាយពេលខ្លីដោយប្រើប្រាស់ឧបករណ៍លក្ខណៈគ្រួសារ ។ អ្នកនេអ្នកនេសាទទាំងនោះអាចចាប់ត្រីបានយ៉ាងងាយពី ០.៥គីឡូក្រាម ទៅ ១គីឡូក្រាម សំរាប់ផ្គត់ផ្គង់ម្ហូបអាហារប្រចាំថ្ងៃរបស់ពួកគាត់ (លោក ទូន ម៉ៅ) ។ ប្រភេទត្រីកម្រខ្លះបានកើតមានឡើងវិញនៅក្នុងកន្លែងនេសាទសហគមន៍ ជាពិសេសនៅកន្លែងអន្លង់អភិរក្សដូចជាប្រភេទត្រីកេសត្រីក្រាយនិងត្រីខ្នាន់ ។នៅក្នុងភូមិអង្គាបុស្សអ្នកនេសាទក៏បានកំណត់សំគាល់ឃើញថា៖ ប្រភេទត្រីមេពូជមានការកើនឡើង(gold fin tinfoil bard) ។



នៅក្នុងសហគមន៍នេសាទភ្នៀតកោះពងសត្វមានព្រៃលិចទឹកជាច្រើនដែលធ្វើឱ្យលក្ខខណ្ឌធម្មជាតិមានភាពប្រសើរឡើង ពីព្រោះសហគមន៍នេសាទបានបញ្ឈប់ការកាប់បំផ្លាញព្រៃលិចទឹក ។ កិច្ចសហប្រតិបត្តការដ៏រឹងមាំរបស់អ្នកពាក់ព័ន្ធទាំងនេះបានធ្វើឱ្យមានការផ្សព្វផ្សាយជាសាធារណៈអំពីការការពារព្រៃលិចទឹកនិងការពង្រឹងច្បាប់ជលផលដើម្បីធ្វើឱ្យប្រសើរឡើងនូវបរិស្ថានទឹកនៅតាមដងស្ទឹង ។ ឥឡូវនេះប្រជាជនអាចប្រើប្រាស់ទឹកស្ទឹងដោយមិនចាំបាច់ប្រើប្រាស់សាច់ជូរដើម្បីធ្វើឱ្យទឹកថ្លាឡើយ (លោក ប៊ុន អាត ប្រធានក្រុមប្រឹក្សាឃុំកោះ–ពងសត្វ) ។

ព្រៃលិចទឹកនៅក្នុងសហគមន៍ភ្នៀត–កោះពងសត្វក្នុងពេលបច្ចុប្បន្ននេះមានភាពប្រសើរជាងមុនដោយសកម្មភាពកាប់បំផ្លាញត្រូវបានថយចុះជាលំដាប់ ។ លទ្ធផលទាំងនេះ គឺដោយសារកិច្ចសហការណ៍ល្អរវាងស្ថាប័នជំនាញជាមួយអ្នកពាក់ព័ន្ធជាពិសេសអាជ្ញាធរដែនដីចុះផ្សព្វផ្សាយដល់ប្រជាពលរដ្ឋឱ្យបានយល់ច្បាស់អំពីតួនាទី និងសារៈប្រយោជន៍នៃព្រៃលិចទឹក ។

លោក ឃឹម លី អនុប្រធានមន្ទីរបរិស្ថានខេត្តបន្ទាយមានជ័យ

ជាធម្មតាពុំមាននរណាម្នាក់ចង់ចាកចេញពីស្រុកកំណើតបែក ឆ្ងាយពីក្រុមគ្រួសារទៅរកការងារឆ្ងាយៗនោះឡើយ តែអាស្រ័យដោយកត្តាចាំបាច់ត្រូវតែបង្ខំចិត្តដើម្បីស្វែងរកប្រាក់ចំណូលខ្វះសម្រាប់ជីវភាពគ្រួសារដែលកំពុងខ្វះខាត។ បច្ចុប្បន្ននេះនៅក្នុងសហគមន៍នេសាទភ្នៀតកោះពងសត្វដោយសារធនធានជលផលមានភាពល្អប្រសើរជាកត្តាមួយក្នុងការជួយកាត់បន្ថយការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋក្នុងមូលដ្ឋានបានមួយចំនួន។ តាមព័ត៌មានពីប្រជាពលរដ្ឋនៅក្នុងសហគមន៍នេសាទភ្នៀតកោះពងសត្វបានឱ្យដឹងថាៈ កាលពីមុនមានប្រជាពលរដ្ឋក្នុងឃុំជាច្រើនបានចាកចេញពីស្រុកកំណើតទៅស៊ីឈ្នួលនៅប្រទេសថៃតែបច្ចុប្បន្ននេះមួយចំនួនបានវិលត្រឡប់មកប្រកបរបររកស៊ីនៅស្រុកកំណើតវិញជាបណ្តើរៗ ហើយដោយពួកគាត់ប្រកបរបរធ្វើស្រែ នេសាទ និងចិញ្ចឹមសត្វ។



សកម្មភាពប្រកបមុខរបរបន្ថែមរបស់សមាជិកសហគមន៍នេសាទ
(រូបថតភាពដោយៈ ក្រុមខេត្តបន្ទាយមានជ័យ, ២០០៦)

លោក អុល កុញ អាយុ៤៣ឆ្នាំ ជាប្រជានេសាទរស់នៅភូមិអង្គាបុស្សបានបញ្ជាក់ថា សព្វថ្ងៃនេះខ្ញុំប្រកបរបរនេសាទតែពុំត្រូវចំណាយពេលយូរដូចពេលមុនទៀតឡើយខ្ញុំអាចសល់ពេលពីការធ្វើនេសាទមកជួយធ្វើកិច្ចការនៅឯផ្ទះបានខ្លះទៀតដើម្បីបង្គ្រប់ទៅដល់ជីវភាពគ្រួសារដូចជាខ្ញុំអាចទៅធ្វើស្រែចំការហើយពេលខ្លះខ្ញុំក៏អាចទៅចិញ្ចឹមជ្រូក។



# ៥.	កិច្ចសហប្រតិបត្តិការណ៍នៃស្ថាប័នពាក់ព័ន្ធនាំឱ្យមានការគាំទ្រដល់សហគមន៍នេសាទ

យោងលើស្នាដៃល្អរបស់សហគមន៍នេសាទ ដែលធ្លាប់ទទួលបាននូវការកោតសរសើរពីអាជ្ញាធរដែនដីសមត្ថកិច្ច ពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់នេះបានបណ្តាលឱ្យមានការគាំទ្រពីគ្រប់ស្ថាប័នពាក់ព័ន្ធនានា ជាពិសេស ការគាំទ្រទាំងនេះត្រូវបានស្តែងចេញជាគំនិតផ្តួចផ្តើមបីសំខាន់ៗដូចជា: ការគ្រប់គ្រងសហគមន៍នេសាទ ការគ្រប់គ្រងអន្លង់អភិរក្សគម្រោងផ្តល់ឥណទានខ្នាតតូច និងការកសាងសមត្ថភាពដល់គណៈកម្មការសហគមន៍នេសាទ ។

## ៥.១.	ការបង្កើតអន្លង់អភិរក្សពូជត្រី

ដើម្បីធានាបាននូវការប្រើប្រាស់ធនធានជលផលប្រកបដោយចីរភាពស្របតាមស្មារតីនៃអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទគណៈកម្មការ និងអនុគណៈកម្មការសហគមន៍នេសាទ និងអ្នកពាក់ព័ន្ធបានរួមសហការគ្នាបង្កើតតំបន់អភិរក្សអន្លង់ពូជត្រីចំនួន៥កន្លែងរួមមាន: អន្លងវត្តភ្នៀត កន្ទួត កោះកំព្រីង ដូនឥដ្ឋ និងស្រះវត្តអង្គាបុស្សការគ្រប់គ្រងសហគមន៍នេសាទបានចង្អុលបង្ហាញឱ្យឃើញថា: ប្រជាជនមានឆន្ទៈចូលរួមការពារពូជត្រីនៅក្នុងដែនសហគមន៍នេសាទក្នុងគោលបំណងសំរាប់ផ្គត់ផ្គង់តំរូវការប្រចាំថ្ងៃនិងធានាបាននូវនិរន្តរភាពនៃការប្រើប្រាស់ធនធានទាំងនេះ ។

បទពិសោធន៍ដែល បានមកពីអន្លង់អភិរក្សវត្តភ្នៀតបង្ហាញឱ្យឃើញថានេះ គឺជាដែនអភិរក្សតែមួយគត់ដែលធ្វើឱ្យមានការទាក់ទាញភ្ញៀវទេសចរណ៍មកទស្សនានៅក្នុងសហគមន៍នេសាទ ហើយថែមទាំងបានទិញចំណីត្រីដាក់ឱ្យត្រីនៅក្នុងអន្លង់អភិរក្សនោះទៀតផង មិនតែប៉ុណ្ណោះភ្ញៀវទេសចរណ៍ដែលមកពីស្ថាប័នជាតិអង្គការជាតិអន្តរជាតិ និងនិសិត្សដែលមកពីសាកលវិទ្យាល័យនានាបានសំរេចយកសហគមន៍នេសាទនេះជាតំបន់សិក្សា និងស្រាវជ្រាវរបស់ពួកគេ។ ពួកគេក៏បានធ្វើវិភាគទានជាថវិកាមួយចំនួនដើម្បីគាំទ្រ និងពង្រឹងការគ្រប់គ្រងសហគមន៍នេសាទឱ្យមានប្រសិទ្ធិភាព ។

យោងតាមការរៀបរាប់របស់លោក មួង ហោន ជាអនុប្រធានគណៈកម្មការសហគមន៍នេសាទ និងប្រជាជនដទៃទៀតនៅក្នុងភូមិបានឱ្យដឹងថា: កាលពីមុនពួកគេមិន

ចាប់តាំងពីបង្កើតតំបន់អភិរក្សមកពូជត្រីមួយចំនួនដែលស្ទើរតែដាច់ពូជនេះបានកើតមានឡើងវិញនៅក្នុងស្ទឹងសិរីសោភ័ណដូចជាប្រភេទត្រីក្រាយត្រី ក្អែក ត្រីកេស ត្រីខ្នាន់ជាដើម ។ល។ ដូច្នេះការគាំទ្រដល់ការងារថែរក្សាអន្លង់អភិរក្សពីសំណាក់ភាគីពាក់ព័ន្ធជាកត្តាចាំបាច់ដែលត្រូវតែអនុត្តឱ្យបានច្រើនថែមទៀតជាពិសេសការផ្តល់ពូជត្រីពីការិយាល័យជលផលខេត្តដើម្បីលែងចូលនៅក្នុងអន្លងអភិរក្សទាំងនេះ ។ សំដីដកស្រង់ពីលោក យិន យឹម ជាអនុគណៈកម្មការសហគមន៍នេសាទភ្នៀតកោះ–ពងសត្វ (២០០៦)



ទាន់បានយល់នូវអ្វីទៅជាកិច្ចសហប្រតិបត្តិការណ៍ និងការការពារធនធានមុនពេលដែលពួកគាត់មានការសម្រេចចិត្តឱ្យមានតំបន់អភិរក្សអន្លង់ពូជត្រីនេះឡើង ។ ទោះបីជាដូច្នេះក៏ដោយ ក៏ប្រជាជនមានការពេញចិត្តចំពោះលទ្ធផលនៃកិច្ចសហប្រតិបត្តិការណ៍ល្អពីសមាជិកសហគមន៍នេសាទ អាជ្ញាធរឃុំ និងប៉ូលីសក្នុងកិច្ចការពារដែននេសាទ និងអន្លង់អភិរក្ស ។ ប្រាក់ចំណូលមួយចំនួនដែលបានមកពីភ្ញៀវទេសចរណ៍ និងការធ្វើវិភាគទានផ្សេងៗទៀតបានធ្វើឱ្យប្រជាជននៅក្នុងសហគមន៍នេសាទមានការយល់កាន់តែច្បាស់អំពីតម្លៃនៃកិច្ចសហប្រតិបត្តិការណ៍ និងកាន់តែធ្វើឱ្យពួកគេមានសកម្មភាពយ៉ាងសកម្មក្នុងការជួយគ្រប់គ្រងធនធានជលផលនៅក្នុងសហគមន៍នេសាទរបស់គាត់ ។

## ៥.២. កម្មវិធីឥណទាន

គម្រោងឥណទាននេះត្រូវបានគាំទ្រជាជំនួយបច្ចេកទេសពីមន្ត្រីការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទដោយមានការសម្របសម្រួលពីគម្រោង IDRC បានបង្កើតនូវក្រុមជួយខ្លួនឯងដែលគ្រប់គ្រងជាលក្ខណៈឥណទានខ្នាតតូចសំរាប់បង្កើនមុខរបរចិញ្ចឹមជីវិតរបស់ពួកគេដូចជា: ការចិញ្ចឹមជ្រូក ការដាំបន្លែ និងការទិញជីគីមីសំរាប់យកមកធ្វើស្រែ ។ គម្រោងឥណទាននេះបានរៀបចំចំនួន១២ក្រុមដោយក្នុងមួយក្រុមៗមានសមាជិក៥គ្រួសារ ។ គ្រប់សមាជិកទាំងអស់នៅក្នុងក្រុមនីមួយៗត្រូវទទួលខុសត្រូវក្នុងការសងត្រឡប់មកក្រុមវិញនូវការប្រាក់ ប្រសិនបើសមាជិកណាម្នាក់នៅក្នុងក្រុមមិនបានបង់ការប្រាក់តាមកាលកំណត់ទេនោះប្រធានក្រុមនិងទទួលខុសត្រូវលើការបាត់បង់នៃការប្រាក់នោះ ។ ប្រាក់ដើមសរុបមានចំនួន៣.០០០ដុល្លា សំរាប់សមាជិកទាំង១២ក្រុមដែលមានរយៈពេល១២ខែដោយគិតអត្រាការប្រាក់ ១% ក្នុងមួយខែតែប៉ុណ្ណោះ ។

ប្រាក់ចំណូលដែលបានមកពីការប្រាក់ត្រូវបានបែងចែកអាស្រ័យទៅតាមការឯកភាពគ្នារបស់សមាជិកក្រុម ។ ឥណទានខ្នាតតូចត្រូវបានផ្តល់អោយគ្រួសារទាំងនោះដើម្បីបង្កើនមុខរបរបន្ថែមសម្រាប់ជួយទ្រទ្រង់ជីវភាពរបស់ពួកគាត់ ។ ទោះបីជាការផ្តល់ឥណទានមានសាច់ប្រាក់តិចតួចក៏ដោយ ក៏ប្រជាជននៅក្នុងមូលដ្ឋានមានការពេញចិត្តចំពោះស្ថេរភាពក្នុងការអនុវត្តគម្រោងចិញ្ចឹមជីវិតជាលក្ខណៈសាមញ្ញរបស់ពួកគាត់ ។ បណ្តុំនៃគម្រោងនេះបានធ្វើអោយមានការលើកទឹកចិត្តដល់ប្រជាជនដើម្បីធ្វើការងារពេញលេញជាងមុន ។ នេះគឺជាការផ្តួចផ្តើមគំនិត ដែលបានធ្វើអោយប្រជាជនមានមោទនភាពចំពោះពួកគេដែលបាននិងកំពុងធ្វើ ។



សកម្មភាពចិញ្ចឹមជ្រូករបស់ក្រុមឥណទាន

(រូបថតភាពដោយ: ក្រុមខេត្តបន្ទាយមានជ័យ ២០០៦)



សកម្មភាពចិញ្ចឹមទារបស់ក្រុមឥណទាន

(រូបថតភាពដោយ: ក្រុមខេត្តបន្ទាយមានជ័យ ២០០៦)

ការបែងចែក និងការប្រើប្រាស់ប្រាក់ការក្នុងគម្រោងឥណទាននេះមានដូចខាងក្រោម:

- ៥០ ភាគរយ ទុកសម្រាប់ពង្រីកទុន
- ១០ ភាគរយ សម្រាប់ការងារអភិវឌ្ឍន៍សហគមន៍នេសាទ
- ៥ ភាគរយ សម្រាប់ចូលរួមអភិវឌ្ឍន៍ភូមិ ឃុំ
- ៥ ភាគរយ សម្រាប់ចំណាយទៅលើ ប៊ិច សៀវភៅ និងការប្រជុំរបស់ក្រុមសន្សំម្តងៗ
- ៥ភាគរយ សម្រាប់ចំណាយការធ្វើដំណើរការងារត្រួតពិនិត្យរាល់ការប្រជុំបង់ការប្រាក់ និងសន្សំរបស់ក្រុមទាំង ១២ រៀងរាល់ខែ
- ២០ ភាគរយសម្រាប់ចំណាយទៅលើប្រធានក្រុមនិងសមាជិកក្រុម
- ៥ភាគរយសម្រាប់ចំណាយក្នុងមូលនិធិជួយសង្គ្រោះសមាជិកចាស់ជរាដែលមានជំងឺ និងគ្រោះថ្នាក់ផ្សេងៗក្នុងសហគមន៍នេសាទ ។

## ៥.៣. ការពង្រឹងសមត្ថភាពសហគមន៍នេសាទ

ការពង្រឹងសមត្ថភាពសហគមន៍នេសាទជាកត្តាមួយយ៉ាងសំខាន់ក្នុងការបង្កើនចំណេះដឹងរបស់សហគមន៍ក្នុងការគ្រប់គ្រង និងដោះស្រាយបញ្ហាផ្សេងៗដែលកើតមាននៅក្នុងសហគមន៍ ។ នៅក្នុងសហគមន៍នេសាទកន្លងមកពុំដែលមានស្ថាប័នជំនាញជាពិសេសមន្ទីរអប់រំឬអង្គការណាចុះទៅសម្របសម្រួល និងផ្តល់ការបណ្តុះបណ្តាលផ្សព្វផ្សាយដល់ប្រជាជន និងកុមារក្នុងភូមិនេះឡើយទើបតែនៅក្នុងឆ្នាំ ២០០៣ គម្រោង IDRC សហការជាមួយការិយាល័យអភិវឌ្ឍន៍សហគមន៍



នេសាទបានចុះសម្របសម្រួលបង្រៀនពីជំនាញសម្របសម្រួលការសរសេររបាយការណ៍ និងកំណត់ហេតុដោះស្រាយទំនាស់ និងរបៀបសរសេរសំណើរស្នើសុំថវិកាដល់គណៈកម្មការ និងអនុគណៈកម្មការសហគមន៍នេសាទ ហើយបានអញ្ជើញពួកគាត់ទៅចូលរួមក្នុងវគ្គសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងទស្សនៈកិច្ចសិក្សាផ្សេងៗទៀត ។ ការគាំទ្រទៅលើការពង្រឹងផ្នែកសមត្ថភាពនេះពុំបានបំបែកប្រធានបទអោយឆ្ងាយចេញពីកិច្ចការអភិរក្សនិងគម្រោងឥណទាន ។ បង្កើនការយល់ដឹងទៅលើថ្នាក់ដឹកនាំនិងសមាជិកសហគមន៍នេសាទអំពីជំនាញគ្រប់គ្រងធនធានជលផលដែលទាក់ទងទៅនឹងបញ្ហាចិញ្ចឹមជីវិត ។ សមត្ថភាពដើម្បីចងក្រងបណ្តាញ និងស្វែងរកការគាំទ្រ និងការលើកទឹកចិត្តពីសំណាក់រាជរដ្ឋាភិបាល ពីស្ថាប័នខាងក្រៅនានា នឹងអង្គការជាដៃគូម្ចាស់ជំនួយដែលជាផ្នែកមួយដ៏សំខាន់ដើម្បីគាំទ្រដល់សហគមន៍នេសាទ ។ ឧទាហរណ៍ដូចជាៈការសរសេរគម្រោងស្នើរសុំថវិកាវាជាចំណេះដឹងជាមូលដ្ឋានមួយដែលថ្នាក់ដឹកនាំសហគមន៍នេសាទត្រូវតែចេះ ។ លោក ទុំ មាល ដែលជាប្រធានក្រុមប្រឹក្សាឃុំភ្លៀតបាននិយាយថាៈ ប្រសិនបើពួកគេមិនបានអភិវឌ្ឍន៍សមត្ថភាពដោយខ្លួនឯងដោយគ្មានការជួយជ្រោមជ្រែងពីអាជ្ញាធរមូលដ្ឋាន និងប្រជាជនមូលដ្ឋានម្លោះសមពួកគេមិនអាចបង្កើតសហគមន៍នេសាទនេះបានទេ ហើយសហគមន៍នេសាទនេះក៏មិនមានដំណើរការល្អយ៉ាងដូច្នេះដែរ ។

លោកកែវ គឺសមាជិកគណៈកម្មការសហគមន៍នេសាទភ្លៀត-កោះពងសត្វបានអះអាងថាៈ កាលពីមុនខ្ញុំមិនធ្លាប់បានទទួលវគ្គបណ្តុះបណ្តាលអ្វីទាំងអស់ ។ ប៉ុន្តែនៅក្នុងឆ្នាំ២០០៣ គម្រោង IDRC បានផ្តល់នូវវគ្គបណ្តុះបណ្តាលទៅដល់គណៈកម្មការសហគមន៍នេសាទ និងបានចែករំលែកបទពិសោធន៍ពីសហគមន៍មួយទៅសហគមន៍ដទៃទៀត ។ ចាប់តាំងពីពេលនោះមកខ្ញុំបានយល់ដឹងកាន់តែច្បាស់អំពីការងារ និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងសហគមន៍នេសាទ ។

## ៦. សន្និដ្ឋាន

សហគមន៍នេសាទភ្លៀតកោះពងសត្វ ជាសហគមន៍មួយដែលត្រូវបានចាត់ទុកជាសហគមន៍នេសាទលេចធ្លោរនៅក្នុងព្រះរាជាណាចក្រកម្ពុជាតាំងពីការបង្កើតឡើង និងមានដំណើរការអស់រយៈពេល ៥ឆ្នាំកន្លងមកនេះ ។ សមិទ្ធិផលដ៏ត្រចះត្រចង់ដែលទទួលបានទាំងនេះ គឺកើតឡើងដោយស្នាដៃនិងការខិតខំប្រឹងប្រែងផ្ទាល់របស់ប្រជាពលរដ្ឋមូលដ្ឋាន ។ ទន្ទឹមនឹងនេះកិច្ចសហការល្អពីភាគីពាក់ព័ន្ធជាពិសេសស្ថាប័នជំនាញ និងអាជ្ញាធរមូលដ្ឋានគឺជាកត្តាចំបងដែលមិនអាចខ្វះបានដែលធ្វើឱ្យការងារនេះទទួលបានជោគជ័យ ។ ទោះជាកិច្ចសហការដោយផាល់ក្តីឬដោយប្រយោលក្តីវាបានជួយទៅដល់ដំណើរការការងារក្នុងសហគមន៍នេសាទតាំងពីការបណ្តុះបណ្តាលការផ្សព្វផ្សាយ និងទប់ស្កាត់បទល្មើសនេសាទផ្សេងៗ ជាពិសេសជួយដល់កិច្ចអភិវឌ្ឍន៍សហគមន៍នេសាទ ។



បទពិសោធន៍របស់សហគមន៍នេសាទនេះក៏បានបង្ហាញថាការគាំទ្រ និងកិច្ចសហប្រតិបត្តការរបស់អាជ្ញាធរមូលដ្ឋាន ការិយាល័យជលផលខេត្តនិងព្រះសង្ឃគឺជាសមាសភាពយ៉ាងសំខាន់នៅក្នុងការគ្រប់គ្រងសហគមន៍នេសាទភ្លៀតកោះពងសត្វ ប្រកបដោយចីរភាព ។ ការចូលរួមរបស់ព្រះសង្ឃ គឺជាលទ្ធផលកើតចេញពីការចាប់អារម្មណ៍ របស់គាត់ក្នុងការការពារធនធានជលផល និងមានឆន្ទៈយ៉ាងពិតប្រាកដក្នុងការអភិរក្ស ។ ព្រះសង្ឃមានជំនឿជឿជាក់ថាការការពារពូជត្រី និងធនធានផ្សេងៗទៀត គឺជាការទទួលខុសត្រូវរបស់មនុស្សគ្រប់រូប ហើយព្រះអង្គចង់ឱ្យប្រជាជនទូទៅមានការចាប់អារម្មណ៍ដូចអ្វីដែលគាត់កំពុងតែអនុវត្ត ។ ព្រះសង្ឃបានដើរតួនាទីយ៉ាងសំខាន់ក្នុងការឃ្លាំមើលនិងការទប់ស្កាត់បទល្មើសនេសាទ ពីព្រោះទីតាំងកន្លែងអភិរក្សស្ថិតនៅទល់មុខវត្ត ។ ដូច្នេះហើយប្រជាជនត្រូវតែគោរពតាមច្បាប់សហគមន៍អំពីការទប់ស្កាត់បទល្មើសនេសាទ ពីព្រោះច្បាប់ទាំងនោះក៏ត្រូវបានព្រះសង្ឃទទួលស្គាល់ដែរ ។

កិច្ចសហប្រតិបត្តិការនេះក៏បានបង្ហាញថាស្ត្រីបានដើរតួនាទីយ៉ាងសំខាន់ក្នុងការគ្រប់គ្រងនិងដឹកនាំធ្វើផែនការសំរាប់សហគមន៍នេសាទដោយមានស្មារតីទទួលខុសត្រូវ និងលះបង់ខ្ពស់ថែមទាំងមានកិច្ចសហការល្អជាមួយស្ថាប័នផ្សេងៗ សមស្របទៅនឹងការលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលដែលជំរុញអោយមានការចូលរួមរបស់ស្ត្រីរួមចំណែកក្នុងការអភិវឌ្ឍន៍សង្គម ។ សហគមន៍នេសាទភ្លៀតកោះពងសត្វ គឺដឹកនាំដោយស្ត្រីហើយការខិតខំប្រឹងប្រែងរបស់គាត់ទាំងនេះបានញុំាងឱ្យស្ត្រីផ្សេងៗទៀតចូលរួមក្នុងការគ្រប់គ្រនធានជលផលយ៉ាងប្រសើរ ។ ករណីសិក្សានេះក៏បានបង្ហាញឱ្យឃើញផងដែរ អំពីការផ្លាស់ប្តូរជាវិជ្ជមានពីការចាប់ផ្តើមរបស់បុគ្គលម្នាក់ ហើយក៏ជាពេលវេលាគ្រប់គ្រាន់ក្នុងការធ្វើឱ្យមានការផ្លាស់ប្តូរនៃការគ្រប់គ្រងសហគមន៍នេសាទឱ្យបានទូលំទូលាយ ។

មិនតែប៉ុណ្ណោះ សហគមន៍នេះមានចក្ខុវិស័យច្បាស់លាស់ក្នុងការគ្រប់គ្រងធនធានជលផលដោយបានបង្កើតជាតំបន់អភិរក្សចំនួន៥កន្លែងក្នុងនោះអន្លង់អភិរក្សវត្តភ្លៀតដែលមានចំណាប់អារម្មណ៍ដល់ប្រជាជនក្នុងខេត្តភ្ញៀវមកទស្សនៈកិច្ចអ្នកស្រាវជ្រាវ និងជាកន្លែងសំរាប់និស្សិតសាកលវិទ្យាល័យធ្វើសារណាបញ្ចប់ការសិក្សា ។ ដោយខ្សែកកម្មវិធីឥណទានបានជួយអោយសមាជិកសហគមន៍នេសាទមានមុខរបរបន្ថែមទៀតដើម្បីបង្កើនប្រាក់ចំណូលប្រចាំគ្រួសារ។ ឯការពង្រឹងសមត្ថភាពជាកត្តាមួយដើរតួនាទីយ៉ាងសំខាន់ក្នុងការបង្កើនចំណេះដឹងទៅលើការគ្រប់គ្រងទំនាក់ទំនងការដោះស្រាយបញ្ហាផ្សេងៗដែលកើតមានឡើង និងធានាបាននូវធនធានមនុស្សល្អៗក្នុងសហគមន៍ក្នុងការអនុវត្តការងារប្រកបដោយប្រសិទ្ធិភាព និងគុណភាពយូរអង្វែង ។ ឆ្លងតាមបទពិសោធន៏របស់សហគមន៏នេសាទភ្លៀត–កោះពងសត្វបានចង្អុលបង្ហាញថា ការងារសហគមន៏នេសាទល្អគឺមានចាប់អារម្មណ៍ និងមានការចូលរួមពីអ្នកពាក់ព័ន្ធផ្សេងៗទៀត ដូចពាក្យស្លោកខ្មែរពោលថា "តក់ៗពេញបំពង់" ។



បទពិសោធន៍ដែលទទួលបានពីដំណើរសហគមន៍នេសាទភ្នៀត កោះពងសត្វ គឺជាមេរៀនមួយយ៉ាងល្អក្នុងការចែករំលែកដល់សហគមន៍នេសាទផ្សេងទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ដូច្នេះអត្ថបទនៃករណីសិក្សានេះ គឺជាមធ្យោបាយមួយដ៏ល្អសម្រាប់ធ្វើការផ្សព្វផ្សាយ និងបង្កលក្ខណៈងាយស្រួលដល់ស្ថាប័នជំនាញ និងអ្នកពាក់ព័ន្ធក្នុងការបំពេញភារៈកិច្ចជួយដល់ដំណើរសហគមន៍នេសាទនៅក្នុងព្រះរាជាណាចក្រឱ្យមានដំណើរការរីកចម្រើនទៅមុខដើម្បីផលប្រយោជន៍យូរអង្វែងរបស់ប្រជាពលរដ្ឋកម្ពុជាយើង ។

## ៧. អនុសាសន៍

សហគមន៍នេសាទភ្នៀត–កោះពងសត្វ គឺជាគំរូមួយក្នុងការងារគ្រប់គ្រងសហគមន៍ ដែលមានការចូលរួមសហការយ៉ាងច្រើនពីអ្នកពាក់ព័ន្ធ ។ កិច្ចការនោះ គឺទាមទារយ៉ាងចាំបាច់ត្រូវតែបន្ត និងមានការសំណូមពរដូចខាងក្រោម :

- ការគាំទ្រថវិកា និង បច្ចេកទេសពីខាងក្រៅ គឺនៅតែត្រូវការចាំបាច់ក្នុងការបន្តការគាំទ្រទៅសហគមន៍នេសាទ ភ្នៀត–កោះពងសត្វ ជាពិសេសគម្រោង IDRC ។ មិនតែប៉ុណ្ណោះថវិកា និងបច្ចេកទេសនេះគួរតែគាំទ្រនៅសម្ភារៈល្បាត និងពង្រឹងសមត្ថភាពដល់សហគមន៍នេសាទ ។
- ការលើកទឹកចិត្ត និងកោតសរសើរពីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងៗទៀត គឺជាផលកម្រៃដ៏ល្អសម្រាប់កិច្ចសហប្រតិបត្តការនេះ ។ អ្នកពាក់ព័ន្ធក្នុងសហគមន៍នេសាទគួរគិតគូរការផ្តល់ផលកម្រៃដល់ការងារគ្រប់គ្រងសហគមន៍នេសាទ ដែលអនុវត្តបានល្អដូចជារង្វាន់លើកទឹកចិត្ត ។
- ការកសាងសមត្ថភាព គឺជាដំណើរការមួយដ៏យូរអង្វែង និងជាតម្រូវការចាំបាច់របស់សមាជិកសហគមន៍នេសាទក្នុងការគាំទ្រឱ្យកើតមានឡើង ។ វគ្គបណ្តុះបណ្តាលជាច្រើនទៀតគួរតែផ្តល់ឱ្យទៅគណៈកម្មការអនុគណៈកម្មការ និងសមាជិកសហគមន៍នេសាទ ។

## REFERENCE:


- ✶ Report Credit activities in Phneat Koh Pong Sat CF ( March 2006 ) ( CFDO / FiA )
- ✶ Summary report of Phneat Koh Pong Sat CF ( 2004 ) ( CFDO / FiA )
- ✶ Report result of the Scoping activities in Phneat Koh Pong Sat CF ( March 2004 ) ( CFDO / FiA )
- ✶ Report on Training CF Committee in Phneat Koh Pong Sat ( CFDO / FiA )
- ✶ Report of Commune in Phneat Koh Pong Sat (2005) ( CFDO / FiA )
- ✶ Report activities of Banteymean chey Provincial Fishery office (2005) ( CFDO / FiA )

រូបភាពទី ៥: ផែនទីសហគមន៍ឆ្មៀត-កោះសត្វ










# ការវិភាគ និងសំយោគមតិ



# ការវិភាគ និងសំយោគមតិ

រៀបរៀងដោយលោក ស៊ឹម ប៊ុនធឿន, លោក លី វុទ្ធី, លោក គឹម ណុង, លោកស្រី សូ ស្រីមុំ និង Rebecca Rivera-Guieb

ករណីសិក្សានីមួយៗបង្ហាញពីបទពិសោធន៍ពិសេសផ្សេងៗគ្នាអំពីសហគមន៍នេសាទនៅក្នុងប្រទេសកម្ពុជា ។ ការចូលរួមរបស់អ្នកពាក់ព័ន្ធ ជាពិសេសកិច្ចសហការរបស់អាជ្ញាធរមូលដ្ឋានស្ថាប័នជលផល និងព្រះសង្ឃបានលើកឡើងនៅក្នុងបទពិសោធន៍សហគមន៍នេសាទភ្មៀត កោះពងសត្វ ។ ភាពចាំបាច់នៃកិច្ចសហប្រតិបត្តិការរបស់អ្នកពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហានេសាទខុសច្បាប់ បានបញ្ជាក់ដោយសង្ខេបនៅក្នុងសាច់រឿងរបស់សហគមន៍នេសាទថ្មស ។ ដោយឡែក ការលើកកំពស់ជីវភាពរស់នៅតាមរយៈការកសាងសមត្ថភាព និងកម្មវិធីឥណទានត្រូវបានលើកឡើងនៅក្នុងករណីសិក្សានៅសហគមន៍នេសាទកំពង់ក្រសាំង ។

ចំណុចរួមដែលបានរកឃើញនៅក្នុងករណីសិក្សាទាំង ៣ រួមមាន :

**ទីមួយ :** ការចូលរួមយ៉ាងសកម្ម ការចាប់អារម្មណ៍ និងការប្ដេជ្ញាចិត្តរបស់អ្នកភូមិ និងសមាជិកសហគមន៍នេសាទគឺជាមូលដ្ឋានគ្រឹះសម្រាប់កសាងការងារគ្រប់គ្រងសហគមន៍នេសាទ ។ នៅក្នុងប្រទេសកម្ពុជាការចូលរួមពីប្រជាពលរដ្ឋជាបញ្ហាមួយយ៉ាងលំបាក ពីព្រោះវាគឺជាកិច្ចការមួយដែលប្រជាពលរដ្ឋនៅមូលដ្ឋាន ជាពិសេសប្រជាពលរដ្ឋនៅក្នុងតំបន់ជនពុំដែលអនុវត្ត (Marschke and Nong, 2003; Markschke, 2003) ។ ករណីសិក្សាទាំងបីបង្ហាញថា ការចូលរួមរបស់ប្រជាជនមិនមែនជាអ្វីដែលកើតឡើងដោយឯកឯងទេ ប៉ុន្តែជាការជំរុញដោយសារបញ្ហាមួយចំនួនដែលអាចកើតមាននៅតាមទីកន្លែងរបស់គេរួចហើយ ឬជាការផ្ដួចផ្ដើមឱ្យមានការចូលរួមតាមរយៈសកម្មភាពគំរោង ។ ជាក់ស្ដែងស្ត្រីបានចូលរួមយ៉ាងសកម្មក្នុងការងារសហគមន៍នេសាទនៅភ្មៀត កោះពងសត្វ ហើយការចូលរួមនេះអាចជាលទ្ធផលនៃការងារដឹកនាំរបស់ស្ត្រីម្នាក់ដែលបានចំណាយកម្លាំងចិត្តកម្លាំងកាយ និងពេលវេលាដើម្បីបំរើសហគមន៍នេសាទ និងការងារអភិវឌ្ឍន៍សហគមន៍ ។ អ្នកស្រី តាន់ គឹមគុយ ប្រធានគណៈកម្មការសហគមន៍នេសាទភ្មៀត កោះពងសត្វ គឺអ្នកដឹកនាំម្នាក់ដ៏ឆ្នើម និងជាអ្នកទទួលការគោរពរាប់អានពីសំណាក់សមាជិកសហគមន៍ ។ ស្នាដៃការងាររបស់លោកស្រីមានការទទួលស្គាល់មិនត្រឹមតែក្នុងសហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពីសហគមន៍ផ្សេងៗទៀតនៅទូទាំងប្រទេស ។ ដោយឡែក នៅសហគមន៍នេសាទកំពង់ក្រសាំង ការចូលរួមរបស់ប្រជាជន ជាពិសេសការចូលរួមរបស់ស្ត្រីមានការលំបាក ប៉ុន្តែសកម្មភាពសាមញ្ញនៃគម្រោងឥណទានខ្នាតតូចរបស់សហគមន៍នេសាទ បានជំរុញឱ្យមានភាពប្រសើរឡើងនូវកិច្ចទំនាក់ទំនង និងកិច្ចសហការយ៉ាងហោចណាស់ក្នុងចំណោម ៤៤ គ្រួសារដែលពាក់ព័ន្ធនឹងគម្រោង ។ ការចូលរួមរបស់ប្រជាជននៅក្នុងសហគមន៍នេសាទឃុំថ្មសគឺជាការលំបាកបំផុតដោយសារតែប្រជាជនយល់ឃើញខុសគ្នាពីមូលហេតុនៃការធ្លាក់ចុះធនធាន ។ អ្នកនេសាទខុសច្បាប់ដែលប្រើប្រាស់ឧបករណ៍ឧន មើលស្រាលអ្នកនេសាទស្របច្បាប់ដោយចាត់ទុកថា អ្នកទាំងនោះឆោតល្ងង់មិនចង់បានប្រាក់

ចំណូលខ្ពស់តាមរយៈការប្រើប្រាស់ឧបករណ៍ទំនើប ។ អ្នកនេសាទខុសច្បាប់ ទាំងនោះយល់ឃើញថាការធ្លាក់ចុះធនធានគឺបណ្តាលមកពីកំនើនប្រជាជន និងការប្រកួតប្រជែងលើការនេសាទក្នុងចំណោមអ្នកនេសាទដោយមិនទាក់ទងនឹងប្រភេទឧបករណ៍នេសាទឡើយ ។

**ទីពីរ:** កិច្ចសហប្រតិបត្តិការ និងការបង្កើតបណ្តាញជាមួយអ្នកពាក់ព័ន្ធ ដែលចាប់ផ្តើមពីភាពជាដៃគូរវាង គណៈកម្មការសហគមន៍នេសាទ មេភូមិ និងក្រុមប្រឹក្សាឃុំ គឺជាកត្តាដ៏សំខាន់ក្នុងការគ្រប់គ្រងសហគមន៍នេសាទ ។ តាមបទពិសោធន៍នៅក្នុងសហគមន៍នេសាទដែលបានលើកឡើងនៅក្នុងសៀវភៅករណីសិក្សានេះបញ្ជាក់ថា កិច្ចសហប្រតិបត្តិការនៅក្នុងការងារសហគមន៍នេសាទ គឺចាប់ផ្តើមដោយភាពជាដៃគូរវាងគណៈកម្មការសហគមន៍នេសាទ ប្រជាពលរដ្ឋនៅក្នុងភូមិ និងក្រុមប្រឹក្សាឃុំ ។ ភាពជាដៃគូនេះបង្ហាញនៅក្នុងវិធីសាស្រ្តធ្វើការងារជាក់ស្តែងមួយចំនួនដូចជា មេភូមិ និងក្រុមប្រឹក្សាឃុំចូលរួមការបោះឆ្នោតជ្រើសគណៈកម្មការសហគមន៍នេសាទ និងបង្កើតលក្ខន្តិកៈសហគមន៍នេសាទដោយទទួលស្គាល់ដំណើរការ និងលទ្ធផលនៃការបោះឆ្នោត ។ ចំណែកឯ តំណាងគណៈកម្មការសហគមន៍នេសាទតែងតែចូលរួមប្រជុំជាមួយក្រុមប្រឹក្សាឃុំយ៉ាងទៀងទាត់ ដើម្បីសំដែងពីកង្វល់ពាក់ព័ន្ធនឹងបញ្ហានេសាទ ។ ក្រៅពីនេះ របាយការណ៍សហគមន៍នេសាទត្រូវបញ្ជូនទៅឱ្យក្រុមប្រឹក្សាឃុំយ៉ាងទៀតទាត់ទៀតផង ។ គណៈកម្មការសហគមន៍នេសាទសហការជាមួយក្រុមប្រឹក្សាឃុំ និងប៉ូលីសឃុំក្នុងការល្បាត និងអនុវត្តលក្ខន្តិកៈសហគមន៍នេសាទ ។ ជួនកាល ក្រុមប្រឹក្សាឃុំបានផ្តល់ថវិការមួយចំនួនសម្រាប់ធ្វើការងាររបស់សហគមន៍នេសាទ ដូចជាការកំណត់ព្រំព្រទល់សហគមន៍នេសាទ ឃុំថ្នល ។ កិច្ចការគ្រប់គ្រងសហគមន៍នេសាទមានភាពងាយស្រួល ប្រសិនប្រធានគណៈកម្មការសហគមន៍នេសាទមានជាប់ពាក់ព័ន្ធនឹងការងារភូមិ និងឃុំ ។ ឧទាហរណ៍ ប្រធានគណៈកម្មការសហគមន៍នេសាទកំពង់ក្រសាំង គឺជាប្រធានភូមិ និងនៅថ្នល ប្រធានគណៈកម្មការសហគមន៍នេសាទត្រូវបានទទួលការតែងតាំងធ្វើជាអ្នកដឹកនាំកិច្ចការនារីឃុំ។ នៅសហគមន៍នេសាទភ្លៀតកោះពងសត្វ ប្រធានគណៈកម្មការសហគមន៍នេសាទពុំមានតួនាទីជាផ្លូវការនៅក្នុងការដឹកនាំភូមិ និងឃុំទេ ប៉ុន្តែគឺជាបុគ្គលិកសុខាភិបាល







របស់រដ្ឋ និងជាធ្នូបឃុំ ។ ការបង្កើតភាពជាដៃគូទាំងនេះគឺស្របគ្នាទៅនឹងខ្លឹមសារនៃកំណែទម្រង់វិមជ្ឈការរបស់រដ្ឋាភិបាលកម្ពុជា ដែលមានគោលដៅផ្ទេរអំណាចពីថ្នាក់ជាតិទៅឱ្យថ្នាក់ឃុំ–សង្កាត់ និងកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលដើម្បីពង្រឹងមុខងារខេត្ត–ក្រុងជាមជ្ឈមណ្ឌលវិសហមជ្ឈការ ។ លោក Oberndorf (2005) ពន្យល់ថា តួនាទីអំណាយនៃការចំណាយ និងធនធានមួយចំនួនធំត្រូវបានប្រគល់ឱ្យរដ្ឋាភិបាលមូលដ្ឋាន ហើយអភិបាលខេត្ត-ក្រុង ទទួលខុសត្រូវផ្តល់ជំនួយ និងត្រួតពិនិត្យដល់ក្រុមប្រឹក្សាឃុំ-សង្កាត់ ។ ក្រុមប្រឹក្សាឃុំមានតួនាទីសំខាន់ ក្នុងការគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិ ទោះបីពុំមានអំណាចផ្ទាល់ក្នុងការសម្រេចចិត្តលើវិស័យមួយចំនួន ដូចជាការគ្រប់គ្រងព្រៃឈើ (ibid) ក៏ដោយ ។ ករណីសិក្សាទាំងអស់ផ្តល់ព័ត៌មានជាពិសេសអំពីបទពិសោធន៍នៃការគ្រប់គ្រងសហគមន៍នេសាទ ។ បទពិសោធន៍នៅសហគមន៍នេសាទភ្លៀតកោះពងសត្វបង្ហាញថា ព្រះសង្ឃមានតួនាទីដឹកនាំប្រជាជនតាមបែបសាសនា ដើម្បីអភិរក្សធនធាន ទោះបីព្រះសង្ឃមិនត្រូវបានគេចាត់ទុកថាជាភាគីផ្ទាល់ក្នុងសហគមន៍នេសាទក៏ដោយ ។ ការចូលរួមរបស់ព្រះសង្ឃបានផ្សារភ្ជាប់ជំនឿសាសនាជាមួយនឹងការអភិរក្សធនធាន ។ ប្រជាជនគោរពតាមលក្ខន្តិកៈ នៃការគ្រប់គ្រងសហគមន៍នេសាទ ពីព្រោះលក្ខន្តិកៈទាំងនោះជារបស់សហគមន៍ផង និងជាផ្នែកមួយនៃជំនឿ សាសនាព្រះពុទ្ធផង ។ ផ្ទុយទៅវិញ កិច្ចសហប្រតិបត្តិការរវាងអ្នកពាក់ព័ន្ធ និងស្ថាប័នពាក់ព័ន្ធនៅក្នុងសហគមន៍ថ្មីសនៅមាន ភាពទន់ខ្សោយនៅឡើយ ។ សហពន្ធ័សហគមន៍នេសាទឃុំថ្មសទើបតែត្រូវបានបង្កើតឡើងកាលពីពេលថ្មីៗកន្លងទៅនេះនិងពុំទាន់មានការទទួលស្គាល់ពីស្ថាប័នពាក់ព័ន្ធលើលក្ខន្តិកៈសហគមន៍នៅឡើយ ។ ទំនាស់រវាងអ្នកនេសាទទ្រង់ទ្រាយតូច និងអ្នកនេសាទទ្រង់ទ្រាយធំមានភាពស្មុគស្មាញ ។

**ទីបី** : យុទ្ធសាស្រ្តសាមញ្ញដែលធ្លាប់អនុវត្ត ដូចជាការបង្កើតក្រុមជួយខ្លួនឯងគឺជាវិធីសាស្រ្តដ៏ល្អក្នុងការលើកកំពស់ជីវភាពរស់នៅរបស់សមាជិកសហគមន៍នេសាទ ។ ភស្តុតាងមួយចំនួនដែលបានលើកឡើងនៅក្នុងករណីសិក្សានេះគឺភាគច្រើនជាការរៀបរាប់ ប៉ុន្តែរឿងរ៉ាវទាំងនេះមិនអាចបដិសេធន៍បានឡើយ ពីព្រោះការប្រែប្រួល គឺបានកើតឡើងពិតប្រាកដមែន ហើយអាចធ្វើការអង្កេតឃើញដោយផ្ទាល់ ។ ក្រុមជួយខ្លួនឯងគឺជាក្រុមដែលត្រូវបានបង្កើតឡើងដោយមានការចូលរួមពី





គ្រួសារមួយចំនួនតូច ។ នៅក្នុងសហគមន៍នេសាទភ្លៀត កោះពងសត្វគម្រោង IDRC បានធ្វើការសម្របសម្រួលបង្កើតក្រុមសន្សំ ឬហៅថាក្រុមជួយខ្លួនឯង ចំនួន ១២ ក្រុម ដែលក្រុមនីមួយៗមានសមាជិក ៥ គ្រួសារ ហើយក្រុមនីមួយៗទទួលបានប្រាក់កម្ចីឥណទានបន្តិចបន្តួចសម្រាប់ការប្រកបមុខរបរទ្រទ្រង់ភាពជីវភាពរស់នៅ ។ ក្រុមជួយខ្លួនឯងហាក់ដូចជាមានដំណើរការល្អ ដោយសារមូលហេតុមួយចំនួន រួមមាន: (១) កិច្ចការនេះបានផ្តល់នូវផលប្រយោជន៍ដល់ប្រជាជនពីព្រោះពួកគាត់ប្រើប្រាក់កម្ចីសម្រាប់ប្រកបមុខរបរចិញ្ចឹមជីវិត ដូចជា ការចិញ្ចឹមជ្រូក និងបង្កើតសួនបន្លែ តាមលំនៅដ្ឋាន ។ (២) ក្រុមជួយខ្លួនឯងគឺជាវេទិកាមួយដែលផ្តល់ឱកាសឱ្យប្រជាជនធ្វើការរួមគ្នាជាក្រុមតូចៗ ។ (៣) ក្រុមជួយខ្លួនឯងមិនមានច្បាប់កំណត់ជាក់លាក់ឡើយ ប៉ុន្តែពួកគេមានការឯកភាពគ្នាទៅលើលក្ខខណ្ឌអំពីការប្រាក់ ការបែងចែកប្រាក់ចំណេញ និងការសងត្រឡប់ ។ (៤) ក្រុមជួយ ខ្លួនឯងត្រូវបានបង្កើតឡើង ដើម្បីផ្តល់ឥណទានដែលជាបញ្ហាសំខាន់នៅតាមតំបន់ជនបទនៃប្រទេសកម្ពុជា ។ ណារី (២០០៦) ពន្យល់ថាមានប្រជាជនតាមជនបទក្នុងប្រទេសកម្ពុជាចំនួន ១៥ ៉% ប៉ុណ្ណោះទទួលបានឥណទាន ក្នុងនោះប្រមាណ ៥០% បានមកពីធនាគារអេស៊ីលីដា និងស្ថាប័នមីក្រូឥនទាន EMT ។ គ្រួសារមិនអាចខ្ចីប្រាក់ពីស្ថាប័នមីក្រូហិរញ្ញវត្ថុទាំងនោះបានឡើយ ប្រសិនគ្រួសារទាំងនោះមានប្រាក់ចំណូលទាប និងមិនទៀតទាត់ ឬពុំមានទ្រព្យដាក់បញ្ចាំ ឬសងត្រឡប់ជាមួយនឹងអត្រាការប្រាក់ខ្ពស់ ។ ជាញឹកញាប់គ្រួសារក្រីក្រទាំងនោះតែងតែទៅរកខ្ចីប្រាក់ពីប្រភពឥណទានមិនផ្លូវការ ដូចជា ឈ្មួញកណ្តាល ឬអ្នកជំនួញ ។ ការបង្កើត ក្រុមជួយខ្លួនឯងនេះត្រូវបានបង្កើតឡើងដើម្បីទទួលបាននូវប្រាក់កម្ចីឥណទានដែលបំពេញចន្លោះខ្វះខាតនៃការផ្តល់សេវាកម្មឥណទាននៅតំបន់ជនបទ ។

**ទីបួន** : ទីផ្សារមានឥទ្ធិពលដល់ការធ្វើសេចក្តីសម្រេចក្នុងការប្រើប្រាស់ និងការធ្វើអាជីវកម្មលើធនធាន ។ បទពិសោធន៍នៅថ្មស និងកំពង់ក្រសាំងគឺជាឧទាហរណ៍នៃបញ្ហានេះ ។ នៅកំពង់ក្រសាំង កសិករសម្រេចចិត្តប្រើប្រាស់ជីគីមី និងថ្នាំសំលាប់សត្វល្អិត ដើម្បីបង្កើនទិន្នផលស្រូវដែលការអនុវត្តដូចនេះនាំឱ្យប៉ះពាល់ដល់ប្រព័ន្ធព្រែកដែលនៅក្បែរស្រែនោះ ។ នៅក្នុងតំបន់ថ្មស ការកើនឡើងនូវតម្រូវការបង្គាធ្វើឱ្យមានការទាក់ទាញដល់អ្នកនេសាទក្នុងការប្រើប្រាស់ឧបករណ៍ឪនដែលជាឧបករណ៍នេសាទមានប្រសិទ្ធភាពក្នុងការចាប់បង្គា។ ឥទ្ធិពលទីផ្សារលើការប្រើប្រាស់ធនធានមិនទាន់ត្រូវបានសិក្សាឱ្យស៊ីជម្រៅនៅឡើយទេ ដោយសារនាពេលបច្ចុប្បន្នសហគមន៍នេសាទកំពុងយកចិត្តទុកដាក់ខ្ពស់ទៅលើការគ្រប់គ្រង និងអភិរក្សធនធាន ។

**ទីប្រាំ** : ចំណុចរួមមួយដែលរកឃើញក្នុងករណីសិក្សាទាំងអស់គឺ តើត្រូវដោះស្រាយបញ្ហាសហគមន៍នេសាទដោយរបៀបណានៅចំពោះមុខជម្រើសតិចតួចនៃជីវភាពរស់នៅ និងការពឹងផ្អែកទាំងស្រុងលើធនធានជលផល ។ លទ្ធផលនៃការស្រាវជ្រាវរបស់ Campell et al. (2005) គឺជាលទ្ធផលដ៏សំខាន់ដែលបានលើកឡើងអំពីមុខរបរចិញ្ចឹមជិវិតរបស់ប្រជាជននៅតំបន់ឆ្នេរសមុទ្រ ។ ការស្រាវជ្រាវនេះ និងការស្រាវជ្រាវផ្សេងទៀតដោយ Sophal and Achary (2002) បានរកឃើញថា សមាជិកក្នុងគ្រួសារប្រកបរបរចិញ្ចឹមជីវិតច្រើនប្រភេទ ។ ចំពោះករណីសិក្សា នៅក្នុងសៀវភៅនេះបង្ហាញថា



គ្រួសារអ្នកនេសាទមានមុខរបរចំរុះច្រើនមុខ ដូចជានេសាទត្រី ធ្វើស្រែ ដាំដំណាំ ចិញ្ចឹមសត្វ ស៊ីឈ្នួលគេ និងមានមុខជំនួញខ្លួនឯង ដូចជាលក់គ្រឿងទេសជាដើម ។ ធម្មតា គ្រួសារក្រីក្រពុំមានដីសម្រាប់ធ្វើកសិកម្ម ឬមានសត្វសម្រាប់ចិញ្ចឹមទេ ។ សកម្មភាពចំរុះ ដែលពាក់ព័ន្ធនឹងការធានាឱ្យបាននូវសេចក្តីសុខរបស់គ្រួសារគឺមានភាពខុសគ្នាពីសហគមន៍នេសាទមួយទៅសហគមន៍នេសាទមួយទៀត ប៉ុន្តែអ្វីដែលមានលក្ខណៈរួមនោះគឺទាក់ទងនឹងការសម្រេចចិត្តរបស់គ្រួសារនីមួយៗក្នុងការផ្លាស់ប្តូរមុខរបរដើម្បីស្វែងរកស្បៀងឱ្យបានគ្រប់គ្រាន់សំរាប់គ្រួសារ និងបំពេញសេចក្តីត្រូវការផ្សេងទៀតសម្រាប់ការរស់នៅរបស់ខ្លួន ។ ប្រជាជននៅភ្នៀត កោះពងសត្វធ្វើចំណាកស្រុកដើម្បីប្រកបមុខរបរដែលធានាដល់សេចក្តីសុខរបស់គ្រួសារ ។ លទ្ធផលនៃករណីសិក្សាបង្ហាញថា បញ្ហាជីវភាពរស់នៅមិនអាចកាត់ផ្តាច់ពីបញ្ហាគ្រប់គ្រង និងអភិរក្សធនធានធម្មជាតិបានទេ ។ លទ្ធផលសិក្សាក៏បានបង្ហាញផងដែរថា អ្នកនេសាទតែងតែរកមធ្យោបាយទប់ទល់នឹងភាពចៃដន្យដែលអាចកើតមានឡើង ទន្ទឹមនឹងពេលដែលពួកគេមានជម្រើសតិចតួចនៃមុខរបរសម្រាប់ទ្រទ្រង់ ជីវភាពរស់នៅ និងពឹងផ្អែកទាំងស្រុងលើធនធានធម្មជាតិ ។

ផ្អែកលើលទ្ធផលនៃការវិភាគខាងលើ អនុសាសន៍មួយចំនួនដូចខាងក្រោមត្រូវបានដាក់ចេញ ដើម្បីអនុវត្តការងារគ្រប់គ្រងសហគមន៍នេសាទទៅថ្ងៃអនាគតឱ្យកាន់តែល្អប្រសើរឡើង ៖

១. កិច្ចការគ្រប់គ្រងសហគមន៍នេសាទចាំបាច់ត្រូវបង្កើតទំនាក់ទំនងជាមួយក្រុមផ្សេងទៀតដែលមានក្នុងសហគមន៍ ដូចជាសមាគមន៍ ឬគណៈកម្មាការដែលបានបង្កើតជាយូររួចមកហើយដោយប្រជាជននៅមូលដ្ឋាន (Sedara & Sovatha, 2005) ។ គណៈកម្មាធិការវត្ត និងគណៈកម្មាធិការសាលារៀន គឺជាឧទាហរណ៍របស់ក្រុមផ្សេងៗ ក្នុងសហគមន៍ ។ គណៈកម្មការវត្តមានឥទ្ធិពលពិសេស ក្នុងការជំរុញឱ្យប្រជាជនចូលរួមនៅក្នុងការងារសហគមន៍នេសាទដោយសារវត្តវត្តជាកន្លែងជួបជុំរបស់ប្រជាជន ។

២. កិច្ចសហការក្នុងការងារសហគមន៍នេសាទត្រូវមានភាពទូលំទូលាយលើសពីការកំរិតថ្នាក់ភូមិ និងឃុំ ។ មានឱកាសជាច្រើនក្នុងការសិក្សាស្រាវជ្រាវតាមវិធីសាស្ត្រប្រកបដោយការច្នៃប្រឌិត ដើម្បីអភិវឌ្ឍសហគមន៍នេសាទ ជាពិសេសនៅកំរិតថ្នាក់ខេត្ត ។ បើពិនិត្យនៅថ្នាក់ភូមិ និងឃុំ បញ្ហាគ្រប់គ្រងធនធានធម្មជាតិមិនទាន់ត្រូវបានកំណត់ឱ្យបានច្បាស់លាស់នៅឡើយ ។ ជាការពិត គឺនៅមានឱកាសជាច្រើនដែលអាចធ្វើការពិសោធន៍ និងរកឱ្យឃើញនូវវិធីសាស្ត្រប្រកបដោយគំនិតច្នៃប្រឌិត ដើម្បីឱ្យការគ្រប់គ្រងសហគមន៍នេសាទទទួលបានលទ្ធផលកាន់តែប្រសើរឡើង។

៣. ការយល់ដឹងអំពីឥទ្ធិពលទីផ្សារលើការគ្រប់គ្រងសហគមន៍នេសាទ គឺជាចំណុចមួយយ៉ាងសំខាន់ ប៉ុន្តែបច្ចុប្បន្នការងារគ្រប់គ្រងសហគមន៍នេសាទពុំទាន់បានគិតគូនៅឡើយ ។ ដូចនេះ តម្រូវឱ្យមានការស្រាវជ្រាវបន្ថែមទៀតដើម្បីបញ្ជាក់

ឱ្យបានច្បាស់នូវឥទ្ធិពលទីផ្សារលើការប្រើប្រាស់ និងគ្រប់គ្រងធនធាននេសាទ ។

៤. តើក្រុមណាដែលជាក្រុមងាយរងគ្រោះជាងគេ? ក្រុមជួយខ្លួនឯងសម្រាប់កម្មវិធីផ្តល់ឥណទានខ្នាតតូច គឺរួមបញ្ចូលតែតែសមាជិកណា ដែលមានលទ្ធភាពអាចសងបំណុលវិញបានតែប៉ុណ្ណោះ ។ ការសម្រេចបែបនេះគឺជាការសម្រេចដ៏សមរម្យ ព្រោះថាគម្រោងមិនចង់ជួបប្រទះនឹងភាពចៃដន្យឡើយ ។ ប៉ុន្តែ តើការឧបត្ថម្ភឥណទាននេះពិតជាបានបម្រើផលប្រយោជន៍ដល់ប្រជាជនដែលងាយរងគ្រោះបំផុត និងក្រីក្របំផុតនៅក្នុងសហគមន៍ដែរឬទេ? បញ្ហានេះតម្រូវឱ្យមានការវិភាគច្រើនថែមទៀតដើម្បីស្វែងរកក្រុមជនដែលក្រីក្រ និងងាយរងគ្រោះបំផុតក្នុងសហគមន៍នេសាទ ។

៥. ការស្វែងយល់ឱ្យបានច្បាស់លាស់នៃលក្ខខណ្ឌចិញ្ចឹមជីវិតរបស់ប្រជាជននៅមូលដ្ឋាន គឺជាតំរូវការចាំបាច់នៅពេលអនាគត ។ ការយល់ដឹងពីវិធីសាស្ត្រចិញ្ចឹមជីវិត និងការសម្រេចចិត្ត ដើម្បីសំរបខ្លួនទៅតាមការប្រែប្រួល និងហានិភ័យ គឺជាប្រការសំខាន់ក្នុងការគ្រប់គ្រងសហគមន៍នេសាទ ។ របៀបដែលប្រជាជនអាចពង្រីកជម្រើសផ្សេងៗសម្រាប់ចិញ្ចឹមជីវិតក៏ជាកង្វល់ធំមួយដែរ ។ គេគួរតែពិចារណាផងដែរថាតើគោលនយោបាយអ្វីខ្លះ ដែលអាចជួយដល់ការលើកកំពស់ជីវភាពរស់នៅរបស់សមាជិកសហគមន៍នេសាទ ។ ប្រការដ៏សាមញ្ញនេះគឺការស្វែងយល់ពីកត្តាផ្សេងៗ ដែលបង្កឱ្យមានការប្រែប្រួលលក្ខខណ្ឌជីវភាពរស់នៅ ដើម្បីធានាដល់ជីវភាពរស់នៅរបស់ប្រជាជននៅមូលដ្ឋាន ។

## REFERENCES


Campbell, Jock et.al. 2005. Understanding the Factors that Support and Inhibit Livelihood Diversification in Coastal Cambodia. IMM Ltd, CFDO and CBNRM LI.

Marschke, Melissa and Kim Nong. 2003. Adaptive Co-Management: Lessons from Coastal Cambodia. Canadian Journal of Development Studies. 24(3): 369-383.

Marschke, M. 2003. From Planning to Action: What can resources management committees do "on the ground", Cambodia Development Review, (7)3: 7-10,12.

Navy, Hap. 2006. The Role of Formal and Informal Credit in the Fish Marketing Chain, Cambodia. An output from the DFID-funded Post-Harvest Fisheries Livelihoods Project. Department of Fisheries, Phnom Penh, Cambodia.

Oberndorf, Robert B. J.D. 2005. Working Paper 31: Law Harmonisation in Relation to the Decentralisation Process in Cambodia. Cambodia Development Research Institute, Phnom Penh, Cambodia,52 pp

Sedara, Kim and Ann Sovatha. 2005. Decentralisation: Can Civil Society Enhance Local Government's Accountability in Cambodia? Cambodia Development Review. Vol 9, Issue 3, July-September

Sophal, Chan and Sarthi Acharya. 2002. Facing the Challenge of Rural Livelihoods: A Perspective from Nine Villages in Cambodia Working Paper 25. Cambodia Development Resource Institute, Phnom Penh.



# ឧបសម្ព័ន្ធទី១

## អ្នករួមសហការនៅក្នុងគម្រោង

### ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ Community Fisheries Development Office (CFDO)

នៅខែមករា ឆ្នាំ ២០០៤ ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទបានកំណត់នូវទស្សនវិស័យបេសកកម្ម និងគោលដៅ(VMG) របស់ខ្លួន ដោយឈរលើមូលដ្ឋាននៃផែនការមេនៃវិស័យជលផលឆ្នាំ ២០០១ ២០១១ របស់រដ្ឋបាលជលផល ។ ទស្សនវិស័យរបស់ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទគឺ "សំឡឹងឃើញការបង្កើតសហគមន៍នេសាទនៅទូទាំងប្រទេសប្រកបដោយភាពរឹងមាំ ហើយអាចទទួលខុសត្រូវដោយខ្លួនឯងបាន ព្រមទាំងធានាបាននូវការប្រើប្រាស់ និងគ្រប់គ្រងធនធានជលផលនៅក្នុងមូលដ្ឋានរបស់ខ្លួនប្រកបដោយសមធម៌ និងមាននិរន្តរភាពក្រោមការជួយឧបត្ថម្ភគាំទ្រពីការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និងការិយាល័យជលផលខេត្ត-ក្រុង ក្នុងគោលដៅលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនដែលពឹងផ្អែកលើធនធានជលផល " ។ ដើម្បីសម្រេចបាននូវទស្សនវិស័យនេះ ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទដាក់ចេញនូវបេសកកម្មដូចខាងក្រោម :

- បង្កើត និងផ្សព្វផ្សាយក្របខ័ណ្ឌច្បាប់ (រួមមានច្បាប់ និងបទដ្ឋានពាក់ព័ន្ធនានា)
- កំណត់ព្រំប្រទល់នៃសហគមន៍នេសាទ
- រៀបចំការចុះបញ្ជីជាផ្លូវការដល់សហគមន៍នេសាទ
- កសាងសមត្ថភាពសម្រាប់ការគ្រប់គ្រងសហគមន៍នេសាទ
- ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពរបស់សហគមន៍នេសាទ
- សិក្សាស្រាវជ្រាវអំពីសហគមន៍នេសាទ
- ដោះស្រាយជម្លោះ
- លើកកំពស់ជីវភាពរស់នៅរបស់សហគមន៍នេសាទ ប្រកបដោយនិរន្តរភាព

នៅឆ្នាំ ២០០៤ រដ្ឋបាលជលផលបានរៀបចំផែនការសកម្មភាពរយៈពេល ៥ ឆ្នាំ របស់ខ្លួនសម្រាប់ឆ្នាំ ២០០៥ ដល់ឆ្នាំ ២០០៨ ។ ផែនការនេះត្រូវបានរៀបចំឡើងដោយផ្អែកលើគោលដៅនៃវិស័យជលផលដើម្បី "ផ្តល់នូវការរួមចំណែកឱ្យបានជាអតិបរមារបស់វិស័យជលផលដល់ការធ្វើឱ្យសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ ជាពិសេសពាក់ព័ន្ធនឹងការលើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រនៅជនបទ ការលើកកំពស់សន្តិសុខស្បៀង ការអភិវឌ្ឍប្រកបដោយនិរន្តរភាព និងការប្រើប្រាស់ធនធានជលផលប្រកបដោយសមធម៌ " ។ ផែនការនេះត្រូវបានរៀបចំឡើងដោយផ្អែកលើក្របខណ្ឌគោល



នយោបាយបានទូលំទូលាយដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គម និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងស្របតាមតម្រូវការនៃយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា ។

ដើម្បីឈានទៅសំរេចគោលដៅខាងលើ គ្រប់ការិយាល័យ និងផ្នែកទាំងអស់របស់រដ្ឋបាលជលផលនឹងបំពេញភារកិច្ចដោយផ្តោតទៅលើសកម្មភាពអាទិភាពចំនួន ៦ ដូចខាងក្រោម ៖

១. ពិនិត្យឡើងវិញ និង កែសម្រួលនយោបាយ ផែនការ លិខិតបទដ្ឋានគតិយុត្តិ រចនាសម្ព័ន្ធ និងសមត្ថភាព (មនុស្ស និងមធ្យោបាយ)នៅក្នុងវិស័យជលផល
២. ពង្រីកបន្ថែមនូវកន្លែងនេសាទសម្រាប់ការនេសាទជាលក្ខណៈគ្រួសារតាមរយៈកំណែទម្រង់ឡូត៍នេសាទ
៣. បង្កើនផលស្តុកនេសាទតាមរយៈការអភិរក្ស និងការសិក្សាស្រាវជ្រាវ
៤. ជម្រុញការគ្រប់គ្រងធនធានជលផលដោយសហគមន៍ ដើម្បីលើកកំពស់ការចូលរួមរបស់ប្រជាពលរដ្ឋងការគ្រប់គ្រជលផល នៅក្នុងមូលដ្ឋានដែលផ្សារភ្ជាប់នឹងជីវភាពរស់នៅរបស់ខ្លួន
៥. លើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រនៅជនបទ តាមរយៈការពង្រឹងមុខនាទីរបស់វិស័យជលផលក្នុងសន្តិសុខស្បៀង ការផ្តល់នូវការងារ និងការរកប្រាក់ចំណូល ដោយធានាឱ្យបាននូវការប្រើប្រាស់ធនធានទាំងនេះប្រកបដោយនិរន្តរភាពនិងការលើកកំពស់កំរិតផលិតកម្មតាមគ្រួសារនីមួយៗ និងសហគមន៍តាមរយៈការអភិវឌ្ឍវារីវប្បកម្មជនបទ ។
៦. លើកកំពស់ជីវភាពរស់នៅរបស់ប្រជាជនក្រីក្រ តាមរយៈការបង្កើនសមត្ថភាពប្រើប្រាស់ផលិតផលត្រីឱ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការលើកកំពស់ការអភិវឌ្ឍខ្សែសង្វាក់ផលិតកម្មជលផល ។

ក្នុងអំឡុងពេលប៉ុន្មានឆ្នាំកន្លងទៅនេះ ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទបានប្រឈមមុខទៅនឹងការលំបាក និងចំណាយពេលវេលាយ៉ាងច្រើនក្នុងការកសាងសមត្ថភាពរបស់ខ្លួនដើម្បីគាំទ្រដល់សហគមន៍នេសាទ ។ ជាក់ស្តែង កិច្ចសហប្រតិបត្តិការ និងការជួយឧបត្ថម្ភពីដៃគូផ្តល់ជំនួយ និងភាគីពាក់ព័ន្ធផ្សេងៗទៀតមានតួនាទីយ៉ាងសំខាន់ក្នុងការកសាងសមត្ថភាពនិងបង្កើននូវបទពិសោធន៍ពាក់ព័ន្ធនឹងសហគមន៍នេសាទដល់ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ ។ ខាងក្រោមនេះ គឺជាគម្រោងមួយចំនួនដែលបានអនុវត្ត នៅក្នុងការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទក្នុងរយៈពេលកន្លងមក ៖

- នៅចុងឆ្នាំ ២០០០ និងដើមឆ្នាំ ២០០១ គម្រោងគ្រប់គ្រងនេសាទទឹកសាបកម្ពុជា (MRC) បានផ្តល់នូវការជួយឧត្ថម្ភជាលើកដំបូងក្នុងការរៀបចំការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ ដោយបានបណ្តុះបណ្តាលសមត្ថភាពដល់មន្ត្រីការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និងមន្ត្រីទទួលខុសត្រូវផ្នែកអភិវឌ្ឍន៍សហគមន៍នេសាទនៅក្នុងខេត្តមួយចំនួន ។
- គម្រោង STREA ចាប់ពីដើមឆ្នាំ ២០០១ មកបានផ្តល់អ្នកស្ម័គ្រចិត្ត ១ រូប ដើម្បីជួយដល់ការិយាល័យអភិវឌ្ឍន៍



- ❖ សហគមន៍នេសាទក្នុងការរៀបចំដំណើរការរបស់ខ្លួនដូចជាការរៀបចំផែនការយុទ្ធសាស្ត្រសម្រាប់ការិយាល័យជាដើម ។ គម្រោង STREAM ក៏បានជួយដល់ប្រព័ន្ធទំនាក់ទំនងជាមួយអ្នកពាក់ព័ន្ធ ជាពិសេសជាមួយបណ្តាប្រទេសជិតខាង ។
- ❖ គម្រោង IDRC បានជួយដល់ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទចាប់ពីឆ្នាំ ២០០៣ ហើយបន្តរហូតមកដល់ដំណាច់ខែ កញ្ញា ឆ្នាំ ២០០៦ ។ គម្រោងនេះបានជួយពង្រឹងសមត្ថភាពមន្ត្រីការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ និង គាំទ្រដល់ ការបង្កើតសហគមន៍ គំរូចំនួន ៣ គឺសហគមន៍នេសាទនៅក្នុងខេត្តបន្ទាយមានជ័យចំនួន ១ សហគមន៍នេសាទខេត្ត តាកែវចំនួន ១ និង សហគមន៍ នេសាទនៅក្នុងខេត្តកោះកុងចំនួន ១។
- ❖ គម្រោងគ្រប់គ្រងអាងទឹក MRC ត្រូវបានអនុវត្តនៅក្នុងការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ ចាប់តាំងពីឆ្នាំ ២០០៣ រហូតដល់ឆ្នាំ ២០០៦ ។ គម្រោងនេះបានជួយបង្កើត និងឧបត្ថម្ភដល់សហគមន៍នេសាទមួយចំនួននៅក្នុងខេត្តកំពង់ចាម ខេត្តកណ្តាល រាជធានីភ្នំពេញ និងខេត្តកំពង់ឆ្នាំង ។
- ❖ គម្រោង UNDP បានជួយដល់ការិយាល័យអភិវឌ្ឍន៍សហគមន៍ក្នុងការកសាងសមត្ថភាពមន្ត្រីការិយាល័យអភិវឌ្ឍន៍នេសាទ និងមន្ត្រីផ្នែកអភិវឌ្ឍន៍សហគមន៍នេសាទនៅក្នុងខេត្តចំនួន ៦ ជុំវិញបឹងទន្លេសាបគឺ ខេត្តកំពង់ធំ សៀមរាប បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ និងខេត្តកំពង់ឆ្នាំង ។ គម្រោងនេះ ចាប់ផ្តើមអនុវត្តតាំងពីខែកក្កដា ឆ្នាំ ២០០៣ ហើយបានបញ្ចប់នៅក្នុងខែ មិថុនា ឆ្នាំ ២០០៦ ។
- ❖ គម្រោងគ្រប់គ្រងបរិស្ថានបឹងទន្លេសាប ជាគម្រោងប្រាក់កំចីឥណទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ដែលជួយដល់ការពង្រឹង សហគមន៍នេសាទនៅក្នុងតំបន់ឋបនីជីវមណ្ឌលបឹងទន្លេសាបដែលមានខេត្តចំនួន ៥ គឺ ខេត្តកំពង់ធំ សៀមរាប បាត់ដំបង ពោធិ៍សាត់ និង ខេត្តកំពង់ឆ្នាំង។ គម្រោងនេះមានរយៈ ពេល ៥ ឆ្នាំ ហើយអនុវត្តចាប់ពីឆ្នាំ ២០០៣ រហូតដល់ ឆ្នាំ ២០០៨។

## វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ (CBNRM LI)

វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយការចូលរួមពីសហគមន៍ គឺជាវិទ្យាស្ថានមួយដែលបានផ្តួចផ្តើមគំនិតជាលើកដំបូងក្នុងការចងក្រងករណីសិក្សា និងរៀបចំបង្កើតបណ្តាញការងារនៃការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ដោយចាប់ផ្តើមឡើងតាំងពីខែមិថុនា ឆ្នាំ២០០១ មក ដើម្បីឆ្លើយតបទៅនឹងតម្រូវការកាន់តែច្រើនឡើងក្នុងការកសាងចំណេះដឹងជំនាញ និងអាកប្បកិរិយា ដែលជាកិច្ចការដ៏សំខាន់នៃវិធីសាស្ត្រដោយមានការចូលរួម ជាពិសេសការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ។ ចាប់តាំងពីពេលចាប់ផ្តើមមក វិទ្យាស្ថាន CBNRM LI បាននឹងកំពុងបំពេញការងារជួយពង្រឹង និងបង្កើនទំនាក់ទំនងក្នុងចំណោមគម្រោងគ្រប់គ្រងធនធានធម្មជាតិនានានៅថ្នាក់មូលដ្ឋានដែលអាចបង្កើននូវសិទ្ធិអំណាចដល់សហគមន៍មូលដ្ឋាន ដើម្បីចូលរួមយ៉ាងសកម្មក្នុងការអភិរក្ស និងគ្រប់គ្រងធនធានធម្មជាតិ ប្រកបដោយនិរន្តរភាពតាមរយៈសហគមន៍ព្រៃឈើ (CFo) សហគមន៍នេសាទ (CF) ការចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លី



(PLUP) និងការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយមានការចូលរួម ។ នៅឆ្នាំ២០០៣ វិទ្យាស្ថាន CBNRM LI បានកែប្រែទ្រង់ទ្រាយពីគម្រោងទៅជាវិទ្យាស្ថានដែលមានចក្ខុវិស័យយូរអង្វែង មិនត្រឹមតែជួយអភិវឌ្ឍន៍គំនិតរបស់ប្រជាជនកម្ពុជាអំពីការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាវិទ្យាស្ថានថ្នាក់តំបន់មួយដោយធ្វើការផ្សារភ្ជាប់ និងកសាងភាពជាដៃគូជាមួយនឹងការិយាល័យ និងបណ្តាញការងារថ្នាក់តំបន់ដែលអនុវត្តការងារទាក់ទងនឹងការគ្រប់គ្រងធនធានធម្មជាតិដោយការចូលរួម ។ ដៃគូសំខាន់ៗរបស់វិទ្យាស្ថាននៅដំណាក់កាលដំបូងរួមមាន WWF, IDRC, OA និង RECOFTC ។

បច្ចុប្បន្ននេះវិទ្យាស្ថាន CBNRM LI គឺជាអង្គការមិនមែនរដ្ឋាភិបាលមិនស្វែងរកកំរៃដែលមានបេសកកម្មធ្វើការវិភាគ និងកែលំអវិធីសាស្ត្រ CBNRM ដែលជាផ្នែកសំខាន់ក្នុងការកាត់បន្ថយភាពក្រីក្រ បង្កើនជីវភាពរស់នៅ និងការគ្រប់គ្រង និងអភិរក្សធនធានប្រកបដោយចីរភាព និងគោលនយោបាយ និងយុទ្ធសាស្ត្រវិមជ្ឈការនៃរាជរដ្ឋាភិបាលកម្ពុជា ។ ក្រៅពីនេះ វិទ្យាស្ថានធ្វើការវាយតម្លៃឥទ្ធិពល នៃការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍នៅតាមកំរិតផ្សេងៗ សម្រួលការចូលរួមរបស់ប្រជាជនក្នុងកិច្ចការ CBNRM នៅក្នុងប្រទេសកម្ពុជា និងនៅក្នុងតំបន់ដើម្បីសិក្សា និងចែករំលែកបទពិសោធន៍ពីគ្នាទៅវិញទៅមក ។

CBNRM LI មានគោលបំណងសំខាន់ ៤ ដូចខាងក្រោម :

- **ការអភិវឌ្ឍធនធានមនុស្ស :** ដើម្បីពង្រឹង ឬបង្កើនជំនាញក្នុងការវិភាគ ការសិក្សាស្រាវជ្រាវ និងការចងក្រងឯកសារសម្រាប់អ្នកសម្របសម្រួល អ្នកស្រាវជ្រាវ និងអ្នកអនុវត្តនៅតាមអង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នរដ្ឋនៅថ្នាក់ជាតិ ខេត្ត និងមូលដ្ឋានដែលជាដៃគូរបស់វិទ្យាស្ថាន CBNRM LI
- **កសាង និងចែករំលែកចំណេះដឹង :** ដើម្បីកំណត់ វិភាគ និងចែករំលែកមេរៀនគំរូ និងបទពិសោធន៍ នៃវិធីសាស្ត្រនានាក្នុងការគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ នៅទូទាំងប្រទេស
- **ការរៀបចំភាពជាដៃគូ :** ដើម្បីរៀបចំទំនាក់ទំនងក្នុងការកសាងបណ្តាការងារជាមួយអង្គការ និងស្ថាប័នដែលគាំទ្រលើយុទ្ធសាស្ត្រគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់
- **ការរៀបចំស្ថាប័ន និងការគាំទ្រខាងគោលនយោបាយ :** ដើម្បីធ្វើឱ្យល្អប្រសើរឡើងនូវសមត្ថភាពតាមស្ថាប័ន និងការយល់ដឹងពីខ្លឹមសារគោលនយោបាយ ដែលមានឥទ្ធិពលដល់ការអនុវត្ត CBNRM នៅថ្នាក់មូលដ្ឋាន ។

វិទ្យាស្ថានបានបង្កើតដៃគូការងារជាមួយវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវផ្សេងៗទៀតក្នុងប្រទេសកម្ពុជា ដូចជា វិទ្យាស្ថានអភិវឌ្ឍន៍ធនធានកម្ពុជា មជ្ឈមណ្ឌល d'étude et de Development Agriculture Cambodgien មជ្ឈមណ្ឌលបណ្តុះបណ្តាលព្រៃឈើ វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍នេសាទទឹកសាប និងគំរោងសិក្សាទន្លេមេគង្គ ។



វិទ្យាស្ថានក៏មានបណ្តាញយ៉ាងច្រើនទៀតជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ ដូចជា ការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទនៃរដ្ឋបាលជលផល ការិយាល័យសហគមន៍ព្រៃឈើនៃរដ្ឋបាលព្រៃឈើ ការិយាល័យអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ (CPADO) នៃនាយកដ្ឋានការពារនិងអភិរក្សធម្មជាតិក្រសួងបរិស្ថាន ផ្នែកទំនាក់ទំនង PLUP នៃក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ និងកម្មវិធីសិលា ។ លើសពីនេះទៅទៀត វិទ្យាស្ថានមានទំនាក់ទំនង ជាមួយគ្រឹះស្ថានសិក្សាផ្សេងៗ ដូចជា សាកលវិទ្យាល័យភូមិន្ទកសិកម្ម និងដេប៉ាតាម៉ង់វិទ្យាសាស្ត្របរិស្ថាន និងទេសចរណ៍នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ។

នៅថ្នាក់តំបន់ វិទ្យាស្ថានមានទំនាក់ទំនងការងារជាមួយនឹងមជ្ឈមណ្ឌលក្សេត្រសាស្ត្រព្រៃឈើពិភពលោក និងវិទ្យាស្ថានអន្តរជាតិសំរាប់កសាងជនបទ ដែលមានមូលដ្ឋាននៅក្នុងប្រទេសហ្វីលីពីន មជ្ឈមណ្ឌលសំរាប់ជីវចម្រុះ និងចំណេះដឹងជនជាតិដើមនៅប្រទេសចិនភាគនីរតី RECOFT នៅប្រទេសថៃ និងមជ្ឈមណ្ឌលសំរាប់ស្រាវជ្រាវព្រៃឈើ អន្តរជាតិក្នុងប្រទេសឥណ្ឌូនេស៊ី ។ ក្នុងនាមជាដៃគូជាមួយការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ វិទ្យាស្ថានគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួមពីសហគមន៍ ផ្តល់ជំនួយបច្ចេកទេសលើការបណ្តុះបណ្តាល ការស្រាវជ្រាវ ការសរសេរករណីសិក្សា បណ្តាញការងារ និងវេទិកាសិក្សារៀនសូត្រ ។



# ឧបសម្ព័ន្ធទី ២
## ការឆ្លុះបញ្ចាំងសំដីរបស់អ្នកសរសេរនៅលើដំណើរការនៃការសរសេរករណីសិក្សា

### លោក ជាម ប៉េអា

ខ្ញុំបានរៀនអំពីសារសំខាន់នៃការផ្តល់នូវមតិយោបល់ចំពោះការគ្រប់គ្រងសហគមន៍នេសាទ ហើយបង្ហាញអំពីរបៀបដែលអាចបំពេញការងារបានជោគជ័យ។ ករណីសិក្សានេះអាចជាការជម្រុញដល់ការចូលរួមរបស់ភាគីផ្សេងៗទៀត។

### លោក ស៊ុក ទិន

ដំណើរការ និងជំហាននៃការរៀបចំសិក្សាស្រាវជ្រាវករណីនេះសិក្សាមានភាពសាមញ្ញងាយយល់ និងច្បាស់លាស់ល្អ។ ប៉ុន្តែមានការលំបាកខ្លះៗក្នុងការប្រមូលព័ត៌មាន ហើយការលំបាកជាងគេនៅក្នុងដំណើរការទាំងមូលនោះ គឺការវិភាគព័ត៌មានដែលប្រមូលបានពីមូលដ្ឋានដើម្បីចងក្រងជាអត្ថបទនៃករណីសិក្សានេះ។

### លោក រុន វិសិទ្ធ

ខ្ញុំមានការពេញចិត្តចំពោះរបៀបនៃការពិភាក្សាអំពីបញ្ហាសម្រាប់ករណីសិក្សា និងខ្លឹមសារគន្លឹះដែលអាចធ្វើឱ្យខ្ញុំអាចរៀបចំបញ្ជីសំនួរសម្រាប់ចុះទៅមូលដ្ឋានបាន។ ការចូលរួមរបស់ខ្ញុំពេលដំបូងគឺមានពុំមានពេលវេលាគ្រប់គ្រប់គ្រាន់ឡើយ ដោយខ្ញុំជាប់រវល់ក្នុងការសរសេរសារណាបទបញ្ចប់ការសិក្សាផ្ទាល់ខ្លួន។ ខ្ញុំបានដឹងថាពុំមែនជាការងាយស្រួលក្នុងការវិភាគទិន្នន័យឡើយ។

### លោក នូ លាង

ដំណើរការនេះមានការចាប់អារម្មណ៍ជាខ្លាំងចំពោះខ្ញុំ ពីព្រោះក្រុមរបស់យើងបានធ្វើការផ្លាស់ប្តូរនូវមតិយោបល់ និងបទពិសោធន៍ទៅវិញទៅមកអំពីសហគមន៍នេសាទ។ ភាពកម្សោយរបស់យើងគឺការសរសេរប៉ុន្តែពួកយើងជួយគ្នាទៅវិញទៅមក។

### កញ្ញា យិន គីមសួរ

ខ្ញុំសូមថ្លែងអំណរគុណចំពោះការផ្តល់ឱកាសខ្ញុំបានចូលរួមនៅក្នុងដំណើរការសិក្សាស្រាវជ្រាវករណីសិក្សានេះ។ ខ្ញុំរៀនសូត្របានច្រើនអំពីទស្សនទាន និងបទពិសោធន៍នៅមូលដ្ឋាន។ ខ្ញុំមានការពេញចិត្តជាខ្លាំងចំពោះការដែលយើងធ្វើការសិក្សាស្រាវជាក្រុម ហើយបានធ្វើការពិភាក្សាជាមួយប្រជាពលរដ្ឋមូលដ្ឋានដោយផ្ទាល់។ ការដែលយើងជួបជុំគ្នាដើម្បី



ពិភាក្សា និងធ្វើការឆ្លុះបញ្ចាំងដើម្បីទទួលនូវការផ្តល់យោបល់ទៅវិញទៅមក គឺជាកិច្ចការសំខាន់សម្រាប់ក្រុមអ្នកសរសេរនីមួយៗ ពីព្រោះនៅក្នុងជំហាននេះយើងទាំងអស់គ្នាបានទទួលនូវការណែនាំពីគ្នាទៅវិញទៅមក ហើយជាពិសេសពីអ្នកសម្របសម្រួល។

**លោក និត តារះ**

នេះគឺជាលើកទីពីររបស់ខ្ញុំដែលបានចូលរួមក្នុងការសរសេរករណីសិក្សា ដែលទាក់ទងទៅនឹងការចិញ្ចឹមជីវិតរបស់សហគមន៍មូលដ្ឋាន។ លើសពីនេះទៅទៀត ខ្ញុំបានសិក្សានិងស្វែងយល់ឃើញថាការសហគមន៍នេសាទមានសារៈសំខាន់ណាស់ចំពោះប្រជាពលរដ្ឋក្នុងសហគមន៍មូលដ្ឋាន តាមរយៈការបង្កើនសមត្ថភាព និងការគាំទ្រផ្នែកឥណទានខ្នាតតូច ពីអ្នកពាក់ព័ន្ធទាំងអស់ ដែលបានធ្វើអោយកំរិតជីវភាពរបស់ពួកគាត់មានការប្រសើរឡើង។

**លោក ប៉ែន មករា**

ការសរសេរករណីសិក្សានេះ គឺបានរៀបចំយ៉ាងល្អ និងមានដំណើរការច្បាស់លាស់ ពីព្រោះគឺការចាប់ផ្តើមដំបូងគឺមានការបណ្តុះបណ្តាលអំពីរបៀបសរសេរករណីសិក្សា ហើយមានសិក្ខាសាលាជាបន្តបន្ទាប់រហូតដល់មានការពិភាក្សា និងពិនិត្យច្បាស់លាស់ ទើបធ្វើការបោះពុម្ពផ្សាយ។ នៅក្នុងដំណើរការសរសេរ យើងមានទីប្រឹក្សាជាអ្នកជួយផ្តល់នូវយោបល់ដែលធ្វើការសរសេរមានភាពរលូន។ ខ្ញុំមានជំនឿមុតមាំថា ឥឡូវនេះខ្ញុំអាចរៀបចំធ្វើការសិក្សាស្រាវជ្រាវករណីសិក្សាបានដោយខ្លួនឯង។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអ្នករៀបចំ និងអ្នកសម្របសម្រួល។

**លោក ណែម ភារុណ្ឌ**

ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រុមអ្នកនិពន្ធទាំងអស់ ពីព្រោះខ្ញុំបានរៀនសូត្រនូវបទពិសោធន៍ពីគ្នាទៅវិញទៅមកបានយ៉ាងច្រើន។ ខ្ញុំក៏បានរៀនសូត្រជាច្រើនពីប្រជាពលរដ្ឋនៅមូលដ្ឋាន។ ការសរសេរគឺជាតំណាក់កាលដ៏លំបាកបំផុតពីព្រោះខ្ញុំពុំមានចំណេះដឹងច្បាស់អំពីករណីរសិក្សា។ ខ្ញុំចង់ធ្វើការសិក្សាស្រាវជ្រាវរបៀបនេះម្តងទៀតប្រសិនបើមានការគាំទ្រ។

**លោក អ៊ុំ សុផាន**

នេះគឺជាលើកទី ១ ហើយដែលខ្ញុំបានចូលរួមនៅក្នុងការសរសេរករណីសិក្សានេះ។ ពីមុន ខ្ញុំមិនមិនចេះធ្វើការងារនេះឡើយ។ ជំហាននៃការសរសេរករណីសិក្សាគឺជាការចាប់អារម្មណ៍របស់ខ្ញុំយ៉ាងខ្លាំង។ ខ្ញុំគិតថា នេះគឺជាដំណើរការយ៉ាងល្អមួយ ពីព្រោះខ្ញុំអាចអនុវត្តបាននូវអ្វីដែលបានរៀនសូត្រពីគ្នាទៅវិញទៅមក។ ការសិក្សាស្រាវជ្រាវជាក្រុម គឺជាគំនិតយ៉ាងល្អ ពីព្រោះប្រសិនបើយើងសរសេរម្នាក់ឯងពិតជាជួបនូវការលំបាក។



**លោកស្រី ចាន់ រតនា**

ខ្ញុំមានការចាប់អារម្មណ៍ចំពោះរបៀបកំណត់រកខ្លឹមសារគន្លឹះ ហើយខ្ញុំអាចធ្វើបាន។ នេះគឺជាលើកទី ១ ដែលខ្ញុំបានចូលរួមនូវការសរសេរករណីសិក្សា។ វាជាការងាយស្រួលក្នុងការប្រមូលព័ត៌មាន ប៉ុន្តែវាមានការលំបាកក្នុងការរៀបចំគំនិត និងការសរសេរ។ យើងមានព័ត៌ជាច្រើនអំពីកម្មវិធីឥណទាន ប៉ុន្តែយើងមិនដឹងថាតើអ្វីខ្លះដែលត្រូវសរសេរចូល ហើយអ្វីខ្លះដែលមិនត្រូវសរសេរចូល។

**លោកព្រំ គឹមហារ**

ដំណើរការសរសេរករណីសិក្សានេះបានផ្តល់នូវផលប្រយោជន៍ជាច្រើន។ ខ្ញុំបានរៀនសូត្រអំពីករណីសិក្សាជាច្រើន ហើយបានយល់ដឹងអំពីស្ថានភាពជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅក្នុងមូលដ្ឋាន និងទំនាក់ទំនងរបស់ពួកគេជាមួយរដ្ឋអំណាចមូលដ្ឋាន និងអ្នកពាក់ព័ន្ធដទៃទៀត។ ខ្ញុំមានសេចក្តីត្រេកអរយ៉ាងខ្លាំងចំពោះការបញ្ចូលឈ្មោះខ្ញុំនៅក្នុងបញ្ជីក្រុម អ្នកនិពន្ធ។ ការលំបាកដែលខ្ញុំជួបប្រទះនៅក្នុងដំណើរការនេះ គឺប្រជាពលរដ្ឋមិនចង់ចូលរួមផ្តល់នូវព័ត៌មានឡើយ ពីព្រោះពួកគេមានការភ័យក្លាចចំពោះបញ្ហាសុវត្ថិភាពរបស់គ្រួសារពួកគេ។ ប្រជាពលរដ្ឋនៅមូលដ្ឋាន សូម្បីតែមិនឱ្យថតរូបពួកគេឡើយ។ ការធ្វើដំណើរទៅសហគមន៍ថ្មសមានការលំបាក។

**លោក សរិត សំបូរ**

យើងមានក្រុមដ៏ល្អ ហើយយើងក៏បានទទួលការជួយយ៉ាងសកម្មពីអ្នកសម្របសម្រួល។ មានការលំបាកមួយចំនួននៅក្នុងសហគមន៍ថ្មស ពីព្រោះប្រធានបទរបស់ក្រុមយើងគឺអំពីបទល្មើសនេសាទ ប៉ុន្តែរដ្ឋអំណាចមូលដ្ឋានបានជួយជ្រោមជ្រែកដល់ក្រុមសិក្សាស្រាវជ្រាវយើង ដើម្បីដោះស្រាយនូវការលំបាក។

**លោក គូ ហ៊ុយលាង**

ក្រុមរបស់យើងគឺមានប្រធានបទអំពីបទល្មើសនេសាទ ដែលជាចំណុចរសើបមួយ។ ដូច្នេះពួកយើងមានការលំបាកក្នុងការប្រមូលព័ត៌មាន។ យើងទទួលអារម្មណ៍ថា ប្រជាពលរដ្ឋនៅមូលដ្ឋានហាក់ដូចជាមិនចង់ស្វាគមន៍ពួកយើងឡើយ។ ទោះជាយ៉ាងដូច្នេះក្តី ខ្ញុំមានការរីករាយចំពោះដំណើរការទាំងមូលពីព្រោះពួកយើងអាចជួយគ្នាទៅវិញទៅមក។ ខ្ញុំបានរៀនសូត្រអំពីរបៀបនៃការកំណត់ប្រធានបទ និងខ្លឹមសារគន្លឹះ ហើយចេះរៀបចំខ្លឹមសារសំខាន់ និងរៀបចំបញ្ជីសំនួរ។



### លោក សោម ពិសិដ្ឋ

ក្នុងនាមការិយាល័យជលផលខេត្តកោះកុង ខ្ញុំមានសេចក្តីសប្បាយរីករាយចំពោះការជ្រើសរើសសហគមន៍នេសាទឃុំថ្មស ជាតំបន់គោលដៅរបស់គម្រោង និងធ្វើការសិក្សាស្រាវជ្រាវករណីសិក្សានេះ។ ហើយខ្ញុំក៏សូមថ្លែងអំណរគុណចំពោះគម្រោង IDRC ដែលបានជួយគាំទ្រ។ នេះគឺជាលើកទី ១ ដែលខ្ញុំបានចូលរួមនៅក្នុងដំណើរការនៃការសិក្សាស្រាវជ្រាវករណីសិក្សា ហើយខ្ញុំបានរៀនសូត្រជាច្រើន។ ខ្ញុំសង្ឃឹមថាយើងអាចធ្វើកិច្ចការនេះម្តងទៀតបាន។ ការទាក់ទងគ្នាមានការលំបាកបន្តិច ដោយសារខ្ញុំមានទីលំនៅ នៅខេត្តកោះកុង។





